ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ

# THE RELATIONSHIP BETWEEN PRINCIPALS' LEADERSHIP AND POLICY IMPLIMENTATION OF STEM EDUCATION AT NEW GENERATION SCHOOLS IN PHNOM PENH CITY

កុយ ពៅគង់

**KOY PAOKOUNG**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២២

ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ

THE RELATIONSHIP BETWEEN PRINCIPALS' LEADERSHIP AND POLICY IMPLIMENTATION OF STEM EDUCATION AT NEW GENERATION SCHOOLS IN PHNOM PENH CITY

**កុយ ពៅគង់**

**KOY PAOKOUNG**

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២២

គ្រូណែនាំគោលៈ បណ្ឌិត ឈាង សទ្ធាត

គ្រូណែនាំរង ៖ បណ្ឌិត អៃ សុងហ៊ាង

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

នាងខ្ញុំសូមធ្វើការបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា **«ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពី ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ»** សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង ហើយស្នាដៃនេះពុំទាន់ត្រូវបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលយកសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើមួយនៅឡើយទេ។ មានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់នៅក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះក្នុងបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំប្រាកដមែន។

ថ្ងៃពុធ ៧កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខាបេក្ខជន**



**ភុយ ពៅគង់**

# លិខិតបញ្ជាក់គ្រូណែនាំ

**បណ្ឌិត ឈាង សង្វាត** ជាគ្រូណែនាំគោល

**បណ្ឌិត អៃ សុងហៀង** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

និស្សិតឈ្មោះ **កុយ ពៅគង់** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពីការ អប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ**» ពិតប្រាកដមែន។

ថ្ងៃពុធ ៧កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២

**បណ្ឌិត ឈាង សង្វាត** **បណ្ឌិត អៃ សុងហៀង**

គ្រូណែនាំគោល គ្រូណែនាំរង

# លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ និងគណៈកម្មការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ**...៣៧០២៤...**អយក.ខុទក**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោងៈ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | លាង សេងហាក់ | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ រ៉ាំ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អៃ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វដអ

# មូលន័យសង្ខេប

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "**ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពីការ អប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ**» មានគោលបំណងសិក្សាពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម និងកិច្ចគាំទ្រដល់ដំណើរការបង្រៀនរបស់គ្រូ តាមរយៈការអនុវត្តគោលនយោបាយអប់រំស្ទែមរបស់នាយកសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ។ ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ ដែលមានភាគសំណាកគ្រូបង្រៀន និងគណៈគ្រប់គ្រងចំនួន ១២៣ នាក់ និង អ្នកចូលរួមសម្ភាសន៍ចំនួន ៩នាក់។ សូចនាករបរិមាណវិស័យ ដើម្បីវាស់ពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម មានចំនួនសរុប ៧៩ និងសូចនាករសម្រាប់វាស់ពីការអនុវត្តគោលនយោបាយអប់រំស្ទែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ មានចំនួនសរុប ១៦។

ជាលទ្ធផល ទិន្នន័យដែលទទួលបានពីគ្រូបង្រៀន និងគណៈគ្រប់គ្រងទៅលើភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែមនៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ មានទំនាក់ទំនងគ្នា ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុសរុប=៤.៤០)។ តាមរយៈទិន្នន័យដែលទទួលបានពីការសម្ភាសន៍ បានបង្ហាញថាភាពជាអ្នកដឹកនាំរបស់នាយក ត្រូវតែមានទំនាក់ទំនងជាមួយការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី។ តាមរយៈទិន្នន័យបរិមាណវិស័យ អ្នកសិក្សាស្រាវជ្រាវអាចទាញសេចក្តីសន្និដ្ឋានបានថាការអនុវត្តគោលនយោបាយអប់រំស្ទែមរបស់នាយកសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ បានផ្តល់កិច្ចគាំទ្រដល់ដំណើរការបង្រៀនរបស់គ្រូ ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុសរុប=៤.៣២) និងទិន្នន័យគុណវិស័យបានបង្ហាញថា ការអនុវត្តតាមគោលនយោបាយអប់រំរបស់នាយកសាលារៀនជំនាន់ថ្មី បានផ្តល់កិច្ចគាំទ្រដល់គ្រូបង្រៀនលើស្វ័យភាពនៃការសម្រេចចិត្តក្នុងដំណើរការបង្រៀន ពង្រឹង

កញ្ចប់សមត្ថភាពបន្ថែមលើជំនាញវិជ្ជាជីវៈ បំណិនក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងឆ្លើយតបទាន់ពេលវេលាទៅនឹងការអប់រំក្នុងយុគសម័យឌីជីថល។

សរុបសេចក្តីមក ភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី ត្រូវតែមានទំនាក់ទំនងគ្នា សំដៅផ្តល់កិច្ចគាំទ្រដល់ដំណើរការបង្រៀនរបស់គ្រូ បានអភិវឌ្ឍសមត្ថភាពគ្រូ ពង្រឹងគុណភាពអប់រំ និងលើកកម្ពស់លទ្ធផលសិក្សាសិស្សឱ្យឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទឧស្សាហកម្ម៤.០។

**ពាក្យគន្លឹះ៖ ទំនាក់ទំនង អ្នកដឹកនាំរបស់នាយក គោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា សាលារៀនជំនាន់ថ្មី**

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំសូមគោរពថ្លែងអំណរគុណដល់ឯកឧត្តមនាយក លោកនាយករង លោក លោកស្រីដែលជាសាស្ត្រាចារ្យ និងគណៈកម្មការគ្រប់គ្រងវគ្គបណ្តុះបណ្តាលនេះទាំងអស់ដែលបានយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលនិស្សិតទាំងអស់ រហូតបានជោគជ័យ។ នាងខ្ញុំក៏មិនអាចបំភ្លេចបាននូវការដឹងគុណជូនចំពោះ បណ្ឌិត **ឈាង សង្វាត** ជាគ្រូណែនាំគោល និងបណ្ឌិត **អៃ សុងហ៊ាង** ជាគ្រូណែនាំរង បានចំណាយពេលវេលាដ៏មានតម្លៃជួយបង្ហាត់បង្ហាញ លើផ្នែកបច្ចេកទេស វិធីសាស្ត្រនៃការរៀបចំ និងផ្តល់ជាធាតុចូលសំខាន់ៗសម្រាប់សំណេរស្រាវជ្រាវ ព្រមទាំងលើកទឹកចិត្តដល់រូបនាងខ្ញុំ។

នាងខ្ញុំក៏មិនអាចបំភ្លេចបានក្នុងការបង្ហាញនូវសេចក្តីដឹងគុណសម្រាប់ការចូលរួមចំណែក ផ្តល់ជាធាតុចូលសម្រាប់កិច្ចការស្រាវជ្រាវរបស់នាងខ្ញុំពីសំណាក់លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងនៅសាលារៀនជំនាន់ថ្មីទាំងពីរ និងមន្ត្រីក្នុងវិស័យអប់រំផ្សេងៗទៀតដែលបានចូលរួមផ្តល់ទិន្នន័យតាមរយៈកម្រងសំណួរ និងសំណួរសម្ភាសន៍ដល់នាងខ្ញុំសម្រាប់ការសរសេរនិក្ខេបបទនេះទទួលបានជោគជ័យ។

នាងខ្ញុំសូមគោរពអរគុណចំពោះក្រុមគ្រួសារ មិត្តភក្តិដែលបានគាំទ្រ និងលើកទឹកចិត្តឱ្យនាងខ្ញុំបន្តការសិក្សាដើម្បីអភិវឌ្ឍលើជំនាញអប់រំនេះ។

ជាទីបញ្ចប់នាងខ្ញុំសូមគោរពជូនពរចំពោះឯកឧត្តម លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ អ្នកនាង កញ្ញា និងមិត្តរួមជំនាន់ទាំងអស់សូមមានសុខភាពល្អ កម្លាំងកាយមាំមួន ជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ..................................................... i

លិខិតបញ្ជាក់គ្រូណែនាំ ..................................................... ii

លិខិតឧទ្ទេសនាមគណៈកម្មការមេប្រយោគ និងគណៈកម្មការការពារនិក្ខេបបទ ..................................................... iii

សេចក្តីថ្លែងអំណរគុណ ..................................................... vii

មាតិកា ..................................................... viii

បញ្ជីតារាង ..................................................... xii

បញ្ជីអក្សរកាត់ ..................................................... xiii

ជំពូកទី១៖ សេចក្តីផ្តើម ..................................................... 1

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ..................................................... 1

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ..................................................... 3

១.៣ គោលបំណងនៃការស្រាវជ្រាវ ..................................................... 7

១.៤ សំណួរស្រាវជ្រាវ ..................................................... 7

១.៥ សារៈសំខាន់នៃការស្រាវជ្រាវ ..................................................... 7

១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..................................................... 8

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..................................................... 8

ជំពូកទី២៖ រំឭកទ្រឹស្តី ..................................................... 10

២.១ គោលនយោបាយអប់រំស្នែម ..................................................... 10

២.១.១ និយមន័យការអប់រំស្នែម ..................................................... 10

២.១.២ ខ្លឹមសារសំខាន់នៃគោលនយោបាយអប់រំស្នែម នៅកម្ពុជា ..................................................... 11

**២.២ ការអនុវត្តគោលនយោបាយអប់រំស្ទែម** ....................................................12
២.២.១ ការអនុវត្តគោលនយោបាយអប់រំស្តីពីស្ទែម.................................................... 12
២.២.២ សាលារៀនជំនាន់ថ្មី និងការបញ្ចូលការអប់រំស្ទែម............................................. 13
**២.៣ តួនាទី និងភារកិច្ចរបស់នាយកសាលារៀនជំនាន់ថ្មី**.............................................15
**២.៤ ភាពជាអ្នកដឹកនាំរបស់នាយកក្នុងការរៀន និងបង្រៀន**.........................................17
២.៤.១ និយមន័យភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀន.......................................... 17
២.៤.២ សមាសភាគនៃភាពជាអ្នកដឹកនាំរបស់នាយកក្នុងការរៀន និងបង្រៀន.........................18
២.៤.៣ ភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនសម្រាប់ការសិក្សានាសតវត្សរ៍ទី២១..................19
**២.៥ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម**..................................................................21
**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** .................................................................25
**៣.១ គម្រោងស្រាវជ្រាវ** .....................................................................25
៣.១.១ ការសិក្សាស្រាវជ្រាវបរិមាណវិស័យ ..................................................... 27
៣.១.១.១ ការគណនាភាគសំណាក.......................................................... 27
៣.១.១.២ ឧបករណ៍សម្រាប់ការស្រាវជ្រាវ................................................... 28
៣.១.១.៣ កម្រិតចង្អុលបង្ហាញ ...........................................................29
៣.១.១.៤ កម្រងសំណួរ....................................................................30
៣.១.១.៥ ការប្រមូលទិន្នន័យតាមបរិមាណវិស័យ .........................................34
៣.១.១.៦ ការវិភាគទិន្នន័យបរិមាណវិស័យ ................................................34
៣.១.២ ការសិក្សាស្រាវជ្រាវគុណវិស័យ..........................................................34
៣.១.២.១ អ្នកចូលរួមសម្ភាសន៍ ...........................................................35
៣.១.២.២ សំណួរសម្ភាសន៍...............................................................37
៣.១.២.៣ ការប្រមូលទិន្នន័យគុណវិស័យ ...................................................38

៣.១.២.៤ ការវិភាគទិន្នន័យតាមគុណវិស័យ ........ 38

**៣.២ ក្រមសីលធម៌នៃការស្រាវជ្រាវ** ........ 39

**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា** ........ 40

**៤.១ ទិន្នន័យព័ត៌មានទូទៅ** ........ 40

៤.១.១ ព័ត៌មានទូទៅរបស់គ្រូបង្រៀន ........ 40

៤.១.២ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀន ........ 41

**៤.២ លទ្ធផលបរិមាណវិស័យលើទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម** ........ 42

៤.២.១ ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី ........ 42

ក.ទិន្នន័យបរិមាណវិស័យ ........ 42

៤.២.២ ការអនុវត្តគោលនយោបាយអប់រំស្ទែម ........ 52

ក. ទិន្នន័យបរិមាណវិស័យ ........ 52

ខ. ទិន្នន័យគុណវិស័យ ........ 57

**៤.៣ ពិភាក្សាលើទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី** ........ 60

**៤.៤ ការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ** ........ 71

៤.៤.១ ទិន្នន័បរិមាណវិស័យ ........ 71

៤.៤.២ ទិន្នន័យគុណវិស័យ ........ 74

**៤.៥. ពិភាក្សាលើការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ** ........ 75

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 83

**៥.១ សេចក្តីសន្និដ្ឋាន** ........ 83

**៥.២ សំណូមពរ** ........ 86

ឯកសារយោង ........................................................................................88
ឧបសម្ព័ន្ធ ...............................................................................................93

# បញ្ជីតារាង

តារាង៣.១៖ គម្រោងស្រាវជ្រាវរៀបរាប់ពីវិធីសាស្រ្តបរិមាណវិស័យ និងគុណវិស័យ.........26

តារាង៣.២៖ ភាគសំណាក់ក្នុងការចុះប្រមូលទិន្នន័យបរិមាណវិស័យ.........28

តារាង៣.៣៖ អ្នកចូលរួមផ្តល់បទសម្ភាសន៍.........35

តារាង៤.១៖ ការគ្រប់គ្រងបង្រៀន និងរៀន.........42

តារាង៤.២៖ ការគ្រប់គ្រងរដ្ឋបាល.........45

តារាង៤.៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ.........47

តារាង៤.៤៖ ការគ្រប់គ្រងធនធានមនុស្ស.........49

តារាង៤.៥៖ ការអនុវត្តគោលនយោបាយអប់រំស្នែម.........52

តារាង៤.៦៖ ភាពជាអ្នកដឹកនាំរបស់នាយកសាលារៀនជំនាន់ថ្មី.........60

តារាង៤.៧៖ សរុបរួមការអនុវត្តគោលនយោបាយអប់រំស្នែម.........63

តារាង៤.៨៖ សូចនាករដែលមានមធ្យមពិន្ទុខ្ពស់ និងទាបស្តីពីការអនុវត្តគោលនយោបាយអប់រំស្នែម.........63

តារាង៤.៩៖ ទិន្នន័យគ្រូបង្រៀន និងគណៈគ្រប់គ្រងស្តីពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែម.........65

តារាង៤.១០៖ ការអនុវត្តគោលនយោបាយអប់រំស្នែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ.........71

តារាង៤.១១៖ សង្ខេបការអនុវត្តគោលនយោបាយអប់រំស្នែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ.........76

តារាង៤.១២៖ សង្ខេបសូចនាករដែលមានមធ្យមភាគខ្ពស់ និងទាបស្តីការអនុវត្តគោលនយោបាយអប់រំស្នែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ.........77

# បញ្ជីអក្សរកាត់

ICT : Information Communication Technology

KAPE : Kampuchea Action to Promote Education

MoEYS : Ministry of Education, Youth and Sport

NEP : NGO Education Partnership

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការអប់រំមានការផ្លាស់ប្តូរទៅតាមស្ថានភាព និងគោលដៅអភិវឌ្ឍនៃប្រទេសជាតិនីមួយៗ ស្របតាមបរិបទតំបន់ និងសកលលោក។ ឆ្លើយតបទៅនឹងតម្រូវការនេះក្រសួងអប់រំ យុជន និងកីឡា បានធ្វើកំណែទម្រង់ស៊ីជម្រៅដោយបានបង្កើតគោលនយោបាយចំនួន ២ចំណុច ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ រួមមាន ១) ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ដើម្បីគាំទ្រដល់ផែនការយុទ្ធសាស្ត្រខាងលើក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាចំនួន ៤ដូចជា ១) យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ ២) យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា ៣) យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជន និង៤) យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។ នៅក្នុងយុទ្ធសាស្ត្រកំណែទម្រង់ទី១ "យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ" បានឆ្លើយតបទៅនឹងគោលនយោបាយទី២ដោយសំដៅលើការអនុវត្តការបំពេញការងាររបស់មន្ត្រីអប់រំដើម្បីចូលរួមលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស ដែលឆ្លុះបញ្ចាំងប្រសិទ្ធភាពនៃការដឹកនាំគ្រប់គ្រងរបស់នាយក (ក្រសួងអ.យ.ក, ២០១៨)។ នាយកដែលល្អគឺនាយកដែលបង្កើតបរិស្ថានល្អសម្រាប់ការរៀន និងបង្រៀនបានចូលរួម ២៥% នៃលទ្ធផលសិក្សារបស់សិស្ស (ហាង់ជួន, ២០២០)។

ចាប់តាំងពីឆ្នាំ ២០១៧ មកកំណែទម្រង់វិស័យអប់រំបានដល់កម្រិតសាលារៀនដោយបានអនុម័តឯកសារស្តីពីការគ្រប់គ្រងដោយឈរលើលទ្ធផល ផ្តោតលើសមាសភាពចំនួន ៤ គឺ ១) ការគ្រប់គ្រងរដ្ឋបាល ២) ការគ្រប់ការរៀន និងបង្រៀន ៣) ការគ្រប់គ្រងធនធានមនុស្ស និង៤) ការគ្រប់គ្រងហិរញ្ញវត្ថុ។ ការគ្រប់គ្រងដោយឈរលើលទ្ធផលជាកម្មវិធីកំណែទម្រង់មួយរបស់MoEYS សម្រាប់ផ្តល់ជូននាយក និងគណៈគ្រប់គ្រង

សាលាអនុវត្តតាមដើម្បីសម្រេចបាននូវគោលនយោបាយរបស់ក្រសួងក្នុងការរៀបចំសាលារៀនឱ្យក្លាយទៅជាសាលារៀនសហគមន៍ ដើម្បីសហគមន៍ និងសហគមន៍ចូលរួមអភិវឌ្ឍផ្តោតលើការបណ្តុះបណ្តាលឱ្យទទួលបាននូវលទ្ធផលសិក្សារបស់សិស្សដែលឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋាន និងសម្រេចតាមគោលដៅអប់រំជាតិបច្ចុប្បន្នដោយធ្វើវិមជ្ឈការនៅក្នុងវិស័យអប់រំដល់កម្រិតសាលារៀននូវស្វ័យភាពលើដំណើរការគ្រប់គ្រងសាលាជាពិសេសលើដំណើរការបង្រៀនរបស់គ្រូ និងការធ្វើតេស្តវង្វាយតម្លៃដើម្បីធ្វើឱ្យបរិស្ថានសិក្សាមានផាសុកភាព ការអប់រំមានគុណភាពល្អ ពង្រឹងលើលទ្ធផលសិក្សាសិស្ស (Gamage, 2018)។

ការបណ្តុះបណ្តាលនៅមធ្យមសិក្សាចំណេះទូទៅ បានផ្តល់ឱ្យសិស្សានុសិស្ស ជ្រើសរើសថ្នាក់វិទ្យាសាស្ត្រពិត និងថ្នាក់សង្គម ទៅតាមចំណង់ចំណូលចិត្ត និងទេពកោសល្យពីកំណើតដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់ឆ្នាំ២០៥០ យកចិត្តទុកដាក់លើការអភិវឌ្ឍវិស័យឧស្សាហកម្ម (ក្រសួងអ.យ.ក, ២០១៩)។ ខណៈដែលបច្ចុប្បន្នប្រទេសយើងនៅមានបញ្ហាប្រឈមលើកាអភិវឌ្ឍវិស័យនេះដូចជាខ្វះធនធានមនុស្សផ្នែកបច្ចេកទេស និងអ្នកជំនាញ ស្ថានភាពឧស្សាហកម្មនៅមានសភាពតូចចង្អៀត មានលក្ខណៈសាមញ្ញមិនទាន់មានសមត្ថភាពប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិនៅឡើយទេ ហើយត្រូវការធនធានមនុស្សផ្នែកស្ទែមដែលកំពុងតែខ្វះខ្លាំង ដើម្បីផ្លាស់ប្តូរពីឧស្សាហកម្មអតពលកម្មឈានទៅឧស្សាហកម្មជំនាញត្រឹមឆ្នាំ ២០២៥ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៥)។ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានេះដើម្បីជាផែនទីបង្ហាញផ្លូវសម្រាប់ដោះស្រាយបញ្ហាប្រឈមដែលកំពុងកើតមាន និងលើកកម្ពស់ការអប់រំស្ទែម ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ស្របតាមសម័យកាល ឱ្យពួកគេមានជំនាញសតវត្សរ៍ទី២១ ហើយសិស្ស និស្សិតអាចផ្សារភ្ជាប់ចំណេះដឹងទៅនឹងជីវភាពរស់នៅក្លាយជាពលរដ្ឋដែលមានមូលធនមនុស្សសម្រាប់ចូលរួមកសាងសង្គមមានស្តង់ដាប្រាក់បៀវត្ស សុវត្ថិភាព សេដ្ឋកិច្ច ចំណូលខ្ពស់ និងនាំឱ្យមានកំណើនសេដ្ឋកិច្ចជាតិ ដើម្បី

អភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយចីរភាព សេចក្តីថ្លៃថ្នូរ និងសេរីភាពស្មើសិទ្ធិជាមួយអន្តរជាតិ (ក្រសួងអ.យ.ក, ២០១៦)។

ការបង្កើតសាលារៀនជំនាន់ថ្មី មានគោលដៅរួមក្នុងការបង្កើតគំរូអភិវឌ្ឍថ្មីមួយនៅក្នុងប្រព័ន្ធអប់រំសាធារណៈស្វយ័តមួយដែលមានគណនេយ្យភាព និងអភិបាលកិច្ច ព្រមទាំងស្តង់ដារវិជ្ជាជីវៈខ្ពស់ សម្រាប់ការសិក្សាជំនាញសតវត្សរ៍ទី២១ដែលមានគោលបំណងលើការអនុវត្តគោលនបាយអប់រំស្វែម ជាមួយនឹងប្រព័ន្ធវាយតម្លៃតឹងរ៉ឹង មានស្តង់ដាអភិបាលកិច្ចខ្ពស់។ សាលារៀនជំនាន់ថ្មី ក៏ផ្តោតលើការផ្តល់ចំណេះដឹងបច្ចេកវិទ្យាដល់គ្រូ និងសិស្សដោយសង្ឃឹមថាគ្រូ និងសិស្សនឹងមានចំណេះដឹងICTខ្ពស់អាចប្រើប្រាស់ក្នុងថ្នាក់រៀន ហើយសិស្សអាចអភិវឌ្ឍសមត្ថភាពយល់ដឹងបន្ថែមទៀតដូចជាការគិតល្អិតល្អន់ ការបង្កើតថ្មី ការសហការណ៍ ទំនាក់ទំនង និងការដោះស្រាយបញ្ហាក្នុងជីវភាព។ ការខិតខំប្រឹងប្រែងកន្លងមកបានធ្វើឱ្យសិស្សានុសិស្ស និងយុវជនទទួលបានសេវាអប់រំពីសាលាសារធារណៈប្រកបដោយគុណភាពខ្ពស់ដែលមានការទទួលស្គាល់ពីមហាជន (ក្រសួងអ.យ.ក,២០១៨)។ សាលារៀនជំនាន់ថ្មី ជាគម្រូសាលាក្នុងសាលាមួយដែលភាពជាអ្នកដឹកនាំរបស់នាយកតាមបែបការគ្រប់គ្រងដោយឈរលើលទ្ធផល និងអនុវត្តគោលនយោបាយអប់រំស្វែម សំដៅបង្កើតនូវបរិយាកាសសិក្សាដែលសិស្សត្រូវខិតខំស្រាជ្រាវដើម្បីអាចធ្វើកិច្ចការដែលគ្រូដាក់ឱ្យដូចជាកិច្ចការក្រុម ការធ្វើគម្រោង នាំមកនូវបរិបទដែលសិស្សត្រូវមានសកម្មភាពសិក្សាដោយខ្លួនឯង បានជួយគាំទ្រគោលដៅអភិវឌ្ឍប្រកបដោយចីរភាពក្នុងវិស័យអប់រំ (Melissa Donaher & Nuoya Wu, 2020)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី បានទទួលឥទ្ធិពលការគ្រប់គ្រងដោយឈរលើលទ្ធផលដែលជាប្រព័ន្ធគ្រប់គ្រងសាលាសាធារណៈកំពុងតែពេញនិយមនៅប្រទេសជាច្រើនលើពិភពលោក ដែលផ្តល់ស្វ័យភាពកម្រិតខ្ពស់ដល់បុគ្គលិកជាចម្បង។ តាមការសិក្សាស្រាវជ្រាវបានង្ហាញថាការគ្រប់គ្រងបែបនេះមានប្រសិទ្ធភាពក្នុងការពង្រឹងលទ្ធផលសិក្សារបស់សិស្សដែលតម្រូវឱ្យនាយកមានជំនាញលើការបង្រៀន និងការគ្រប់គ្រងក៏ដូចជាមានស្វ័យភាពពិតប្រាកដដើម្បីអនុវត្តការផ្លាស់ប្តូរផ្សេងៗនៅក្នុងសាលា។ ភាពជាអ្នក

ដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី មានស្វ័យភាពទៅលើដំណើរការគ្រប់គ្រងសាលារៀន និងទទួលបានមូលនិធិទ្រទ្រង់ដំណើរការសាលារៀនដោយរដ្ឋាភិបាល ដៃគូរអភិវឌ្ឍ បដិភាគពីអាណាព្យាបាល (Char Vann, 2018)។ ប្រហែល ៨០% នៃការវិនិយោគទៅលើសាលាត្រូវបានផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា និងប្រហែល ២០% ទៀតទទួលបានពីប្រភពចំនួន ៣ ផ្សេងទៀតចាប់តាំងពីឆ្នាំ ២០១៥ សម្រាប់ទ្រទ្រង់ដល់ដំណើរការបង្រៀន និងរៀន ការរៀបចំតេស្តវង្វាយតម្លៃលើការបង្រៀន និងរៀននៅសាលានេះក្នុងគោលបំណងផ្តល់ឱ្យសិស្សនូវចំណេះដឹងវិទ្យាសាស្ត្រ (ក្រសួងអ.យ.ក, ២០១៨)។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្សក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងនិន្នាការអប់រំក្នុងតំបន់ និងសកល ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅឆ្នាំ២០១៦ដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ និងឧត្តមសិក្សា សាធារណៈ និងឯកជន (ក្រសួងអ.យ.ក, ២០១៦) ក្នុងគោលបំណងអភិវឌ្ឍសិស្សចំណេះទូទៅ និងនិស្សិតឧត្តមសិក្សាឱ្យមានសមត្ថភាពស្ទែម ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងសហគមន៍អាស៊ាន។ ជាលទ្ធផលកំណែទម្រង់សាលារៀនជំនាន់ថ្មី ទទួលបានជោគជ័យដោយសម្រេចបានលទ្ធផលដែលចង់បាន។ តាមរយៈលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិសិស្សដែលមកពីសាលារៀនជំនាន់ថ្មី ធ្វើបានល្អជាងសិស្សសាលាផ្សេង។ ប៉ុន្តែការអនុវត្តគោលនយោបាយនេះ នៅមានបញ្ហាប្រឈមមួយចំនួនដូចជាចំនួនដែលសិស្សចាប់យកជំនាញស្ទែម នៅតិចនៅឡើយ ចំនួនសិស្សដែលចាប់អារម្មណ៍លើការសិក្សាថ្នាក់វិទ្យាសាស្ត្រមានការថយចុះខ្លាំងពេលដល់ថ្នាក់ឧត្តមសិក្សា។ ចំណែកនៅមធ្យមសិក្សាចំណេះទូទៅសិស្សសម្រេចចិត្តរៀនផ្នែកសង្គមច្រើនជាងផ្នែកវិទ្យាសាស្ត្រដែលធ្វើឱ្យប្រទេសកម្ពុជាជួបប្រទះនូវកង្វះអ្នកជំនាញផ្នែកវិទ្យាសាស្ត្រ (Kaing, 2016)។ មូលហេតុដែលធ្វើឱ្យចំនួនអ្នកចាប់យកការអប់រំស្ទែម នៅមានកម្រិតនេះដោយសារមានបញ្ហាប្រឈមមួយចំនួននៅក្នុងការអនុវត្តគោលនយោបាយអប់រំស្ទែម ដូចជាកង្វះធនធានគ្រូបង្រៀនដែលមានចំណេះដឹងលើស្ទែម ចំណាប់អារម្មណ៍សិស្សលើបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រនៅមានកម្រិតទាប ហេដ្ឋារចនាសម្ព័ន្ធមិនទាន់សម

ស្របតាមស្តង់ដា ប្រព័ន្ធដឹកនាំសាលារៀននៅមានកម្រិត គោលនយោបាយអប់រំនៅមានកម្រិត កម្មវិធីសិក្សាមិនសូវឆ្លើយតបទៅនឹងការអប់រំស្នែម (ក្រសួងអ.យ.ក, ២០១៦)។ លើសពីនេះទៅទៀតការសិក្សាស្រាវជ្រាវក៏រកឃើញវិធីសាស្ត្រនៃការវាយតម្លៃគឺជាកត្តាចាំបាច់ក្នុងការអនុវត្តគោលនយោបាយអប់រំស្នែម ផងដែរ (Marshall, 2010) និងការខ្វះព័ត៌មានឱ្យបានគ្រប់ជ្រុងជ្រោយទៅលើការសម្រេចចិត្តសិក្សាផ្នែកសង្គម និងផ្នែកវិទ្យាសាស្ត្រនៅកម្រិតមធ្យមសិក្សា ដែលធ្វើឱ្យសិស្សជ្រើសរើសយកការសិក្សាផ្នែកសង្គមច្រើនជាង (Kaing, 2016)។ តាមរយៈលទ្ធផលនៃការអនុវត្តគោលនយោបាយអប់រំស្នែម នៅសាលារៀនជំនាន់ថ្មីទទួលបានលទ្ធផលសិក្សារបស់សិស្សប្រសើរឡើង ជាងការអនុវត្តគោលនយោបាយនេះនៅសាលាផ្សេង។ ជារួមទោះបីការចេញគោលនយោបាយអប់រំស្នែម ជាចំណុចគន្លឹះចូលរួមក្នុងការអភិវឌ្ឍប្រទេសពិតមែន ប៉ុន្តែការអនុវត្តគោលនយោបាយនេះជារួមនៅប្រទេសយើងនៅមិនទាន់ជោគជ័យបានប្រសើរដូចការរំពឹងទុកនៅឡើយទេ។

ការអនុវត្តគោលនយោបាយជាអន្តរកម្មនៃការកំណត់គោលដៅ និងសកម្មភាព។ ដើម្បីអនុវត្តគោលនយោបាយត្រូវមានផែនការសកម្មភាពមានការបែងចែកការទទួលខុសត្រូវ ផ្តល់នូវក្របខណ្ឌគតិយុត្ត មានការបណ្តុះបណ្តាលធនធានមនុស្ស និងដំណើរការអនុវត្តដែលមានការផ្សព្វផ្សាយ ការត្រួតពិនិត្យតាមដាន វង្វាយតម្លៃ កែតម្រូវ និងបន្តអនុវត្តរហូតដល់សម្រេចគោលដៅដែលបានកំណត់។ កត្តាសំខាន់ដែលមិនអាចខ្វះបានក្នុងការអនុវត្តគោលនយោបាយឱ្យមានប្រសិទ្ធភាពគឺធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានសម្ភារៈបរិក្ខារគ្រប់គ្រាន់ដែលជាកត្តាមិនអាចខ្វះបាន។ ភាពជោគជ័យនៃការអនុវត្តគោលនយោបាយមួយបានអាស្រ័យដោយកត្តាជាច្រើនដូចជា ១) មានការទទួលយកនៃសង្គមគឺការរៀបចំសង្គម ២) មានគោលបំណងតែមួយគឺការយល់ដឹងរវាងអ្នកធ្វើ និងអ្នកទទួលដើម្បីឱ្យមានភាពស៊ីសង្វាក់គ្នារវាងអ្នកដាក់ចេញគោលនយោបាយ និងអ្នកអនុវត្ត ៣) មានសមត្ថភាពក្នុងការអនុវត្ត គឺឆ្លុះបញ្ចាំងភាពស៊ីជម្រៅ ទទួលបានពីអ្នកគាំទ្រ និងរិះគន់ ៤) ទំនាក់ទំនងគឺមានការសម្របសម្រួល មានគោលបំណងច្បាស់លាស់ ៥) ការអនុវត្ត

ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលគឺការផ្តល់សិទ្ធអំណាច ៦) ភាពសមហេតុនៃដំណោះស្រាយច្បាស់លាស់ និង ៧) មានធនធានគ្រប់គ្រាន់ និងកិច្ចគាំទ្រ។

សាលារៀនជំនាន់ថ្មី ជាសាលារៀនដែលមានស្វ័យភាពក្នុងការប្រតិបត្តិ មានគណនេយ្យភាព និងអភិបាលកិច្ចខ្ពស់ មានស្តង់ដារវិជ្ជាជីវៈខ្ពស់ មានក្របខណ្ឌបែងចែកធនធានប្រកបដោយភាពសនិទាន មានស្វ័យភាពប្រតិបត្តិការផ្អែកលើការទទួលបានការបន្តការទទួលស្គាល់ដោយអនុវត្តតាមគោលនយោបាយអប់រំស្នែម។ គោលនយោបាយអប់រំស្នែម ដែលបានដាក់ចេញក្នុងឆ្នាំ ២០១៦ បានឆ្លើយតបទៅនឹងទិដ្ឋភាពទាំងប្រាំមួយនៃការដាក់ចេញគោលនយោបាយដូចះ ១) កត្តានយោបាយ ២) កត្តាសង្គម ៣) កត្តាសេដ្ឋកិច្ច ៤) កត្តាសកលភាវូបនីយកម្ម កត្តាបច្ចេកវិទ្យា កត្តាអប់រំ។ យោងតាម Wikipedia (2022) បានបញ្ជាក់ថាគោលនយោបាយអប់រំជាគោលការណ៍ដែលរដ្ឋាភិបាលបង្កើតឡើងក្នុងវិស័យអប់រំ ឬជាច្បាប់ ជាវិធាន ដែលគ្រប់គ្រងលើការប្រតិបត្តិនៅក្នុងប្រព័ន្ធអប់រំដោយផ្តោតលើការអនុវត្តជាក់ស្តែង។ វាពិនិត្យមើលទំនាក់ទំនងរវាងគោលនយោបាយអប់រំ និងការអនុវត្តការអប់រំ។ ការអនុវត្តគោលនយោបាយអប់រំគឺមានន័យថាអនុវត្តច្បាប់ដែលតម្រូវឱ្យអ្នកអនុវត្តត្រូវសម្របទៅនឹងស្ថានភាពថ្មីក្រោមការគំរាមពិន័យ។ ដូចនេះសម្រាប់ការអនុវត្តគោលនយោបាយអប់រំស្នែម គឺជាច្បាប់សម្រាប់ឱ្យនាយក គ្រូបង្រៀន សិស្សចូលរួមអនុវត្តតាមដើម្បីសម្រេចគោលដៅគឺលទ្ធផលសិក្សារបស់សិស្សដែលមានចំណេះដឹងស្នែម ឆ្លើយតបទៅនឹងតម្រូវការធនធានមនុស្ស។ យោងតាមសៀវភៅកំណែទម្រង់សាលារៀនកម្ពុជា (២០២០) បានបញ្ជាក់ថាលទ្ធផលសិក្សារបស់សិស្សចំណុះឱ្យកត្តាធំៗចំនួន ៤ គឺះ ១) នាយកល្អ ២) គ្រូល្អ ៣) សិស្សល្អ និង ៤) មាតាបិតា សហគមន៍ល្អ។ ដូចនេះក្នុងការដឹកនាំគ្រប់គ្រងសាលាគណៈគ្រប់គ្រងត្រូវធ្វើរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលាដែលអាចធានាបាននូវការពង្រឹងគុណភាពគ្រូបង្រៀន ការអនុវត្តកម្មវិធីសិក្សា និងគុណភាពសិក្សាថ្នាក់វិទ្យាសាស្ត្រ។ ដូចនេះដើម្បីឱ្យសម្រេចបាននូវប្រសិទ្ធភាពលើការអនុវត្តគោលនយោបាយអប់រំស្នែម នាយកសាលារៀនជំនាន់ថ្មីត្រូវរក្សាឥរិយាបថក្នុងការអនុវត្តការងារតាមក្របខណ្ឌគោលនយោបាយ និងផ្តល់ការគាំទ្រដល់

ការអនុវត្តគោលនយោបាយអប់រំស្នេម គ្រប់គ្រងលើដំណើរការសាលារៀនជំនាន់ថ្មីដោយប្រកាន់ឥរិយាបថគោរពតាមក្របខណ្ឌគោលនយោបាយ គោរពច្បាប់ដោយផ្សារភ្ជាប់ការអនុវត្តគោលនយោបាយនៅក្នុងដំណើរការគ្រប់គ្រងសាលារៀន។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណង៖

- ❖ សិក្សាពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេមនៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ។
- ❖ ស្វែងយល់ពីកិច្ចគាំទ្រដែលបានពីទំនាក់ទំនងនៃភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេម ដល់ការបង្រៀនរបស់គ្រូនៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ។

## ១.៤ សំណួរស្រាវជ្រាវ

១) តើភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេម នៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ មានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះ?

២) តើទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូនៅសាលារៀនជំនាន់ថ្មីក្នុ ងរាជធានីភ្នំពេញយ៉ាងដូចម្តេចខ្លះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទខាងលើនឹងទាញបានលទ្ធផលដែលបានពីការសិក្សាស្រាវជ្រាវស្តីពីទំនាក់ទំនងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេម ព្រមទាំងការផ្តល់កិច្ចគាំទ្រដែលបានពីភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេម ដល់ការបង្រៀនរបស់គ្រូសាលារៀនជំនាន់ថ្មីនៅរាជធានីភ្នំពេញ ហើយតាមរយៈលទ្ធផលនេះ នឹងទាញបានជាសេចក្តីសន្និដ្ឋាន អនុសាសន៍ សំណូមពរដើម្បីជាប្រយោជន៍បានដល់នាយកសាលានានាអនុវត្តគោលនយោបាយអប់រំស្នេមមានប្រសិទ្ធភាពជាងមុន និងបង្រួមគម្លាតនៃការអនុវត្តគោលនយោបាយអប់រំស្នេមនៅមធ្យមសិក្សាចំណេះទូទៅ

ដោយយកប្រធានបទនេះជាករណីសិក្សាមួយដែលអាចឱ្យសាលារៀនផ្សេងៗចាប់ផ្តើមយកគោលនយោបាយអប់រំមកអនុវត្តនៅសលារៀនដើម្បីចូលរួមលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងាររបស់គ្រូបង្រៀន និងលទ្ធផលសិក្សារបស់សិស្សដែលមានភាពឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច។

## ១.៦ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទនេះធ្វើឡើងនៅសាលារៀនជំនាន់ថ្មីទាំងពីរក្នុងរាជធានីភ្នំពេញសម្រាប់គណៈនាយក និងគ្រូបង្រៀនដែលបង្រៀនថ្នាក់ទី ៧ ដល់ទី ១២ មន្ទីរអប់រំរាជធានីភ្នំពេញ មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី នាយកដ្ឋានផែនការ នាយកដ្ឋានគោលនយោបាយ ផ្តោតទៅលើភាពទាក់ទងគ្នានៃភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែម ព្រមទាំងការផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សដោយវាស់ទៅលើគម្លាតរវាងការអនុវត្តគោលនយោបាយអប់រំស្នែម និងភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ ត្រូវបានបែងចែកជា ៥ ជំពូកគឺៈ

- **ជំពូកទី១ៈ** ចំណុចបង្ហាញរួមមានៈ១) លំនាំបញ្ហានៃការស្រាវជ្រាវ ២) ចំណោទបញ្ហានៃការស្រាវជ្រាវ ៣) គោលបំណងនៃការស្រាវជ្រាវ មានចំនួន២ ៤) សំណួរស្រាវជ្រាវមានចំនួនពីរឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវ ៥) សារៈសំខាន់នៃការស្រាវជ្រាវ ៦) ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ៧) រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។
- **ជំពូកទី២ៈ** រំឭកទ្រឹស្តី រំឭកពាក់ព័ន្ធនឹងអថេរ និងពាក្យគន្លឹះ (គោលនយោបាយអប់រំស្នែម ការអនុវត្តគោលនយោបាយអប់រំស្នែម តួនាទី និងភារកិច្ចរបស់នាយកសាលារៀនជំនាន់ថ្មី ភាពជាអ្នកដឹកនាំរបស់នាយកក្នុងការរៀន និងបង្រៀន និងទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្នែម ដើម្បីទាញបានជាគ្រោងគំនិត បង្កើតកម្រងសំណួរ និងសំណួរសម្ភាសន៍ដែលជាឧបករណ៍សម្រាប់ប្រមូលទិន្នន័យ។

- **ជំពូកទី៣៖** វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យត្រូវបានលើកយកមកប្រើប្រាស់នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ។ វិធីសាស្ត្រស្រាវជ្រាវ មានសមាសភាពសំខាន់ៗ ដូចជា៖ គម្រោងស្រាវជ្រាវ ការជ្រើសរើសភាគសំណាក ឧបករណ៍ស្រាវជ្រាវ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងក្រមសីលធម៌នៃការស្រាវជ្រាវ។
- **ជំពូកទី៤៖** បង្ហាញពីលទ្ធផលស្រាវជ្រាវទៅលើសំណួរស្រាវជ្រាវដែលបានមកពីការប្រមូលទិន្នន័យនៃ វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ រួចទាញកិច្ចពិភាក្សា សំយោគបញ្ចូលគ្នាដើម្បីឆ្លុះបញ្ចាំងទៅលើទំនាក់ទំនងនៃភាពជាអ្នកដឹកនាំរបស់នាយកសាលារៀនជំនាន់ថ្មី និងការអនុវត្តគោលនយោបាយស្ទែម។
- **ជំពូកទី៥៖** សេចក្តីសន្និដ្ឋានលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់ និងធ្វើការសំណូមពរដល់ភាគីពាក់ព័ន្ធ។

# ជំពូកទី២
# រំឭកទ្រឹស្តី

## ២.១ គោលនយោបាយអប់រំស្ទែម

### ២.១.១ និយមន័យការអប់រំស្ទែម

តាមទស្សនៈរបស់អ្នកសិក្សាស្រាវជ្រាវផ្សេងៗបានឱ្យនិយមន័យស្រដៀងគ្នាទៅលើការអប់រំស្ទែម។ បើតាមលោក Burnett and Jayaram (2012) និងលោក Hooker (2017) បានលើកឡើងថា ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) គឺចាំបាច់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ភាពប្រកួតប្រជែងអន្តរជាតិ និងការបង្កើតការងារ។ ស្ទែម មានប្រយោជន៍សម្រាប់ពង្រឹងការបណ្តុះបណ្តាលគ្រូនៅតាមបណ្តាលប្រទេសកំពុងអភិវឌ្ឍ ជំរុញការប្រើប្រាស់វិធីសាស្ត្រប្រកបដោយភាពច្នៃប្រឌិត ការសិក្សាស្រាវជ្រាវដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ សម្រាប់ការអប់រំមធ្យមសិក្សាប្រកបដោយគុណភាព និងតម្រឹមតម្រូវការងារ និងការផ្គត់ផ្គង់ជំនាញ។ តាមលោក Holman (2015) ការអប់រំស្ទែម ត្រូវបានគេលើកឡើងដើម្បីបង្កើនផលិតភាពនៅប្រទេសកម្ពុជា បង្កើនសង្វាក់តម្លៃសកល ក៏ដូចជាបង្កើនប្រាក់ឈ្នួល និង កម្រិតជីវភាពរបស់ប្រជាជនកម្ពុជា។ ការអប់រំស្ទែម ត្រូវបានកំណត់ថាជាវិធីសាស្ត្រសម្រាប់ការអភិវឌ្ឍចំណេះដឹង ជំនាញ និងជំនឿអំពីមុខវិជ្ជាស្ទែមជាមួយនឹងវិធីសាស្ត្រអប់រំ (Baran, Canbazoglu Bilici, & Mesutoglu, 2016)។ ការអប់រំស្ទែម គឺជាការសិក្សាដែលផ្តោតលើគោលគំនិតសិក្សាតឹងរ៉ឹង ហើយត្រូវបានផ្សារភ្ជាប់ជាមួយនឹងមេរៀនពិភពលោកជាក់ស្តែងនៅពេលសិស្សអនុវត្ត វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាក្នុងបរិបទដែលភ្ជាប់ទំនាក់ទំនងរវាងសាលារៀន សហគមន៍ ការងារ និងសហគ្រាសសកលដែលអាចជួយអភិវឌ្ឍអក្ខរកម្មស្ទែម ហើយមានសមត្ថភាពប្រកួតប្រជែងក្នុងសេដ្ឋកិច្ចថ្មី (Tsupros, 2009)។

ជារួមការអប់រំស្ទែម គឺជាវិធីសាស្ត្របង្រៀនទំនើបដែលផ្តោតលើបណ្តុំមុខវិជ្ជាដ៏មានសារៈសំខាន់ និងមានភាពចាំបាច់សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការផលិតធនធានមនុស្សដែលមានជំនាញស្ទែម ឱ្យមានសមត្ថភាព ជំនាញច្បាស់លាស់ សីលធម៌ ដោយផ្តោតលើវិធានការដោះស្រាយបញ្ហាក្នុងជីវិតរស់នៅជាក់ស្តែង ការ

អភិវឌ្ឍនូវផលិតផល និងមធ្យោបាយថ្មីៗដែលនឹងជួយសម្រួល និងកែលម្អជីវិត និងការរស់នៅប្រចាំថ្ងៃ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ចជាតិឆ្លើយតបទៅនឹងតម្រូវការការងារក្នុងសតវត្សរ៍ទី២១ បង្កើនកម្លាំងពលកម្មសម្រាប់ជម្រុញការអភិវឌ្ឍប្រទេសជាតិ ជាពិសេសប្រទេសកំពុងអភិវឌ្ឍដូចជាប្រទេសកម្ពុជាជាដើមដែលត្រូវការជំនាញពាក់ព័ន្ធជាមួយ ស្ទែម ដើម្បីឱ្យមានលទ្ធភាពប្រកួតប្រជែងសេដ្ឋកិច្ចក្នុងតំបន់ និងអន្តរជាតិ ក៏ដូចជាដើម្បីការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។

### ២.១.២ ខ្លឹមសារសំខាន់នៃគោលនយោបាយអប់រំស្ទែម នៅកម្ពុជា

គោលនយោបាយស្តីពីការអប់រំស្ទែម ត្រូវបានដាក់ឱ្យដំណើរការអនុវត្ត នៅសាលាចំណេះទូទៅ និងឧត្តមសិក្សាទូទាំងប្រទេសដោយមានការបញ្ជ្រាបលើបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្ររួមមាន គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា និងICT (ក្រសួងអ.យ.ក, ២០១៦)។ ការដាក់ចេញនូវគោលនយោបាយស្តីពីការអប់រំស្ទែម នេះមានខ្លឹមសារសំខាន់ៗដូចជា៖ ទី១) គោលនយោបាយនេះជាផែនទីបង្ហាញផ្លូវសម្រាប់បុគ្គលិកអប់រំ សិស្ស និស្សិត អ្នកស្រាវជ្រាវ និងអ្នកពាក់ព័ន្ធទទួលបានចំណេះដឹង និងសមត្ថភាព នវានុវត្តន៍ លើចំណេះដឹងស្ទែម ដោយគុណភាព និងសមធម៌ ដើម្បីផ្សារភ្ជាប់ចំណេះដឹងទៅនឹងជីវភាពឱ្យមានជំនាញសតវត្សរ៍ទី២១ ដើម្បីចូលរួមលើកកម្ពស់ស្ថានភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេសប្រកបដោយចីរភាព និងសមភាព។ ទី២) ការអភិវឌ្ឍវិស័យស្ទែម ដើម្បីផ្តល់នូវចំណេះដឹង និងកម្លាំងពលកម្មឆ្លើយតបនឹងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម (២០១៥-២០២៥) របស់រាជរដ្ឋាភិបាលកម្ពុជា។ ទី៣) ការងារ មុខរបរដែលពាក់ព័ន្ធនឹងវិស័យស្ទែម កាន់តែពេញនិយម និងទទួលបានប្រាក់ចំណូលខ្ពស់។ ទី៤) ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការអនុវត្តគោលនយោបាយនេះទាមទារឱ្យមានធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងសម្ភារបរិក្ខាគ្រប់គ្រាន់ដែលជាកត្តាមិនអាចខ្វះបាន ដោយក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹម និងជឿជាក់ថាគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នឹងចូលរួមចំណែកជម្រុញ ផ្សព្វផ្សាយគាំទ្រ និងអនុវត្តគោលនយោបាយនេះឱ្យទទួលបានជោគជ័យ (ក្រសួងអ.យ.ក, ២០១៦)។

## ២.២ ការអនុវត្តគោលនយោបាយអប់រំស្ទែម

### ២.២.១ ការអនុវត្តគោលនយោបាយអប់រំស្តីពីស្ទែម

ក្នុងការអនុវត្តគោលនយោបាយស្តីពីការអប់រំស្ទែម គឺត្រូវមានភាគីពាក់ព័ន្ធជាច្រើនដូចជា អ្នករៀបចំគោលនយោបាយ អ្នកគ្រប់គ្រង និងអ្នកអនុវត្ត (គ្រូ និស្សិត សិស្ស អ្នកស្រាវជ្រាវ ជាដើម)។ គោលនយោបាយនេះមានគោលដៅអភិវឌ្ឍសមត្ថភាពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដល់សិស្ស និស្សិត អ្នកស្រាវជ្រាវប្រកបដោយគុណភាព និងសមភាពដើម្បីផ្សារភ្ជាប់ចំណេះដឹងទៅនឹងជីវភាពរស់នៅ ក៏ដូចជាការបង្កើនប្រសិទ្ធិភាពក្នុងការធ្វើសមាហរណកម្មផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាក្នុងការចូលរួមអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម (ក្រសួងអ.យ.ក,២០១៦)។

ពិភពលោកយើងបានឈានមកដល់សម័យកាលបដិវត្តន៍ឧស្សាហកម្ម ៤.0 ដូចច្នេះការប្រើប្រាស់បច្ចេកវិទ្យាពិតជាមានសារៈសំខាន់ណាស់។ ដូចគ្នានេះដែរដើម្បីឱ្យការអនុវត្តគោលនយោបាយស្តីពីការអប់រំស្ទែម មានប្រសិទ្ធិភាពល្អត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និងការប្រើប្រាស់បច្ចេកវិទ្យា សម្ភារៈរូបវន្តគ្រប់គ្រាន់។ នាយកសាលារៀនជំនាន់ថ្មី បានបញ្ជ្រាប គាំទ្រ ជំរុញការអនុវត្តគោលនយោបាយអប់រំស្ទែម នៅក្នុងសាលារៀនដូចជាលើកទឹកចិត្តឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាដើម្បីគាំទ្រការបង្រៀន និងរៀន និងមានច្រើនសកម្មភាពដូចជា៖ ១) នៅបន្ទប់សាស្ត្រាចារ្យមានសមាជិកភាពក្នុងបណ្តាញទំនាក់ទំនងសង្គម ក្រុមអេឡិចត្រូនិចមាន Google Drive បញ្ជូនសារអេឡិចត្រូនិចផ្ទៃក្នុង (អ៊ីម៉ែល និងបណ្តាញសង្គមផ្សេងៗ និងកាលបរិច្ឆេទការប្រជុំផ្លូវការ និងមិនផ្លូវការ) ២) គ្រូបង្រៀនទាំងអស់នៅសាលារៀនជំនាន់ថ្មីត្រូវមានកុំព្យូទ័រយួរដៃផ្ទាល់ខ្លួនមួយគ្រឿងដើម្បីសម្រួលក្នុងការប្រើបច្ចេកវិទ្យានៅក្នុងវិស័យអប់រំដូចជាការធ្វើកិច្ចតែងការបង្រៀនអេឡិចត្រូនិច សម្រាប់ធ្វើបទបង្ហាញនៅក្នុងថ្នាក់រៀន ការស្រាវជ្រាវ និងការសិក្សាតាមអ៊ីនធឺណិត (Internet) ការវាយតម្លៃតាមកម្មវិធីប្រើកុំព្យូទ័រដែលជាតម្រូវការចាំបាច់សម្រាប់ការទទួលបានគុណភាពអប់រំ ៣) សាលារៀនជំនាន់ថ្មីត្រូវមានបន្ទប់កុំព្យូទ័រដែលដំណើរការហើយអាចផ្តល់ឱ្យសិស្ស៥០% ឬច្រើនជាងនេះចូលរៀនបាន ៤) បណ្ណាល័យមានឧបករណ៍សិក្សាចល័តដែលអាចប្រើប្រាស់សេវាបណ្ណាល័យអេឡិចត្រូនិច កម្មវិធីសិក្សាតាម

ប្រព័ន្ធអេឡិចត្រូនិច ការចូលប្រើប្រាស់ថេបប្លេតជាដើម ៥) សហគមន៍នៅក្នុងសាលារៀនជំនាន់ថ្មីត្រូវតែភ្ជាប់ទំនាក់ទំនងគ្នាតាមរយៈសម្ភារៈ ដូចជា Google Drive, Email ការជួបប្រជុំទៀងទាត់ និងបណ្តាញសង្គមផ្សេងៗ ៦) គ្រូទាំងអស់នៅសាលារៀនជំនាន់ថ្មី ត្រូវតែមានគណនី Email ហើយអាចប្រើប្រាស់ម៉ាស៊ីនបញ្ចាំងរូបភាព ឬស្លាយ LCD បាន ៧)សាលារៀនជំនាន់ថ្មី ត្រូវតែប្រើប្រាស់កម្មវិធីកុំព្យូទ័រសម្រាប់អប់រំដើម្បីលើកកម្ពស់ប្រសិទ្ធិភាពទាំងក្នុងការងាររដ្ឋបាល ការបង្រៀន និងរៀន ការវាយតម្លៃដែលត្រូវកំណត់ដោយក្រសួងដូចជា Literatu 3D Classroom SMA ហើយនាយកសាលារៀនជំនាន់ថ្មី បានយកចិត្តទុកដាក់លើការពង្រឹងគុណភាពបង្រៀនដូចជារៀបចំឱ្យមានសហគមន៍វិជ្ជាជីវៈនៅក្នុងសាលា និងការបណ្តុះបណ្តាលគ្រូលើវិធីសាស្ត្របង្រៀន ខ្លឹមសារមេរៀន និងសមត្ថភាពលើការប្រើប្រាស់សម្ភារៈក្នុងបន្ទប់ពិសោធន៍។ មានការលើកទឹកចិត្តដល់ការបង្កើតថ្មី និងការចែករំលែកគំនិតនវានុវត្តន៍ដើម្បីអភិវឌ្ឍសាលារៀន ព្រមទាំងមានការរៀបចំផ្គត់ផ្គង់និងតាមដានការប្រើប្រាស់សម្ភារៈសម្រាប់គាំទ្រដល់ការបង្រៀន និងរៀន បង្កឱ្យមានបរិយាកាសសិក្សាល្អដែលធ្វើឱ្យសិស្សងាយស្រួលសិក្សា មានការបែងចែកតួនាទីភារកិច្ចបុគ្គលិកទៅតាមជំនាញបានត្រឹមត្រូវ មានការតាំងពិពណ៌ស្នាដៃសិក្សា និងការប្រកួតប្រជែងរបស់សិស្សបានទៀងទាត់ ព្រមទាំងមានការតាមដានត្រួតពិនិត្យទៅលើដំណើរការបំពេញការងារ និងវាយតម្លៃលើលទ្ធផលសិក្សា និងការបំពេញការងាររបស់បុគ្គលិកតាមវិទ្យាសាស្ត្រ។ (ក្រសួងអ.យ.ក, ២០១៨)។

### ២.២.២ សាលារៀនជំនាន់ថ្មី និងការបញ្ចូលការអប់រំស្នែម

សាលារៀនជំនាន់ថ្មីគឺមានលក្ខណៈតែមួយដែលការអនុវត្តស្រដៀងគ្នាជាមួយសាលា Charter នៅសហរដ្ឋអាមេរិច។ ការអនុវត្តកិច្ចការនៅក្នុងសាលារៀនផ្អែកលើអ្នកគ្រប់គ្រង និងបុគ្គលិកមានស្វ័យភាពខ្ពស់នៅកម្រិតសាលារៀនលើការប្រតិបត្តិ ធនធាន កម្មវិធីសិក្សា និងការបង្រៀនជាមួយស្តង់ដារវិជ្ជាជីវៈខ្ពស់និងគណនេយ្យភាពសាលារៀនក្នុងគោលបំណងពង្រឹងគុណភាពបង្រៀន និងរៀន (Melissa Donaher & Nuoya Wu, 2020)។ សាលារៀនជំនាន់ថ្មី ជាគំរូរដ្ឋបាលថ្មីមួយដែលមានលក្ខណៈស្វយ័ត មានគណនេយ្យភាព អភិបាលកិច្ចល្អ និងទទួលបានការវិនិយោគពីសាធារណៈជន ហើយនឹងចូលរួមជួយប្រទេសកម្ពុជាក្នុង

ការដោះស្រាយបញ្ហាប្រឈមផ្សេងៗប្រកបដោយប្រសិទ្ធិភាពខ្ពស់ តាមរយៈការលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយនិរន្តរភាព និងជំនាញខ្ពស់លើមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (NEP, 2015)។ សាលារៀននេះបន្ថែមជម្រើសថ្មីមួយទៀតដល់យុទ្ធសាស្ត្រវិនិយោគលើវិស័យអប់រំជាតិ ដែលជួយបំពេញបន្ថែមលើយុទ្ធសាស្ត្រកន្លងមកក្នុងការជួយសាលារៀនរដ្ឋឱ្យសម្រេចបាននូវស្តង់ដារអប់រំពីអប្បបរមាទៅស្តង់ដារអតិប្បរមា មានផ្តល់បន្ថែមសេវាអប់រំលើភាសាអង់គ្លេស បច្ចេកវិទ្យា និងស្ទែម ដល់សិស្ស (ក្រសួងអ.យ.ក, ២០១៨)។ ការកំណត់និយមន័យសាលារៀនជំនាន់ថ្មី រួមមាន គណនេយ្យភាព អភិបាលកិច្ចល្អ ស្តង់ដារវិជ្ជាជីវៈ ស្វ័យភាព ការច្នៃប្រឌិតថ្មីៗ ការវាយតម្លៃទទួលស្គាល់គុណភាព និងប្រព័ន្ធបែងចែកធនធានប្រកបដោយសនិទានភាព (ក្រសួងអ.យ.ក, ២០១៨)។

ការអប់រំស្ទែម និងអាជីពស្ទែម កំពុងដើរតួនាទីយ៉ាងសំខាន់ដើម្បីជួយអភិវឌ្ឍ និងជំរុញកំណើនសេដ្ឋកិច្ចទាំងនៅក្នុងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍឱ្យឆ្ពោះទៅមុខជាពិសេសនៅក្នុងសមាហរណកម្មអាស៊ានដែលមានការប្រកួតប្រជែងក្នុងឆ្នាំ ២០១៥ (Kaing, 2016)។ ប្រទេសកម្ពុជាមានតម្រូវការធនធានមនុស្សយ៉ាងខ្លាំងសម្រាប់ធ្វើនវានុវត្តសាលារៀន កម្មវិធីសិក្សា និងការបង្រៀន ការរៀនសូត្រ ដើម្បីជំរុញ ការអប់រំទំនើប សម្រាប់ជំនាន់ក្រោយតាមរយៈការសាកល្បងសាលារៀនជំនាន់ថ្មី និងអនុវត្តការអប់រំស្ទែម (ក្រសួងអ.យ.ក, ២០១៦)។ សាលារៀននេះត្រូវបានគេចាត់ទុកថាជាសាលាទំនើបមួយដែលលើកកម្ពស់ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធិភាព ការបង្រៀនតារិះរក តាមសហការគ្នា និងការដោះស្រាយបញ្ហាក្នុងន័យផ្សារភ្ជាប់សាលារៀន គ្រូបង្រៀន សិស្ស និងសហគមន៍ប្រកបដោយប្រសិទ្ធិភាព និងចាត់ទុកសាលារៀនជំនាន់ថ្មី ជាបេះដូងនៃដំណើរការបង្រៀន និងរៀនថ្មីៗ គោលនយោបាយអប់រំស្ទែម គឺជាការធ្វើនវានុវត្តមួយដែលមានគោលបំណងពង្រឹងការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងមធ្យោបាយមួយដើម្បីបង្កើនការយកចិត្តទុកដាក់លើមុខវិជ្ជាស្ទែម នៅក្នុងកម្មវិធីសិក្សា (ក្រសួងអ.យ.ក, ២០១៨)។

ដោយសារភាពចាំបាច់ក្នុងការកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាដើម្បីទាក់ទាញទំនុកចិត្តពីសំណាក់សិស្សានុសិស្ស អាណាព្យាបាល សហគមន៍មកលើគុណភាពអប់រំឡើងវិញ សាលារៀនជំនាន់ថ្មីត្រូវបានបង្កើតឡើងដើម្បីធានាបាននូវការពង្រឹងគុណភាពអប់រំទាំងមូលដែលមានការបញ្ចូលការអប់រំបែបទំនើបដូចជា៖ X-reading, Google Classroom, Classroom Observe (ក្រសួងអ.យ.ក, ២០១៦) ដែលធ្វើឱ្យសិស្សានុសិស្សយល់ដឹងកាន់តែច្បាស់ពីគោលវិធីរៀន និងបង្រៀនថ្មីៗរាប់ទាំងវិធីរៀនផ្អែកលើការស្គាល់បញ្ហា វិធីដោះស្រាយបញ្ហា និងវិធីរៀន ស្ពានា និងមានការប្រើប្រាស់បច្ចេកវិទ្យាក្នុងការគ្រប់គ្រង ការបង្រៀន និងរៀនផងដែរ (ក្រសួងអ.យ.ក, ២០១៨) ។ ដើម្បីសម្រេចបានតាមចក្ខុវិស័យ គោលបំណង និងគោលដៅរបស់សាលារៀនជំនាន់ថ្មី ត្រូវមានយុទ្ធសាស្ត្រមួយចំនួនដូចជា ការជ្រើសរើសសាលាយ៉ាងហ្មត់ចត់ ការកសាងភាពជាដៃគូរពីគ្រប់ភាគីពាកព័ន្ធ ការទទួលខុសត្រូវរបស់សាលារៀនជំនាន់ថ្មី ការត្រួតពិនិត្យសាលារៀនជំនាន់ថ្មី ដោយផ្ទាល់ពីថ្នាក់ជាតិ ប្រាក់លើកទឹកចិត្ត ដំណើរការស្វ័យភាពផ្សារភ្ជាប់នឹងការច្នៃប្រឌិតថ្មី ការប្រើប្រាស់បច្ចេកវិទ្យាឱ្យបានទូលំទូលាយដើម្បីជំរុញការច្នៃប្រឌិតថ្មី ការពង្រឹងសិទ្ធិអំណាចយុវជន ការបង្កើនម៉ោងបង្រៀន និងរៀន ការដាក់ឱ្យអនុវត្តនូវមុខវិជ្ជាស្នែម និងភាសាបរទេស ការបង្កើតមូលនិធិសមធម៌សង្គម ការអនុវត្តគំរូសាលាក្នុងសាលា ការកាត់បន្ថយផលធៀបគ្រូ-សិស្ស ការផ្លាស់ប្តូរផ្នត់គំនិតបុគ្គល និងការធ្វើទំនើបកម្មបរិស្ថានសិក្សា។

## ២.៣ តួនាទី និងភារកិច្ចរបស់នាយកសាលារៀនជំនាន់ថ្មី

នាយកជាកត្តាសំខាន់មួយចូលរួមចំណែកក្នុងលទ្ធផលសិក្សារបស់សិស្ស និងសាលា។ គណៈគ្រប់គ្រងនៅសាលារៀនជំនាន់ថ្មី ត្រូវបានជ្រើសរើសតាមការប្រកួតប្រជែងការលើកទឹកចិត្តផ្សារភ្ជាប់នឹងការបំពេញភារកិច្ចបានល្អដោយអនុវត្តតាមគ្រប់គ្រងសាលា (School-Based Management) (ក្រសួងអ.យ.ក, ២០១៦)។ នាយកសាលារៀនជំនាន់ថ្មីជាអ្នកដឹកនាំដែលមានបុគ្គលិកលក្ខណៈខ្ពស់ និងមានជំនឿជាក់លើទស្សនៈវិស័យរបស់សាលារៀនជំនាន់ថ្មីហើយមានតួនាទី និងភារកិច្ចជាច្រើនដូចជា៖ ១) **ការអនុវត្តគោលនយោបាយ សេចក្តីណែនាំ បទដ្ឋានគតិយុត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា**៖យកចិត្តទុកដាក់បំពេញ

ការងារបំពេញជាមួយក្រុមប្រឹក្សាភិបាល សម្របសម្រួលទំនាក់ទំនងផ្សេងៗជាមួយក្រុមប្រឹក្សាភិបាល និងបុគ្គលិក ២) **ការធ្វើរបាយការណ៍ពីព័ត៌មាន និងទិន្នន័យៈ** នាយកសាលាត្រូវពិនិត្យលើស្ថិតិ និងរបាយការណ៍នៃទិន្នន័យក្នុងសាលារៀន មុនពេលដាក់ជូនថ្នាក់ដឹកនាំ ៣) **ការរៀបចំៈ** រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង លើកកម្ពស់តម្លាភាពផ្ទៃក្នុង និងទំនាក់ទំនងល្អក្នុងស្ថាប័នដើម្បីឱ្យដំណើរការប្រចាំថ្ងៃប្រព្រឹត្តទៅបានល្អ ៤) **ធ្វើផែនការ និងវិភាគផែនការៈ** ចូលរួមជាមួយបុគ្គលិក និងក្រុមប្រឹក្សាភិបាលវិភាគស្ថានការ និងរៀបចំផែនការអភិវឌ្ឍសាលារៀនស្របទៅតាមនិន្នាការអប់រំព្រមទាំងចូលរួមសិក្ខាសិលាអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ៥) **កម្មវិធីសិក្សាៈ** រៀបចំអនុវត្ត និងគ្រប់គ្រងកម្មវិធីសិក្សា បញ្ចូលវិធីសាស្ត្របង្រៀន សេវាកម្ម និងសកម្មភាពផ្សេងៗទៀតដើម្បីឱ្យមានភាពទាក់ទាញដល់សិស្ស បំពេញតម្រូវការសិស្ស ៦) **បុគ្គលិកលក្ខណៈ** : ជ្រើសរើសបុគ្គលិក និងគ្រូបង្រៀនមានសមត្ថភាព បង្កើតយន្តការបំពេញការងារ និងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពដើម្បីលើកកម្ពស់ប្រសិទ្ធភាពបំពេញការងារ ៧) **ការគាំទ្រកម្មវិធី និងសេវាៈ** រៀបចំសកម្មភាពផ្សេងៗដូចជាសន្តិសុខសុវត្ថិភាព ទំនាក់ទំនង សកម្មភាពយុវជន ការប្រឹក្សាអាជីពដើម្បីគាំទ្រដល់ការផ្តល់សេវាអប់រំកាន់តែមានភាពទាក់ទាញ និងមានគុណភាព ៨) **ហិរញ្ញវត្ថុៈ** គ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយតម្លាភាព មានការទទួលខុសត្រូវ និងស្របតាមបទដ្ឋានគតិយុត្ត ៩) **ការចុះឈ្មោះចូលរៀនៈ** រៀបចំដំណើរការចុះឈ្មោះចូលរៀនប្រកបដោយតម្លាភាព ព្រមទាំងប្រមូលព័ត៌មានឆ្លើយតបដើម្បីពង្រឹងប្រសិទ្ធភាពការចុះឈ្មោះចូលរៀន ១០) **ទំនាក់ទំនងសហគមន៍ៈ** បង្កើតទំនាក់ទំនងល្អជាមួយដៃគូរអភិវឌ្ឍ សាលារៀនដទៃ ស្ថាប័នឯកជន ស្ថាប័នរដ្ឋ អតីតសិស្ស អាណាព្យាបាលក្នុងគោលបំណងជាប្រយោជន៍ និងគាំទ្រដល់ការអភិវឌ្ឍសាលារៀន និង១១) **គុណវឌ្ឍិៈ** នាយកសាលារៀនត្រូវមានសញ្ញាបត្រ និងបទពិសោធន៍ក្នុងវិស័យអប់រំព្រមទាំងមានបំណិនបន្ថែមដូចជាការវិភាគ ទំនាក់ទំនង ការធ្វើការសម្រេចចិត្ត ភាពជាអ្នកដឹកនាំគ្រប់គ្រងព្រមព្រៀងទៅលើគោលបំណងរបស់សាលានេះ។

## ២.៤ ភាពជាអ្នកដឹកនាំរបស់នាយកក្នុងការរៀន និងបង្រៀន

យោងតាមឯកសារទស្សនាទានស្តីពីការគ្រប់គ្រងតាមសាលារៀនដោយឈរលើលទ្ធផល ការបំពេញការងាររបស់នាយកផ្តោតសំខាន់លើសមាសភាគចំនួន៤គឺៈ ១) ការគ្រប់គ្រងរដ្ឋបាល ២) ការគ្រប់គ្រងការរៀន និងបង្រៀន ៣) ការគ្រប់គ្រងធនធានមនុស្ស ៤) ការគ្រប់គ្រងហិរញ្ញវត្ថុ។ យុទ្ធសាស្ត្រនៃការអភិវឌ្ឍភាពជាអ្នកដឹកនាំសាលារៀនពិតជាមានសារៈសំខាន់ណាស់ព្រោះជាកត្តាកំណត់សម្រាប់ការអប់រំ និងការបណ្តុះគ្រាប់ពូជថ្មីសម្រាប់អ្នកសិក្សាក្នុងសតវត្សរ៍ទី២១នេះ។ អ្នកដឹកនាំសាលារៀនសតវត្សរ៍ទី២១ត្រូវប្រឈមជាមួយនឹងកិច្ចការយ៉ាងលំបាកជាច្រើនក្នុងការហ្វឹកហាត់ផ្លូវចិត្តរបស់យុវជនសម្រាប់ថ្ងៃអនាគត និងត្រូវមានការគិតបែបយុទ្ធសាស្ត្រក្នុងការបង្កើតគោលដៅ និងប្រព័ន្ធផ្សេងៗដែលមានតួនាទីគាំទ្រទៅលើការងារទាំងអស់នេះ។ សមត្ថភាពបុគ្គលរួមមានភាពចង់ចេះចង់ដឹងភាពតស៊ូ ភាពបត់បែន ភាពមានទំនួលខុសត្រូវ និងការខិតខំប្រឹងប្រែងពិតជាមានសារៈសំខាន់សម្រាប់អ្នកដឹកនាំ។ ការផ្លាស់ប្តូរគំរូនៃភាពជាអ្នកដឹកនាំសាលារៀនសមត្ថភាពគឺតែងតែជាកូនសោរគន្លឹះឈានទៅរកភាពជោគជ័យ។ គ្មាននរណាម្នាក់កើតមកជាមួយនឹងសមត្ថភាពនៃការដឹកនាំសាលារៀនតាំងពីកំណើតនោះទេ ហេតុនេះហើយទាមទារឱ្យមានឆន្ទៈខ្ពស់ក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន និងធ្វើឱ្យខ្លួនឯងមានការវិវត្តទៅមុខជានិច្ច។

### ២.៤.១ និយមន័យភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀន

ភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនត្រូវបានរំលេចឡើងតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០មកពោលគឺចាប់ពីមានការចាប់អារម្មណ៍លើការស្រាវជ្រាវអំពីសាលារៀនដែលប្រកបដោយប្រសិទ្ធិភាព។ លោក Fowler and Walter ( 2020 ) បានផ្តល់និយមន័យទៅលើភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនថាជាការគ្រប់គ្រងអប់រំដែលផ្តោតលើតួនាទីរបស់នាយក ឬគណៈគ្រប់គ្រងសាលាក្នុងការជួយបង្កើតវប្បធម៌នៃការបង្រៀន និងការវាយតម្លៃក្នុងសាលារៀនមួយ ដែលចាត់ទុកការរៀនរបស់សិស្សជាស្នូលនៃដំណើរការបង្រៀន និងការជំរុញឱ្យមានការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ ភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនគឺជាការដឹកនាំដ៏ធំ និងរឹងមាំមួយ ដែលផ្តោតលើសកម្មភាពរបស់នាយកសាលាក្នុងការដឹកនាំវប្បធម៌នៃការបង្រៀន

និងរៀន តាមរយៈការអនុវត្ត និងអន្តរកម្មជាមួយគ្រូ និងសិស្សសំដៅសម្រេចកម្មវិធីសិក្សាមួយដែលមានប្រសិទ្ធិភាព (Hallinger, 2009)។ យោងតាម Hoy and Miskel (2002) បានលើកឡើងថាភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀន ផ្តោតទៅលើការកែលម្អការរៀន និងបង្រៀនក្នុងសាលារៀន។ អ្នកដឹកនាំខិតខំកែលម្អសាលារៀន លើខ្លឹមសារកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន យុទ្ធសាស្ត្រ វាយតម្លៃ និងវប្បធម៌ក្នុងសាលារៀន ក្នុងគោលដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស។ នាយកសាលា គណៈគ្រប់គ្រង គ្រូបង្រៀន មាតាបិតា និងសិស្សខ្លួនឯងអាចចាត់ទុកថាជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀន។ យោងតាម (Hallinger, 2005) ភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនផ្តោតលើសមាសភាគចំនួនបីគឺ៖១) កំណត់បេសកម្មសាលារៀន៖ ដោយចេញគោលដៅច្បាស់លាស់ អាចវាស់បាន និងកំណត់ពេលដើម្បីសម្រេចបាននូវការកែប្រែលទ្ធផលសិក្សារបស់សិស្ស ២) ការគ្រប់គ្រងកម្មវិធីសិក្សា៖សម្របសម្រួលការអនុវត្តកម្មវិធីសិក្សា ការរៀន និងបង្រៀនតាមដានត្រួតពិនិត្យ និងវាយតម្លៃ និង៣) លើកម្ពស់បរិយាកាសសិក្សាជាវិជ្ជមានដើម្បីឱ្យគណៈគ្រប់គ្រង គ្រូបង្រៀន និងសិស្សដាក់ចេញស្តង់ដា និងការរំពឹងទុកខ្ពស់។

ភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងតួនាទី និងភារកិច្ចរបស់នាយកសាលាដូចជាការតាក់តែង ការផ្សព្វផ្សាយគោលដៅរបស់សាលាការបង្កើតស្តង់ដាសម្រាប់សាលារៀន ការរៀបចំកម្មវិធីសិក្សា ការត្រួតពិនិត្យ និងការវាយតម្លៃការបង្រៀនរបស់គ្រូ ឬសាស្ត្រាចារ្យ ការលើកទឹកចិត្តសិស្សឱ្យខិតខំរៀនសូត្រ និងបង្កើនការអភិវឌ្ឍអាជីពរបស់គ្រូ និងបុគ្គលិករដ្ឋបាលរបស់សាលា (Boe, 2008, as cited in Ismail, Don, Husin & Khalid, 2018)។

### ២.៤.២ សមាសភាគនៃភាពជាអ្នកដឹកនាំរបស់នាយកក្នុងការរៀន និងបង្រៀន

- **នាទីនៃភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនក្នុងសាលារៀន**

យោងតាមលោក Mc Ewan (2002) បានអះអាងថានាយកសាលាត្រូវធ្វើរឿង៧យ៉ាងនៅក្នុងសាលារៀនដើម្បីឱ្យសាលាប្រព្រឹត្តទៅប្រកបដោយជោគជ័យ និងគុណភាពរួមមាន៖ ១) កំណត់គោលដៅសាលាឱ្យបានច្បាស់លាស់ ២) ត្រូវមានវត្តមាននៅសាលារៀនជាប្រចាំ ៣) បង្កើតបរិយាកាសការងារល្អនៅក្នុងសាលា ៤)

រៀបចំទស្សនៈវិស័យ និងបេសកកម្មសម្រាប់សាលារៀន ៥) ត្រូវមានក្តីរំពឹងទុកខ្ពស់ចំពោះសាលារៀន ៦) បណ្តុះបណ្តាលគ្រូសម្រាប់ត្រៀមស្នងតំណែងជានាយកនាថ្ងៃអនាគត និង៧) រក្សាអកប្បកិរិយាវិជ្ជមាន។

- **តួនាទីនៃភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនជាមួយគ្រូ**

គ្រូបង្រៀនដើរតួនាទីសំខាន់ណាស់ក្នុងការជំរុញឱ្យសាលាទទួលបានភាពជោគជ័យហើយនាយកឬគណៈគ្រប់គ្រងសាលាត្រូវតែប្រព្រឹត្តទៅលើគ្រូបង្រៀនឱ្យបានត្រឹមត្រូវ និងត្រូវយកចិត្តទុកដាក់ខ្ពស់។ មតិរបស់ Zapeda (2003) បានលើកឡើងថានាយកសាលាត្រូវមានទំនាក់ទំនងល្អជាមួយគ្រូបង្រៀន ជំរុញ និងលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈព្រមទាំងធ្វើការវាយតម្លៃគ្រូបង្រៀនជាប្រចាំនោះទើបសាលាមានការអភិវឌ្ឍ និងធានាបាននូវប្រសិទ្ធិភាពក្នុងការបង្ហាត់បង្រៀន។

- **តួនាទីនៃភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនជាមួយសិស្ស**

ក្រៅពីកត្តាគ្រូបង្រៀន នាយកសាលាត្រូវយកចិត្តទុកដាក់ទៅលើសិស្ស និងការសិក្សារបស់សិស្សផងដែរ។ លោក Graham (1991) បានរកឃើញថាភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនរបស់នាយកមានឥទ្ធិពលលើភាពជោគជ័យនៃការសិក្សារបស់សិស្ស២០% ហើយទំនួលខុសត្រូវរបស់សាលាគឺត្រូវគិតថាតើសិស្សអាចរៀនអ្វីបានខ្លះនៅក្នុងសាលា ដោយមិនត្រូវគិតតែពីអ្វីដែលកំពុងបង្រៀនដល់សិស្សនោះទេ។

- **តួនាទីនៃភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនជាមួយសហគមន៍**

យោងតាម Matthews and Crow (2010) បានលើកឡើងថាសាលារៀនត្រូវចូលរួមជាមួយសហគមន៍ដើម្បីធានាបាននូវការសម្រេចគោលដៅ និងបេសកកម្មរបស់សាលា។ តាមការអះអាងរបស់ Carpenter (2015) គោលបំណងនៃការជំរុញឱ្យមានសហគមន៍នៅក្នុងសាលា រៀនគឺដើម្បីឱ្យសិស្សទទួលបានលទ្ធផលសិក្សាល្អប្រសើរដែលអាចធ្វើឡើងក្នុងបរិយាកាសមួយប្រកបដោយភាពបត់បែន និងប្រកបដោយគុណភាព។

**២.៤.៣ ភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនសម្រាប់ការសិក្សានាសតវត្សរ៍ទី២១**

នៅក្នុងសតវត្សរ៍ទី២១ភាពជានាយកបានដើរតួនាទីសំខាន់ណាស់ក្នុងការដឹកនាំគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធិភាពស្របទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យា និងសាកលភាវូបនីយកម្ម។ ប្រការនេះតម្រូវ

ឱ្យនាយកសាលាទទួលខុសត្រូវខ្ពស់ចំពោះសមិទ្ធិផលរបស់សិស្សដោយត្រូវផ្តល់ឱ្យសិស្សនូវជំនាញសម្រាប់សតវត្សរ៍ទី២១គឺការរៀនសហការណ៍គ្នា ទំនាក់ទំនង ការច្នៃប្រឌិត និងការគិតល្អិតល្អន់។ យោងតាម Whitehead et al. (2013) ភាពជានាយកផ្តោតលើតួនាទីរបស់នាយកក្នុងការគ្រប់គ្រងសាលារៀនទំនើប ដើម្បីធានាបាននូវប្រសិទ្ធភាពរបស់សាលា។ តួនាទីនាយកសាលានៅក្នុងទ្រឹស្តីនៃភាពជានាយកនេះគឺមានតួនាទីជាអ្នកប្រតិបត្តិ ជាអ្នកគ្រប់គ្រង ជាអ្នករៀបចំ ជាចៅហ្វាយ និងជាអ្នកជំនាញ។ យោងតាម Akinbode and Shuhumi (2018) ដើម្បីដោះស្រាយបញ្ហាប្រឈមនានាក្នុងសម័យទំនើប ទ្រឹស្តីភាពជានាយកតម្រូវឱ្យនាយកចេះប្រើប្រាស់បច្ចេកវិទ្យាទំនើប ដើម្បីសម្រេចចក្ខុវិស័យបេសកកម្ម និងការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងដំណើរការគ្រប់គ្រងរដ្ឋបាលសាលារៀន ដូចជាក្នុងទំនាក់ទំនងជាមួយ អាណាព្យាបាលសិស្ស និងសិស្សានុសិស្សតាមរយៈសារអេឡិចត្រូនិក និងបណ្តាញសង្គម។

នៅក្នុងបរិបទអប់រំនាសតវត្សរ៍ទី២១ ដែលជាយុគសម័យសាកលភាវូបនីយកម្ម នវានុវត្តន៍បច្ចេកវិទ្យាក៏ដូចជាឌីជីថល គេនៅមើលពីសារៈសំខាន់នៃភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនដែលអាចធ្វើឱ្យវិស័យអប់រំទទួលបានជោគជ័យ និងឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ យោងតាម Robinson et al. (2008) បានកំណត់នូវទិដ្ឋភាពចំនួន ៥នៃភាពជាអ្នកដឹកនាំក្នុងការរៀន និងបង្រៀនដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងប្រសិទ្ធិភាពនៃសាលារៀនសម័យទំនើបរួមមាន ១) ការកំណត់គោលដៅ ២) ការធានាបាននូវការបង្រៀនប្រកបដោយគុណភាព ៣) ការដឹកនាំការអភិវឌ្ឍសមត្ថភាពរបស់គ្រូ ៤) ការផ្គត់ផ្គង់សម្ភារជាយុទ្ធសាស្ត្រ និង៥) ការធានានូវបរិយាកាសប្រកបដោយសណ្តាប់ធ្នាប់ និងសុវត្ថិភាព។

តាមការគូសបញ្ជាក់របស់ Hallinger (2003) និង Hallinger (2005) ទោះបីជាបច្ចុប្បន្នមានទ្រឹស្តីនៃភាពជាអ្នកដឹកនាំអប់រំជាច្រើនដូចជា ភាពជាអ្នកដឹកនាំរួម ភាពជាអ្នកដឹកនាំតាមបែបនាយកនិយម ក៏ភាពជាអ្នកដឹកនាំក្នុងការរៀន និង បង្រៀននៅតែពេញនិយម និងត្រូវបានចាត់ទុកថាមានភាពជាអ្នកដឹកនាំខាងអប់រំដ៏មានប្រជាប្រិយបំផុតនាសតវត្សរ៍ទី២១នេះ។

យោងតាម Sheninger (2014) បានបង្ហាញពីតួនាទី និងគុណសម្បត្តិនាយកក្នុងយុគសម័យឌីជីថលត្រូវមាន៖ ១) បំណិនទំនាក់ទំនង ២) ទំនាក់ទំនងសាធារណៈ និងជាមួយសហគមន៍ ៣) បំណិនបង្កើតម៉ាក ៤) បង្កលក្ខណៈឱ្យសិស្សរៀន ៥) បង្កលក្ខណៈឱ្យគ្រូអភិវឌ្ឍជំនាញវិជ្ជាជីវៈ ៦) ចេះច្នៃប្រឌិតបរិស្ថានសិក្សាដែលទាក់ទាញដល់ការរៀន និងបង្រៀនដោយប្រើវិធីនវានុវត្តន៍ និង៧) ចេះចាប់យក និងផ្តល់ឱកាស។

## ២.៥ ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម

កម្មវិធីសាលារៀនជំនាន់ថ្មីជាគម្រូល្អមួយក្នុងការអនុវត្តការងារអប់រំឆ្ពោះទៅរកការលើកកម្ពស់គុណភាពការងារគ្រប់គ្រងអប់រំតាមការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធ ដែលមានសមាសភាពទាំងបួនគឺ៖១) ការគ្រប់គ្រងការរៀន និងបង្រៀន ២) ការគ្រប់គ្រងរដ្ឋបាល ៣) ការគ្រប់គ្រងហិរញ្ញវត្ថុ និង៤) ការគ្រប់គ្រងធនធានមនុស្ស ដើម្បីសម្រេចគោលដៅច្បាស់លាស់ក្នុងការរៀបចំការរៀនរបស់សិស្សឱ្យស្របជាមួយតម្រូវការកម្លាំងពលកម្មសម្រាប់សតវត្សរ៍ទី២១ដែលផ្តល់នូវពន្លកបច្ចេកវិទ្យាសកលដោយអភិវឌ្ឍសមត្ថភាពស្ទែម ចំណេះដឹងបច្ចេកវិទ្យា ការគិតស៊ីជម្រៅដល់សិស្ស (Melissa Donaher & Nuoya Wu, 2020)។ ការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធល គឺជាការផ្ទេរអំណាចដល់កម្រិតសាលានៅក្នុងការធ្វើស្វ័យសម្រេចចិត្តទៅដល់អ្នកពាក់ព័ន្ធក្នុងសាលានូវអំណាច សិទ្ធិដើម្បីគ្រប់គ្រង និងស្វ័យភាពក្នុងការប្រតិបត្តិនៅក្នុងសាលាដល់អ្នកគ្រប់គ្រង អ្នកឯកទេសអប់រំ នាយក គ្រូបង្រៀន អាណាព្យាបាល សិស្សមានកម្រិតខ្ពស់ (Agustinus Bandur, 2008)។ ការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធល មានប្រសិទ្ធិភាពខ្ពស់ក្នុងការពង្រឹងលទ្ធផលសិក្សារបស់សិស្ស ហើយការគ្រប់គ្រងនេះទាមទារឱ្យនាយកមានជំនាញទាំងផ្នែកការគ្រប់គ្រង និងការបង្រៀនក៏ដូចជាមានស្វ័យភាពពិតប្រាកដដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរលើការអនុវត្តនៅក្នុងសាលា (Demas & Arcia, 2015)។ ការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធល និងការអនុវត្តគោលនយោបាយអប់រំស្ទែមនៅនៅសាលារៀនជំនាន់ថ្មី នេះបានធ្វើឱ្យមានការផ្លាស់ប្តូរដល់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីដូចជាការបង្កើតនូវប្រព័ន្ធ និងវប្បធម៌ស្តង់ដាវិជ្ជាជីវៈនិយម និងផ្តល់នូវការអភិវឌ្ឍអាជីពមានគុណភាពខ្ពស់ដែលអាចឱ្យ

គ្រូអនុវត្តការបង្រៀន និងរៀនប្រកបដោយនវានុវត្ត និងអភិវឌ្ឍបំណិនសតវត្សរ៍ទី២១ដល់សិស្ស (Mellisa Donah & Nuoya Wu, 2020)។

ការបង្កើតនូវប្រព័ន្ធ និងវប្បធម៌ស្តង់ដារវិជ្ជាជីវៈនិយមមានគោលការណ៍ស្នូល៤គឺៈ ទី១) ស្តង់ដារវិជ្ជាជីវៈខ្ពស់ៈសម្រាប់នាយក និងគ្រូដែលមានភាពស្មោះត្រង់មិនប្រព្រឹត្តអំពើពុករលួយនៅក្នុងសាលា ទី២) ការអនុវត្តស្វ័យភាពៈ នាយក និងគ្រូមានស្វ័យភាពស្ទើរទាំងស្រុងលើកិច្ចការដែលពាក់ព័ន្ធទៅនឹងសាលាដូចជាការជ្រើសរើសគ្រូ ការកែប្រែកម្មវិធីសិក្សា ផលធៀបសិស្ស គ្រូ វិធីសាស្ត្របង្រៀន និងការប្បច្ចេកវិទ្យាក្នុងការអប់រំដែលគាត់យល់ថាអាចជម្រុញគំនិតនវានុវត្ត និងគុណភាពអប់រំ ទី៣) សនិទានកម្មធនធានដោយឡែកៈ សាលាបានទទួលធនធានដោយឡែកលើសពីសាលាប្រពៃណី និងមានឆន្ទានុសិទ្ធិក្នុងការបង្កើតមូលនិធិស្របច្បាប់ដើម្បីសម្រេចគោលដៅនៃការសិក្សានិង ទី៤) គណនេយ្យភាព និងការទទួលស្គាល់ៈ សាលា ត្រូវមានស្វ័យភាពកម្រិតសាលានិងស្តង់ដារវិជ្ជាជីវៈខ្ពស់ដោយទាមទារឱ្យមានគណនេយ្យភាពខ្លាំងសម្រាប់ការទទួលស្គាល់ជាសាលរៀនជំនាន់ថ្មី ដោយមានការចូលរួមត្រួតពិនិត្យពីក្រសួងអប់រំ យុវជន និងកីឡា និងស្ថាប័នមិនមែនរដ្ឋាភិបាលដើម្បីបង្កើតគុណភាពរៀនកម្រិតខ្ពស់។

ការអភិវឌ្ឍអាជីពមានគុណភាពខ្ពស់សាលារៀនជំនាន់ថ្មី បានប្រើប្រាស់នូវគំរូជាច្រើនដើម្បីគាំទ្រ និងបណ្តុះបណ្តាលគ្រូឱ្យមានសមត្ថភាពឆ្លើយតបទៅនឹងតម្រូវការក្នុងការបង្រៀន និងរៀនជំនាញសតវត្សរ៍ទី២១ ដូចជាៈ ទី១) ការបណ្តុះបណ្តាលសម្រាប់គ្រូនៅសាលារៀនជំនាន់ថ្មី ដើម្បីឱ្យគ្រូអាចប្រើវិធីសាស្ត្រថ្មីៗ ជំរុញគ្រូអនុវត្តតាមគន្លងអាជីពវិជ្ជាជីវៈគ្រូបង្រៀន ផ្តល់ឱកាសដល់គ្រូបង្រៀនធ្វើកិច្ចការស្រាវជ្រាវ និងបង្កើតគំនិតនវានុវត្តន៍ បង្កើតសហគមន៍វិជ្ជាជីវៈតាមមុខវិជ្ជាឯកទេសរៀងខ្លួន ប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមក្នុងការរៀន និងបង្រៀន ជំរុញការច្នៃប្រឌិតថ្មីៗ និងនវានុវត្តន៍តាមរយៈការប្រើបច្ចេកវិទ្យាក្នុងថ្នាក់រៀន ព្រមទាំងបានរៀបចំសមត្ថភាពគ្រូបង្រៀនឆ្លើយតបទៅនឹងតម្រូវការអប់រំសតវត្សទី២១ ទី២) បានពង្រឹងគុណភាពបង្រៀនតាមរយៈ ការធ្វើផែនការអាជីពដោយបាន អនុវត្តការបង្រៀនឆ្លុះបញ្ចាំងជាបុគ្គល និងសហការណ៍គ្នា

ជាមួយសហការី និងអ្នកប្រឹក្សាទៅលើការបង្រៀន និងរៀន ប្រើប្រាស់សម្ភារៈឧបទេសឆ្លើយតបមុខវិជ្ជាស្ទែម ផ្តល់ឱកាសឱ្យគ្រូប្រើបច្ចេកវិទ្យាក្នុងដំណើរការបង្រៀន វាយតម្លៃសិស្ស និងរក្សាទុកឯកសារ ផ្តល់ស្វ័យភាពដល់គ្រូក្នុងការបង្រៀនទៅតាមស្ថានភាពរបស់សិស្ស (Mellisa Donaher & Nuoya Wu, 2020) ទី៣) ការប្រឹក្សា សាលារៀនជំនាន់ថ្មីមានគ្រូប្រឹក្សាគរុកោសល្យដែលអាចជួយគ្រូលើវិធីសាស្ត្របង្រៀន និងការផ្តល់យោបល់កែលម្អ ដែលអាចអភិវឌ្ឍគន្លងអាជីពបាន ទី៤) ការបណ្តុះបណ្តាលក្នុងសេវាគឺគ្រូទាំងអស់ចូលរួមក្នុងការបណ្តុះបណ្តាល និងរៀនវិធីសាស្ត្រដែលមានប្រសិទ្ធិភាពដើម្បីអភិវឌ្ឍជំនាញការគិត បែបល្អិតល្អន់ និងការច្នៃប្រឌិត ទី៥) បង្កើតបរិស្ថានសិក្សាប្រកបដោយប្រសិទ្ធភាពដូចជាលើកកម្ពស់ទំនាក់ទំនងរបស់សិស្សលើដំណើរការបង្រៀន និងរៀន សិស្សទទួលបានចំណេះដឹងបច្ចេកវិទ្យាតាមរយៈការបង្រៀនរបស់គ្រូ បន្ទប់វៃឆ្លាតបណ្ណាល័យទំនើប ទី៦) ទស្សនៈកិច្ចសិក្សានៅក្រៅប្រទេស គ្រូបង្រៀន និងនាយកសាលារៀនជំនាន់ថ្មីមានឱកាសទៅទស្សនៈកិច្ច និងរៀនពីសាលាក្នុងសតវត្សរ៍ទី២១នៅប្រទេសផ្សេងៗ ទី៧) ការគាំទ្ររបស់នាយក សាលារៀនជំនាន់ថ្មីបានផ្តល់ការគាំទ្រដល់គ្រូក្នុងការបំពេញការងាររបស់ពួកគាត់ដោយសហការណ៍ជាមួយគ្រូក្នុងការកំណត់គោលដៅនៃការអភិវឌ្ឍវិជ្ជាជីវៈដូចជាការប្រើICTវិធីសាស្ត្របែបស្ថាបនានិយមនៅក្នុងថ្នាក់ ការសង្កេតថ្នាក់រៀន ផ្តល់ការកែលម្អដោយលិខិត និងដោយផ្ទាល់មាត់ ត្រួតពិនិត្យអត្ថបទឆ្លុះបញ្ចាំងរបស់គ្រូ និងគាំទ្រដល់សហគមន៍វិជ្ជាជីវៈដើម្បីសម្រេចការបង្រៀន និងរៀនបែបនវានុវត្ត និងគាំទ្រសិស្សឱ្យអភិវឌ្ឍជំនាញសតវត្សរ៍ទី២១។ ការបង្រៀន និងរៀនបែបនវានុវត្តគឺមានស្វ័យភាពលើការអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ការរៀបចំបរិស្ថានសិក្សា និងការបង្រៀនដោយអនុវត្តកម្មវិធីសិក្សាបន្ថែមក្រៅពីកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ដូចសាលាប្រពៃណីដែលស្របទៅនឹងស្តង់ដារៀនសតវត្សរ៍ទី២១ ព្រមទាំងប្រើប្រាស់បច្ចេកវិទ្យា និងឧបករណ៍ទំនើបដើម្បីបង្កើតបរិស្ថានសិក្សាបែបទំនើបប្រកបដោយប្រសិទ្ធិភាព។ ចំណែកឯការគាំទ្រសិស្សលើការអភិវឌ្ឍជំនាញសតវត្សរ៍ទី២១ ដើម្បីចូលរួមទីផ្សារពលកម្មដោយបង្កើតការយល់ដឹងលើICTទាំងសិស្ស និងគ្រូដើម្បីពង្រឹងសមត្ថភាពចំណេះដឹងពីស្ទែម ICT និងការគិតល្អិតល្អន់ដោយតម្រូវឱ្យ

សាលារៀនជំនាន់ថ្មី មានបណ្ណាល័យសតវត្សរ៍ទី២១សេវាកម្មបន្ទប់ICT និងវិទ្យាសាស្ត្រជាដើម (Melissa Donaher & Nuoya Wu, 2020 )។

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវលើកប្រធានបទស្តីពី «**ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពីការ អប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ**» ប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យដើម្បីសិក្សាស្វែងយល់ពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម និងការផ្តល់កិច្ចគាំទ្រដល់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ។

## ៣.១ គម្រោងស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យ និងគុណវិស័យ៖

**១.វិធីសាស្ត្របរិមាណវិស័យ (Quantitative Research Design)៖** ជ្រើសរើសវិធីសាស្ត្របរិមាណវិស័យទំនាក់ទំនងអថេរ ដោយប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យពីនាយកសាលា និងគ្រូបង្រៀនកម្រិតមធ្យមសិក្សានៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ។ ការរៀបចំកម្រងសំណួរគឺចែកជាបួនផ្នែក៖ ១) ព័ត៌មានទូទៅ ២) សូចនាករសម្រាប់វាស់ពីភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី ៣) សូចនាករសម្រាប់វាស់វែងពីការអនុវត្តគោលនយោបាយអប់រំស្ទែម និង ៤) ផលជះនៃទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម ទៅដល់ការបង្រៀនរបស់គ្រូ។

**២.វិធីសាស្ត្រគុណវិស័យ (Qualitative Research Design)៖** ប្រើប្រាស់សំណួរសម្រាប់សម្ភាសពីអ្នកចូលរួមផ្តល់ទិន្នន័យគុណវិស័យរួមមាន៖ ១) គ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនជំនាន់ថ្មី ២) មន្ត្រីមន្ទីរអប់រំរាជធានីភ្នំពេញ ៣) មន្ត្រីមជ្ឈមណ្ឌលគរុកោសល្យជំនាន់ថ្មី ៤) មន្ត្រីនាយកដ្ឋានគោលនយោបាយនៃក្រសួងអប់រំ និង៥) មន្ត្រីនាយកដ្ឋានផែនការនៃក្រសួងអប់រំ ។ ការរៀបចំសំណួរសម្ភាសន៍គឺភ្ជាប់សូចនាករដែលបានប្រើក្នុងការប្រមូលទិន្នន័យតាមបរិមាណវិស័យដើម្បីយកទិន្នន័យមកផ្ទៀងផ្ទាត់តម្លៃមធ្យមភាគពិន្ទុដែលទទួលបាន និងទស្សនៈយល់ឃើញរបស់អ្នកចូលរួមសម្ភាសន៍មកពិភាក្សាបញ្ចូលគ្នា។

**តារាង៣.១៖ គម្រោងស្រាវជ្រាវរៀបរាប់ពីវិធីសាស្ត្រតាមបរិមាណវិស័យ និងគុណវិស័យ**

| គោលបំណង | ឧបករណ៍ស្រាវជ្រាវ | ភាគសំណាក | ការវិភាគទិន្នន័យ |
|---|---|---|---|
| ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម | បរិមាណវិស័យៈប្រើប្រាស់កម្រងសំណួរ (Questionnaires) | -គណៈគ្រប់គ្រងសាលារៀន(n=3)<br>-គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មី (n=120) | -កម្រិតចង្អុបង្ហាញពីទាបបំផុត (១) ដល់ខ្ពស់បំផុត (៥)<br>- ភាគរយ(%) មធ្យមពិន្ទុ (Mean) គម្លាតស្តង់ដា (Standard Deviation) |
| | គុណវិស័យប្រើប្រាស់សំណួរក្នុងការសម្ភាសន៍ (Interview Questions) | - គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន<br>- ថ្នាក់ដឹកនាំនៅមន្ទីអប់រំរាជធានីភ្នំពេញ<br>- គណៈគ្រប់គ្រង និងគ្រូបង្រៀននៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី<br>- ថ្នាក់ដឹកនាំនៅនាយកដ្ឋានគោលនយោបាយអប់រំ និងនាយកដ្ឋានផែនការ (n=9) | - ការបកស្រាយខ្លឹមសារ (Transcript)<br>- ការទាញយកពាក្យគន្លឹះ(Coding)<br>- ខ្លឹមសារគោល (Themes) |
| ទំនាក់ទំនងនៃភាពជាអ្នកដឹកនាំរបស់នាយក និងការអនុ | បរិមាណវិស័យៈប្រើប្រាស់កម្រងសំណួរ (Questionnaires) | -គណៈគ្រប់គ្រងសាលារៀន(n=3) | -កម្រិតចង្អុលបង្ហាញពីទាបបំផុត (១) ដល់ខ្ពស់បំផុត (៥) |

| គោលបំណង | ឧបករណ៍ស្រាវជ្រាវ | ភាគសំណាក | ការវិភាគទិន្នន័យ |
|---|---|---|---|
| វត្តគោលនយោបាយអប់រំស្ទែម ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូនៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ។ | | -គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មី (n=120) | - ភាគរយ (%) មធ្យមភាគពិន្ទុ (Mean) គម្លាតស្តង់ដា (Standard Deviation) |
| | គុណវិស័យប្រើប្រាស់សំណួរក្នុងការសម្ភាសន៍ (Interview Questions) | - គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន<br>- ថ្នាក់ដឹកនាំនៅមន្ទីរអប់រំរាជធានីភ្នំពេញ<br>- គណៈគ្រប់គ្រងនិងគ្រូបង្រៀននៅមជ្ឈមណ្ឌលស្រាវជ្រាវតេរុកោសល្យជំនាន់ថ្មី<br>- ថ្នាក់ដឹកនាំនៅនាយកដ្ឋានគោលនយោបាយអប់រំ និងនាយកដ្ឋានផែនការ (n=9) | - ការបកស្រាយខ្លឹមសារ (Transcript)<br>- ការទាញយកពាក្យគន្លឹះ(Coding)<br>- ខ្លឹមសារគោល (Themes) |

## ៣.១.១ ការសិក្សាស្រាវជ្រាវបរិមាណវិស័យ

### ៣.១.១.១ ការគណនាភាគសំណាក

ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ គឺប្រមូលទិន្នន័យពីសាលារៀនជំនាន់ថ្មីក្នុ ងរាជធានីភ្នំពេញ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យព្រែកលៀប ដែលមានភាគសំណាកសរុបពីគ្រូបង្រៀនចំនួន១៣៧ នាក់ និងគណៈគ្រប់គ្រងសរុបចំនួន៦នាក់។

តារាង៣.២៖ ភាគសំណាកក្នុងការចុះប្រមូលទិន្នន័យបរិមាណវិស័យ

| ល.រ | ឈ្មោះវិទ្យាល័យ | គណៈគ្រប់គ្រង | | គ្រូបង្រៀន | |
|---|---|---|---|---|---|
| | | ចំនួនភាគសំណាកសរុប | ចំនួនភាគសំណាកទទួលបានសរុប | ចំនួនភាគសំណាកសរុប | ចំនួនភាគសំណាកទទួលបានសរុប |
| ១ | វិទ្យាល័យព្រះស៊ីសុវត្ថិ | ៣នាក់ | ១នាក់ | ៥៩នាក់ | ៥៤នាក់ |
| ២ | វិទ្យាល័យព្រែកលៀប | ៣នាក់ | ២នាក់ | ៧៨នាក់ | ៦៦នាក់ |
| សរុប | | ៦នាក់ | ០៣នាក់ | ១៣៧នាក់ | ១២០នាក់ |

តាមរយៈការចុះប្រមូលទិន្នន័យពីគ្រូបង្រៀនចំនួន ១៣៧ នាក់ ភាគសំណាកដែលទទួលបានចំនួន ១២០នាក់មូលហេតុដោយសារគ្រូបង្រៀនមួយចំនួនពុំបានឆ្លើយតបលើកម្រងសំណួរនេះទេ។

តាមរយៈការចុះប្រមូលទិន្នន័យពីគណៈគ្រប់គ្រងចំនួន ០៦នាក់ ភាគសំណាកដែលទទួលបានចំនួន ៣ នាក់មូលហេតុដោយសារគណៈគ្រប់គ្រងមួយចំនួនពុំបានឆ្លើយតបលើកម្រងសំណួរនេះទេ។

### ៣.១.១.២ ឧបករណ៍សម្រាប់ការស្រាវជ្រាវ

ទិន្នន័យជាបរិមាណវិស័យគឺប្រើប្រាស់កម្រងសំណួរសម្រាប់ការប្រមូលទិន្នន័យទៅតាមក្រុមគោលដៅនៅកម្រិតសាលារៀន តាមភាគសំណាកជាក់លាក់ដើម្បីបានទិន្នន័យមកធ្វើការវិភាគ។ កម្រងសំណួរសម្រាប់ប្រមូលទិន្នន័យស្តីពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្នៃម ត្រូវបានរៀបចំឡើងដោយផ្តោតលើសមាសភាពទាំង៤នៃការដឹកនាំគ្រប់គ្រងដោយផ្អែកលើលទ្ធផលរួមមាន ៖១) ការដឹកនាំគ្រប់គ្រងការបង្រៀន និងរៀន ២) ការដឹកនាំគ្រប់គ្រងរដ្ឋបាល ៣) ការដឹកនាំគ្រប់គ្រងហិរញ្ញវត្ថុ និង ៤) ការដឹកនាំគ្រប់គ្រងធនធានមនុស្សដែលមានសូចនាករចំនួន ៤៦ រួមទាំងសូចនាករដែលឆ្លុះបញ្ចាំងពីការ

អនុវត្តគោលនយោបាយអប់រំស្នែម មានសូចនាករចំនួន ៣៣ ដើម្បីឆ្លងយោបល់គ្រូណែនាំ។ ឯកម្រងសំណួរសម្រាប់ប្រមូលទិន្នន័យស្តីពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែម ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់នាយក នៅសាលារៀនជំនាន់ថ្មី ប្រើសូចនាករដែលឆ្លុះបញ្ចាំងពីកិច្ចគាំទ្រនៃទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែម ដល់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីចំនួន ១៦ ។

### ៣.១.១.៣ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញគឺប្រើប្រាស់ក្នុងសូចនាករដើម្បីចុះប្រមូលទិន្នន័យពីភាគគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតតួលេខជាក់លាក់ ដែលមានចំនួន៥កម្រិត ( Likert Scale ) ដែលត្រូវបានប្រើនៅក្នុងកម្រងសំណួរស្រាប់ដើម្បីឱ្យអ្នកចូលរួមធ្វើការវាស់វែងតាមកម្រិតសូចនាករ។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃលើកម្រិតនៃការបំពេញការងាររបស់គណៈគ្រប់គ្រងសាលាជំនាន់ថ្មី។

ក្នុងការស្រាវជ្រាវនេះ កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗមាន៥កម្រិតពីទាបបំផុត ( ១ ) ទៅខ្ពស់បំផុត ( ៥ ) ដែលមានកម្រិតចង្អុលបង្ហាញដូចខាងក្រោម៖

១ គឺ មិនយល់ស្របទាល់តែសោះ

២ គឺ មិនយល់ស្រប

៣ គឺ យល់ស្របខ្លះ

៤ គឺ យល់ស្រប

៥ គឺ យល់ស្របខ្លាំង

ការបកស្រាយទៅលើការគណនាពិន្ទុពីការប្រមូលទិន្នន័យដើម្បីវិភាគលើមធ្យមពិន្ទុនៃសូចនាករនីមួយៗគឺមានរូបមន្ត ( Best, 1981 ) ដូចខាងក្រោម៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត - ពិន្ទុទាបបំផុត}}{\text{ចំនួនកម្រិតចង្អុលបង្ហាញ}} = \frac{៥ - ១}{៥} = \frac{៤}{៥} = ០.៨០$$

១.០០ — ១.៨០  មានន័យថា  មិនយល់ស្របទាល់តែសោះ

១.៨១ — ២.៦០  មានន័យថា  មិនយល់ស្រប

២.៦១ — ៣.៤០  មានន័យថា  យល់ស្របខ្លះ

៣.៤១ — ៤.២០  មានន័យថា  យល់ស្រប

៤.២១ — ៥.០០  មានន័យថា  យល់ស្របខ្លាំង

### ៣.១.១.៤ កម្រងសំណួរ

កម្រងសំណួររៀបចំឡើងដើម្បីឆ្លើយតបទៅនឹងគោលបំណងស្រាវជ្រាវដោយសំយោគចូលគ្នារវាងសូចនាករតួនាទីនៃភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល ការអនុវត្តគោលនយោបាយអប់រំស្នេម និងទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេម ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ។ កម្រងសំណួរត្រូវបានចែកចេញជា២ប្រភេទគឺកម្រងសំណួរសម្រាប់គណៈគ្រប់គ្រង និងសម្រាប់គ្រូបង្រៀន ។ សម្រាប់ទិន្នន័យដែលប្រមូលបាននេះគឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវលើប្រធានបទនេះតែប៉ុណ្ណោះ។

### កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងគឺប្រើសម្រាប់ប្រមូលទិន្នន័យពីគណៈគ្រប់គ្រងសាលាជំនាន់ថ្មីនៅក្នុងរាជធានីភ្នំពេញហើយចែកចេញជា ៤ផ្នែកគឺ៖

### ផ្នែកទី១៖ ព័ត៌មានទូទៅ

ផ្តោតលើ ៨ចំណុចដូចជា៖១)តួនាទី ២)មុខវិជ្ជាឯកទេស ៣) បម្រើការងារនៅ ៤)ភេទ ៥)អាយុ ៧)បទពិសោធន៍ការងារ ៦)កម្រិតវប្បធម៌ និង៨)ភាសាបរទេស។

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី១ស្តីពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេម អ្នកស្រាវជ្រាវបែងចែកជាពីរផ្នែកគឺភាពជាអ្នកដឹកនាំរបស់នាយកសាលារៀនជំនាន់ថ្មី និងការអនុវត្តគោលនយោបាយអប់រំស្នេម។

**ផ្នែកទី២៖ ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី**

ផ្តោតលើសូចនាករនៃតួនាទីភាពជាអ្នកដឹកនាំគ្រប់គ្រងដោយឈរលើលទ្ធផលទាញបានសូចនាករគន្លឹះចំនួន៤គឺ ១) ការគ្រប់ការបង្រៀន និងរៀន ២)ការគ្រប់គ្រងរដ្ឋបាល ៣)ការគ្រប់គ្រងហិរញ្ញវត្ថុ និង៤) ការគ្រប់គ្រងធនធានមនុស្ស ដែលមានសូចនាកររងសរុប៤៦។ កម្រងសំណួរទាំងនេះប្រើប្រាស់ជាឧបករណ៍ដើម្បីប្រមូលទិន្នន័យឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការបំពេញការងាររបស់នាយកនៅសាលារៀនជំនាន់ថ្មីដែលប្រើប្រាស់ការគ្រប់គ្រងសាលារៀនយកគម្រូតាមការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល (School-Based Management)។

**ផ្នែកទី៣៖ ការអនុវត្តគោលនយោបាយអប់រំស្នែម**

ការគ្រប់គ្រងសាលារៀនជំនាន់ថ្មីយកគម្រូតាមការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល (School-Based Management) និងរួមផ្សំសាលារៀនជំនាន់ថ្មីមានគោលបំណងដាក់លាក់ក្នុងការអនុវត្តការអប់រំស្នែម ដើម្បីលើកកម្ពស់គុណភាពចំណេះដឹង សមត្ថភាព នវានុវត្តន៍របស់ប្រជាជនដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ និង ២០៥០។ ដើម្បីវាស់ស្ទង់ពីកម្រិតនៃការអនុវត្តគោលនយោបាយខាងលើ អ្នកស្រាវជ្រាវបានប្រើសូចនាករចំនួន៣៣ ដើម្បីជូនគណៈគ្រប់គ្រង នៅសាលាទាំងពីរបង្ហាញតាមការអនុវត្តជាក់ស្តែង។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបលើកម្រងសំណួរក្នុងគោលបំណងឱ្យទិនន្ន័យដែលប្រមូលបានមកកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយឆ្លើយតបទៅលើសំណួរស្រាវជ្រាវ។

**ផ្នែកទី៤៖ ការអនុវត្តគោលនយោបាយអប់រំស្នែម ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ**

ការអប់រំស្នែម គឺជានិន្នាការនៃការអប់រំបែបថ្មីដែលប្រទេសជាច្រើនបាននឹងកំពុងអនុវត្តទាមទារសមត្ថភាពគ្រូដែលមានចំណេះស្នែម និងវិធីសាស្រ្តបង្រៀនស្នែម នេះផងដែរ។ ដើម្បីអនុវត្តគោលនយោបាយអប់រំស្នែម តម្រូវជាចំខាតត្រូវផ្តល់កិច្ចគាំទ្រដល់គ្រូបង្រៀនដូចជារៀបចំសមត្ថភាពគ្រូ ផ្តល់ការលើកទឹកចិត្ត សម្ភារៈ

បរិស្ថានសិក្សា ស្វ័យភាពក្នុងការបំពេញការងារជាដើម។ ដើម្បីឆ្លុះបញ្ចាំងពីការគាំទ្រនៃការអនុវត្តគោលនយោបាយអប់រំស្នែម ដល់ការបង្រៀនរបស់គ្រូ អ្នកស្រាវជ្រាវបានប្រើសូចនាករចំនួន១៦ដើម្បីជូនគណៈគ្រប់គ្រងសាលាបង្ហាញតាមការជាក់ស្តែងដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី២។ លើសពីនេះអ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបលើកម្រងសំណួរក្នុងគោលបំណងឱ្យទិន្នន័យដែលប្រមូលបានមកកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយឆ្លើយតបទៅលើសំណួរស្រាវជ្រាវ។

**កម្រងសំណួរសម្រាប់គ្រូបង្រៀន**

កម្រងសំណួរសម្រាប់គ្រូបង្រៀនគឺប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យពីគ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីនៅក្នុងរាជធានីភ្នំពេញហើយចែកចេញជា ៤ផ្នែក ប្រើប្រាស់សូចនាករ និងមតិយោបល់បន្ថែមដូចកម្រងសំណួរសម្រាប់គណៈគ្រប់គ្រងដែរដោយមានប្តូរខ្លឹមសារតិចតួចដើម្បីឱ្យសមស្របសម្រាប់គ្រូបង្រៀនឆ្លុះបញ្ចាំងឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទាំងពីរ។

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

ផ្តោតលើ៩ចំណុចដូចជា៖ ១)មុខវិជ្ជាឯកទេស ២)បង្រៀនមុខវិជ្ជា ៣)បង្រៀនថ្នាក់ទី ៤)បម្រើការងារនៅ ៥)ភេទ ៦)អាយុ ៧)កម្រិតវប្បធម៌ ៨) បទពិសោធន៍បង្រៀន ៩)ចំនួនម៉ោងបង្រៀនក្នុងមួយសប្តាហ៍។

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី១ស្តីពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែម អ្នកស្រាវជ្រាវបែងចែកជាពីរផ្នែកគឺភាពជាអ្នកដឹកនាំរបស់នាយកសាលារៀនជំនាន់ថ្មី និងការអនុវត្តគោលនយោបាយអប់រំស្នែម។

**ផ្នែកទី២៖ ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី**

ផ្តោតលើសូចនាករនៃតួនាទីភាពជាអ្នកដឹកនាំគ្រប់គ្រងដោយឈរលើលទ្ធផលទាញបានសូចនាករគន្លឹះចំនួន៤គឺ ១) ការគ្រប់ការបង្រៀន និងរៀន ២)ការគ្រប់គ្រងរដ្ឋបាល ៣)ការគ្រប់គ្រងហិរញ្ញវត្ថុ និង៤)ការ

គ្រប់គ្រងធនធានមនុស្ស ដែលមានសូចនាកររងសរុប៤៦។ កម្រងសំណួរទាំងនេះប្រើប្រាស់ជាឧបករណ៍ដើម្បីប្រមូលទិន្នន័យឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការបំពេញការងាររបស់នាយកនៅសាលារៀនជំនាន់ថ្មីដែលប្រើប្រាស់ការគ្រប់គ្រងសាលារៀនយកគម្រូតាមការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល (School-Based Management)។

### ផ្នែកទី៣៖ ការអនុវត្តគោលនយោបាយអប់រំស្ទែម

ការគ្រប់គ្រងសាលារៀនជំនាន់ថ្មីយកគម្រូតាមការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល (School-Based Management) និងរួមផ្សំសាលារៀនជំនាន់ថ្មីមានគោលបំណងដាក់លាក់ក្នុងការអនុវត្តការអប់រំស្ទែម ដើម្បីលើកកម្ពស់គុណភាពចំណេះដឹង សមត្ថភាព នវានុវត្តន៍របស់ប្រជាជនដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ និង ២០៥០។ ដើម្បីវាស់ស្ទង់ពីកម្រិតនៃការអនុវត្តគោលនយោបាយខាងលើ អ្នកស្រាវជ្រាវបានប្រើសូចនាករចំនួន ៣៣ ដើម្បីជូនគ្រូបង្រៀន នៅសាលាទាំងពីរបង្ហាញតាមការអនុវត្តជាក់ស្តែង។ អ្នកសិក្សាស្រាវជ្រាវបានស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបលើកម្រងសំណួរក្នុងគោលបំណងឱ្យទិន្នន័យដែលប្រមូលបានមកកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយឆ្លើយតបទៅលើសំណួរស្រាវជ្រាវ។

### ផ្នែកទី៤៖ ការអនុវត្តគោលនយោបាយអប់រំស្ទែម ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ

ការអប់រំស្ទែម គឺជានិន្នាការនៃការអប់រំបែបថ្មីដែលប្រទេសជាច្រើនបាននឹងកំពុងអនុវត្តើយទាមទារសមត្ថភាពគ្រូដែលមានចំណេះដឹងស្ទែម និងវិធីសាស្ត្របង្រៀនស្ទែម ផងដែរ។ ដើម្បីអនុវត្តគោលនយោបាយអប់រំស្ទែម តម្រូវដាច់ខាតត្រូវផ្តល់កិច្ចគាំទ្រដល់គ្រូបង្រៀនដូចជារៀបចំសមត្ថភាពគ្រូ ផ្តល់ការលើកទឹកចិត្ត សម្ភារៈ បរិស្ថានសិក្សា ស្វ័យភាពក្នុងការបំពេញការងារជាដើម។ ដើម្បីឆ្លុះបញ្ចាំងពីការគាំទ្រនៃការអនុវត្តគោលនយោបាយអប់រំស្ទែម ដល់ការបង្រៀនរបស់គ្រូ អ្នកស្រាវជ្រាវបានប្រើសូចនាករចំនួន ១៦ ដើម្បីជូនគ្រូបង្រៀនបង្ហាញតាមការជាក់ស្តែងដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវទី២។ លើសពីនេះអ្នកសិក្សាស្រាវជ្រាវបាន

ស្នើសុំមតិយោបល់បន្ថែមពីការឆ្លើយតបលើកម្រងសំណួរក្នុងគោលបំណងឱ្យទិន្នន័យដែលប្រមូលបានមកកាន់តែមានភាពជឿជាក់ខ្ពស់ និងគ្រប់ជ្រុងជ្រោយឆ្លើយតបទៅលើសំណួរស្រាវជ្រាវ។

### ៣.១.១.៥ ការប្រមូលទិន្នន័យតាមបរិមាណវិស័យ

ការប្រមូលទិន្នន័យសម្រាប់កិច្ចការស្រាវជ្រាវលើប្រធានបទនេះគឺអ្នកសិក្សាស្រាវជ្រាវបានទទួលលិខិតអនុញ្ញាតជាផ្លូវការសម្រាប់ការចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅនៃគម្រោងស្រាវជ្រាវដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា មានរយៈពេលចន្លោះ៣ខែសម្រាប់ចុះប្រមូលទិន្នន័យនៅសាលារៀនជំនាន់ថ្មី ទាំងពីរនៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។ លិខិតឧទ្ទេសនាមដែលបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡាត្រូវបានយកទៅប្រគល់ជូនមន្ទីអប់រំ យុវជន និងកីឡារាជធានីភ្នំពេញដើម្បីសុំការអនុញ្ញាតបំពេញភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់មន្ទីអប់រំរាជធានីភ្នំពេញ និងការសម្របសម្រួលផ្សេងៗ។ បន្ទាប់មកអ្នកស្រាវជ្រាវបានយកលិខិតឧទ្ទេសនាមជូននាយក ឬគណៈគ្រប់គ្រងសាលាទាំងពីរដើម្បីស្នើសុំកិច្ចសហការក្នុងការចុះប្រមូលទិន្នន័យ និងការចាំបាច់ផ្សេងៗ។ ការចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរ ឬGoogle Form។ ជាលទ្ធផលនៃការប្រមូលទិន្នន័យពីភាគសំណាកទទួលបានចំនួន ១២៣ កម្រងសំណួរ ដើម្បីយកមកធ្វើការវិភាគបកស្រាយលើលទ្ធផលសិក្សាស្រាវជ្រាវ។

### ៣.១.១.៦ ការវិភាគទិន្នន័យបរិមាណវិស័យ

កម្រងសំណួរដែលប្រមូលបានពីក្រុមគោលដៅក្នុងការផ្តល់ទិន្នន័យត្រូវបានយកមករៀបចំតាមលំដាប់ផ្នែកគណៈគ្រប់គ្រង និងគ្រូបង្រៀននៅក្នុងកម្មវិធី Excel សម្រាប់ជាមូលដ្ឋានក្នុងការវិភាគទិន្នន័យបរិមាណវិស័យ។ ការវិភាគទិន្នន័យផ្តោតសំខាន់ទៅលើៈ ១) ភាគរយ (%) ២) មធ្យមភាគពិន្ទុ (Mean) ៣) គម្លាតស្តង់ដា (Standard Deviation)។

### ៣.១.២ ការសិក្សាស្រាវជ្រាវគុណវិស័យ

ដើម្បីឱ្យលទ្ធផលនៃការស្រាវជ្រាវកាន់តែមានសង្គតិភាព និងឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវ ទិន្នន័យគុណវិស័យត្រូវបានរៀបចំប្រមូលបន្ថែម ដើម្បីផ្ទៀងផ្ទាត់ទៅលើលទ្ធផលនៃមធ្យមភាគពិន្ទុ

ដែលទទួលបានពីទិន្នន័យបរិមាណវិស័យ និងបានឆ្លងកាត់ការត្រួតពិនិត្យ និងវាយតម្លៃពីគ្រូណែនាំ។ អ្នកស្រាវជ្រាវបានរៀបចំការសម្ភាសន៍ (Semi-structured interview) ជាមួយអ្នកចូលរួមចំនួន ៥គ្រឹះស្ថាន មានចំនួន ៩នាក់។ សំណួរសម្ភាសន៍មានទម្រង់ជាសំណួរបើក ដើម្បីសួរទៅភាគីចូលរួមសម្ភាសន៍ ផ្តល់ទិន្នន័យតាមរយៈបទពិសោធន៍ បើកកិច្ចពិភាក្សា និងវិភាគស៊ីជម្រៅទៅលើព័ត៌មានដែលទាក់ទងនឹងសំណួរស្រាវជ្រាវនៃប្រធានបទដែលយកមកសិក្សា ព្រមទាំងប្រើប្រាស់ការសង្កេត (Observation Protocol) ក្នុងកំឡុងពេលសម្ភាសន៍ផងដែរ។

### ៣.១.២.១ អ្នកចូលរួមសម្ភាសន៍

អ្នកចូលរួមក្នុងកិច្ចសម្ភាសន៍មានចំនួន៩នាក់ (ស្រី២នាក់)ទៅលើក្រុមគោលដៅចំនួន៥គឺ៖ ១) មន្ត្រីសាលារៀនជំនាន់ថ្មី ២) មន្ត្រីមន្ទីអប់រំរាជធានីភ្នំពេញ ៣) មន្ត្រីមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ៤) មន្ត្រីនាយកដ្ឋានគោលនយោបាយអប់រំ និង៥) មន្ត្រីនាយកដ្ឋានផែនការ។ អ្នកស្រាវជ្រាវបានជ្រើសរើសអ្នកចូលរួមតាមលក្ខខណ្ឌកំណត់ និងមានគោលបំណងច្បាស់លាស់ (Purposive Sampling) ដោយផ្តោតលើចំណេះដឹង និងបទពិសោធន៍ការងារក្នុងវិស័យអប់រំរបស់អ្នកចូលរួម។

**តារាង៣.៣៖ អ្នកចូលរួមផ្តល់សម្ភាសន៍**

| ល.រ | តំណាងស្ថាប័ន | តួនាទី | ចំនួន |
|---|---|---|---|
| ១ | សាលារៀនជំនាន់ថ្មី | គណៈគ្រប់គ្រង និងគ្រូបង្រៀន | ៤នាក់ |
| ២ | មន្ទីអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ | ថ្នាក់ដឹកនាំ | ១នាក់ |
| ៣ | មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | ថ្នាក់ដឹកនាំ និងគ្រូបង្រៀន | ២នាក់ |
| ៤ | នាយកដ្ឋានគោលនយោបាយនៃក្រសួងអប់រំ | ថ្នាក់ដឹកនាំ | ១នាក់ |
| ៥ | នាយកដ្ឋានផែនការនៃក្រសួងអប់រំ | ថ្នាក់ដឹកនាំ | ១នាក់ |
| | **សរុប** | | ៩នាក់ |

**លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកចូលរួមផ្តល់កិច្ចសម្ភាសន៍នៅសាលារៀនជំនាន់ថ្មី៖**

- **គ្រូបង្រៀន**
    - ✓ ជាគ្រូដែលកំពុងបង្រៀននៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ
    - ✓ មានកម្រិតសញ្ញាបត្របរិញ្ញាបត្រលើឯកទេសដែលកំពុងបង្រៀន
    - ✓ មានបទពិសោធន៍ក្នុងការបង្រៀនចាប់ពី ៥ឆ្នាំឡើងទៅ
    - ✓ ជាគ្រូដែលមានម៉ោងបង្រៀនចំនួនចាប់ពី ១៦ម៉ោងឡើងទៅ។
- **គណៈគ្រប់គ្រង**
    - ✓ មានតួនាទីជាថ្នាក់ដឹកនាំនៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ
    - ✓ មានកម្រិតសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់លើវិស័យអប់រំ
    - ✓ មានបទពិសោធក្នុងការបំពេញការងារក្នុងវិស័យអប់រំចាប់ពី ១០ឆ្នាំឡើងទៅ
    - ✓ បានចូលរួមវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំក្នុងវិស័យអប់រំ។

**លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកចូលរួមផ្តល់កិច្ចសម្ភាសន៍នៅមន្ទីរអប់រំ យុវជន និងកីឡា**

- ✓ កំពុងបំពេញការងារក្នុងមុខតំណែងជាថ្នាក់ដឹកនាំ
- ✓ មានកម្រិតសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ
- ✓ មានបទពិសោធក្នុងការងារបំពេញការងារក្នុងវិស័យអប់រំចាប់ពី ១០ឆ្នាំឡើងទៅ
- ✓ មានចំណេះដឹងលើការអប់រំស្ទែម និងកម្មវិធីសិក្សានៅសាលារៀនជំនាន់ថ្មី។

**លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកចូលរួមផ្តល់កិច្ចសម្ភាសន៍នៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី**

- ✓ កំពុងបំពេញការងារក្នុងមុខតំណែងជាថ្នាក់ដឹកនាំ
- ✓ មានកម្រិតសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់

- ✓ មានបទពិសោធក្នុងការងារបំពេញការងារក្នុងវិស័យអប់រំរយៈពេលចាប់ពី ១០ឆ្នាំឡើងទៅ
- ✓ មានចំណេះដឹងលើការអប់រំស្ទែម និងកម្មវិធីសិក្សានៅសាលារៀនជំនាន់ថ្មី។

**លក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសអ្នកចូលរួមផ្តល់កិច្ចសម្ភាសន៍នៅនាយកដ្ឋានគោលនយោបាយ និងនាយកដ្ឋានផែនការ**

- ✓ កំពុងបំពេញការងារក្នុងមុខតំណែងជាថ្នាក់ដឹកនាំ
- ✓ មានកម្រិតសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់
- ✓ មានបទពិសោធន៍ក្នុងការបំពេញការងារចាប់ពី៥ឆ្នាំឡើងទៅ
- ✓ មានចំណេះដឹងលើការអប់រំស្ទែម និងកម្មវិធីសិក្សានៅសាលារៀនជំនាន់ថ្មី។

### ៣.១.២.២ សំណួរសម្ភាសន៍

សំណួរសម្ភាសន៍សម្រាប់សម្ភាសន៍ពីអ្នកចូលរួមដែលជាមន្ត្រីអប់រំ។ សំណួរស្រាវជ្រាទី១មានពីរផ្នែកគឺភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី និងការអនុវត្តគោលនយោបាយអប់រំស្ទែម។ សម្រាប់ភាពជាអ្នកដឹកនាំរបស់នាយកសួរទៅលើផ្នែកផ្សេងៗដូចជាការគ្រប់គ្រងការរៀន និងបង្រៀនផ្តោតលើការអនុវត្តកម្មវិធីសិក្សា ការអនុវត្តវិធីសាស្ត្របង្រៀន និងការវាយតម្លៃលទ្ធផលប្រកបដោយវិទ្យាសាស្ត្រ។ ការគ្រប់គ្រងរដ្ឋបាលផ្តោតលើការប្រើប្រាស់លិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រង និងការលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងដំណើរការសាលារៀន។ ការគ្រប់គ្រងហិរញ្ញវត្ថុផ្តោតលើការកៀរគរថវិការគាំទ្រដំណើរការសាលារៀន និងតម្លាភាពក្នុងការគ្រប់គ្រងថវិការ។ ចំណែកឯការគ្រប់គ្រងធនធានមនុស្សផ្តោតលើការអភិវឌ្ឍសមត្ថភាពបុគ្គលិក ការរៀបចំបរិយាកាសបំពេញការងារ។ សម្រាប់ការអនុវត្តគោលនយោបាយអប់រំស្ទែមផ្តោតលើការបញ្ជ្រាបការអនុវត្តគោលនយោបាយអប់រំស្ទែម ការគាំទ្រផ្នែកសម្ភារៈ បច្ចេកទេសសម្រាប់ការអប់រំស្ទែម និងការរៀបចំបរិយាកាសសិក្សាដែលគាំទ្រដល់ការអប់រំស្ទែម។ សំណួរស្រាវជ្រាវទី២ផ្តោតលើការរៀបចំសមត្ថភាពគ្រូបង្រៀនឆ្លើយតបការអប់រំស្ទែម។

### ៣.១.២.៣ ការប្រមូលទិន្នន័យគុណវិស័យ

សម្រាប់ការប្រមូលទិន្នន័យគុណវិស័យតាមរយៈការសម្ភាសជាមួយអ្នកចូលរួមនូវសំណួរសម្ភាសន៍ដែលបានរៀបចំរួច។ ដំបូងអ្នកស្រាវជ្រាវជូនលិខិតស្នើសុំសម្ភាសន៍ដល់អ្នកចូលរួមដើម្បីសុំកិច្ចសហការណ៍ បញ្ជាក់ពីពេលវេលា និងមធ្យោបាយសម្ភាសន៍ព្រមទាំងបង្ហាញសំណួរគោលជាមុនដើម្បីអាចឱ្យអ្នកចូលរួមត្រៀមលក្ខណៈក្នុងការផ្ដល់ទិន្នន័យ និងការពិភាក្សាលើចំណុចសំខាន់ៗបានច្បាស់លាស់ពេលសម្ភាសន៍។ អ្នកស្រាវជ្រាវរៀបចំការសម្ភាសន៍ដោយផ្ទាល់ ឬតាមរយៈប្រព័ន្ធអនឡាញ (Zoom or Google meet) បត់បែនទៅតាមលទ្ធភាពរបស់អ្នកចូលរួមសម្ភាសន៍។ និតិវិធីនៃការសម្ភាសន៍គឺប្រើប្រាស់ទម្រង់ពាក់កណ្ដាលរចនាសម្ព័ន្ធ (Semi-structure interview) ជាមួយអ្នកចូលរួមផ្ដល់កិច្ចសម្ភាសន៍ទាំងអស់។ ការសង្កេតទៅលើឥរិយាបថរបស់អ្នកចូលរួមសម្ភាសន៍ និងបរិយាកាសក្នុងការផ្ដល់ទិន្នន័យត្រូវបានប្រើប្រាស់ក្នុងដំណើរការសម្ភាសន៍។ មុនពេលចាប់ផ្ដើមសម្ភាសន៍ អ្នកស្រាវជ្រាវបានណែនាំខ្លួន និងប្រាប់ពីវត្ថុបំណងនៃការស្រាវជ្រាវទៅដល់អ្នកចូលរួមជាមុន ហើយទិន្នន័យដែលបានពីការសម្ភាសន៍គឺប្រើប្រាស់សម្រាប់តែការសិក្សាស្រាវជ្រាវលើប្រធានបទនេះតែម្យ៉ាងប៉ុណ្ណោះ។ អ្នកស្រាវជ្រាវយកចិត្តទុកដាក់ស្ដាប់ កត់ត្រា និងបានស្នើសុំថតសម្លេងលើដំណើរការសម្ភាសន៍។ ពេលសម្ភាសន៍ចប់ អ្នកស្រាវជ្រាវបានចុះកូដរក្សាទុក សម្រាប់បន្តធ្វើការវិភាគទាញរកលទ្ធផលនៃទិន្នន័យគុណវិស័យ។

### ៣.១.២.៤ ការវិភាគទិន្នន័យតាមគុណវិស័យ

ក្រោយពីបានប្រមូលទិន្នន័យតាមរយៈសម្ភាសន៍រួចមក ទិន្នន័យគុណវិស័យត្រូវបានយកមករៀបចំវិភាគទៅតាមនីតិវិធីច្បាស់លាស់ដោយធ្វើការចាប់បណ្ដុំនៃពាក្យលើអថេរនៃសំណួរនីមួយៗ និងឆ្លើយតបទៅនឹងគោលគំនិតចម្បងៗពីអ្នកផ្ដល់ទិន្នន័យ។ អ្នកសិក្សាស្រាវជ្រាវបានកត់ត្រាទិន្នន័យពីការធ្វើសម្ភាសន៍ទៅតាមផ្នែកនៃសំណួរស្រាវជ្រាវទី១ និងទី២។ ការរៀបចំត្រូវបានអនុវត្តទៅតាមជំហានដូចជា៖១) រៀបចំទិន្នន័យប្រមូលបានតាមរយៈការថតសម្លេងបទសម្ភាសន៍ ការបកប្រែទិន្នន័យ ការកត់ត្រាព័ត៌មានលម្អិត និងការកំណត់ខ្លឹមសារ (Transcript) ២) កំណត់ក្របខណ្ឌនៃការវិភាគទិន្នន័យដោយធ្វើការដាក់កូដទិន្នន័យ

ក្នុងគម្រោងវិភាគ ដាក់សញ្ញា និងកំណត់ទិន្នន័យ (Coding and Consolidation) ៣) សំយោគក្របខណ្ឌនៃគោលគំនិតរួម (Themes) តាមរយៈការវិភាគពិពណ៌នាដោយផ្អែកលើក្របខណ្ឌ (Content analysis) ឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវនីមួយៗ។

## ៣.២ ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវបានប្រកាន់ខ្ជាប់នូវគោលការណ៍ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងការចុះប្រមូលទិន្នន័យនៅតាមក្រុមគោលដៅដែលបានកំណត់នៅក្នុងការស្រាវជ្រាវប្រធានបទ។ លិខិតឧទ្ទេសនាមសម្រាប់បំពេញបេសកកម្មត្រូវបានអនុញ្ញាតដោយវិទ្យាស្ថានជាតិអប់រំ និងបានប្រគល់ជូនទៅតាមអង្គភាពពាក់ព័ន្ធ។ ការប្រមូលទិន្នន័យគឺអ្នកសិក្សាស្រាវជ្រាវបានប្រាប់ពីគោលបំណងច្បាស់លាស់ និងរក្សាការសម្ងាត់នៃការផ្ដល់ទិន្នន័យលើកម្រងសំណួរក៏ដូចជាសំណួរសម្ភាសន៍។ ទិន្នន័យដែលផ្តល់មកទាំងពីរបែបនេះគឺសម្រាប់ប្រើប្រាស់ក្នុងគោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទតែប៉ុណ្ណោះ។ ការផ្ដល់ទិន្នន័យពីក្រុមគោលដៅគឺក្នុងលក្ខខណ្ឌពេញចិត្ត មានការចូលរួមការសហការគ្នា និងផ្ដល់ព័ត៌មានដោយឈរលើភាពពិតប្រាកដ និងបទពិសោធន៍ជាក់ស្ដែងទៅលើការងារក្នុងវិស័យអប់រំ។

# ជំពូកទី៤
# លទ្ធផល និងការពិភាក្សា

ការបកស្រាយ និងការពិភាក្សាទៅលើទិន្នន័យទទួលបានពីបរិមាណវិស័យ និងគុណវិស័យពីគ្រូបង្រៀន និងគណៈនាយកសាលារៀន។ ប្រធានបទសិក្សាពី **"ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ"** ត្រូវបានលើកយកមកវិភាគ និងសំយោគស្របទៅតាមគោលបំណងនៃការសិក្សាស្រាវជ្រាវទាំងពីរគឺ ១) ស្វែងយល់ពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ និង២) ស្វែងយល់ពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាដល់ការបង្រៀនរបស់គ្រូនៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ។

## ៤.១ ទិន្នន័យព័ត៌មានទូទៅ

ព័ត៌មានទូទៅដែលត្រូវយកមកបង្ហាញនៅក្នុងផ្នែកនេះគឺជាព័ត៌មានរបស់គ្រូបង្រៀន គណៈនាយក និងអ្នកឯកទេសអប់រំដែលជាភាគសំណាកនៃការសិក្សាស្រាវជ្រាវនេះទាំងអស់ស្តីពីកម្រិតថ្នាក់បង្រៀន ភេទ អាយុ កម្រិតវប្បធម៌ បទពិសោធន៍ការងារ មុខវិជ្ជាឯកទេស មុខវិជ្ជាបង្រៀន ចំនួនម៉ោងបង្រៀន ទីកន្លែងបម្រើការងារ និងភាសាបរទេស។

### ៤.១.១ ព័ត៌មានទូទៅរបស់គ្រូបង្រៀន

តាមទិន្នន័យដែលបានពីគ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីទាំងពីរបានបង្ហាញថាគ្រូដែលចូលរួមផ្តល់ទិន្នន័យក្នុងការសិក្សាស្រាវជ្រាវនេះមានចំនួន ១២០នាក់ ស្រី ៦១ នាក់ មានគ្រូគ្រប់មុខវិជ្ជាឯកទេសក្នុងនោះគ្រូមុខវិជ្ជាឯកទេសគណិតវិទ្យាមានចំនួនច្រើនជាងគេស្មើ ១៥.៨៣% ខណៈមុខវិជ្ជាឯកទេសកីឡា និងសិល្បៈមានចំនួនតិចជាងគេគឺ ១.៦៧% និងបានពីគ្រូដែលកំពុងបង្រៀនគ្រប់មុខវិជ្ជាហើយមុខវិជ្ជាដែលមាន

ចំនួនច្រើនជាងគេនៅតែគណិតវិទ្យាមានចំនួន ១៥% និងមុខវិជ្ជាដែលមានចំនួនតិចជាគេកីឡាមានចំនួន ១.៦៧%។ គ្រូបង្រៀនថ្នាក់ទី៧មានចំនួន ១២.៥០% ថ្នាក់ទី៨មានចំនួន ១១.៦៧% ថ្នាក់ទី៩មានចំនួន១០% ថ្នាក់ទី១០មានចំនួន ១០% ថ្នាក់ទី១១មានចំនួន២៩.១៧% និងថ្នាក់ទី១២មានចំនួន ២៦.៦៧%។ គ្រូបង្រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិមានចំនួន ៤៥% និងគ្រូបង្រៀននៅវិទ្យាល័យព្រែកលៀបមានចំនួន ៥៥% ។ គ្រូបង្រៀនភេទស្រីមានចំនួន ៥១% និងគ្រូបង្រៀនភេទប្រុសមានចំនួន ៤៩.%។ គ្រូបង្រៀនចំនួន ៤៥.៨៣% មានអាយុចន្លោះ ២៥ ដល់៣០ឆ្នាំ មាន ៣៦.៦៧% អាយុចន្លោះ ៣១ ដល់ ៣៥ឆ្នាំ មាន ៨.៣៣% អាយុចន្លោះ ៣៦ ដល់ ៤០ឆ្នាំ និង ៩.១៧% មានអាយុលើស ៤០ឆ្នាំ។ គ្រូបង្រៀនបានបញ្ចប់ថ្នាក់ទី១២មានចំនួន ៥% បញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួន ៧៨.៣៣% និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ១៦.៦៧%។ គ្រូបង្រៀនមានចំនួន ៤១.៦៧% មានបទពិសោធន៍ត្រឹម ១ ដល់ ៥ឆ្នាំ ចំនួន ៣៨.៣៣% មានបទពិសោធន៍ត្រឹម ៦ ដល់ ១០ឆ្នាំ ចំនួន ៦.៦៧% មានបទពិសោធន៍ពី ១១ ដល់ ១៥ឆ្នាំ និងគ្រូបង្រៀនដែលមានបទពិសោធន៍លើសពី ១៥ឆ្នាំមានចំនួន ១៣.៣៣%។ គ្រូបង្រៀនដែលបង្រៀនចន្លោះពី សូន្យ ដល់ ១៤ម៉ោងមានចំនួន ៣.៣៣% ចន្លោះពី ១៥ ដល់ ២០ម៉ោងមានចំនួន ៦៤.១៧% ចន្លោះពី ២១ ទៅ ២៤ម៉ោង ១៤.១៧% និងគ្រូបង្រៀនចាប់ពី២៥ម៉ោងឡើងមានចំនួន ១៨.៣៣%។

### ៤.១.២ ព័ត៌មានទូទៅរបស់គណៈគ្រប់គ្រងសាលារៀន

តាមទិន្នន័យដែលបានពីគណៈគ្រប់គ្រងសាលាទាំងពីរបង្ហាញថាគណៈគ្រប់គ្រងដែលមានតួនាទីជានាយកសាលាមានចំនួន ៣៣.៣៣% និងមានតួនាទីជានាយក ឬនាយិការងមានចំនួន៦៦.៦៧%។ គណៈគ្រប់គ្រងមានមុខវិជ្ជាឯកទេសគីមីវិទ្យាចំនួន ៦៦.៦៧% និងគណិតវិទ្យាចំនួន ៣៣.៣៣%។ គណៈគ្រប់គ្រងដែលបម្រើការងារនៅវិទ្យាល័យព្រះស៊ីសុវត្ថិមានចំនួន ៣៣.៣៣% និងវិទ្យាល័យព្រែកលៀបចំនួន ៦៦.៦៧% ។ គណៈគ្រប់គ្រងភេទស្រីចំនួន ៣៣.៦៧% និងគណៈគ្រប់គ្រងភេទប្រុសចំនួន៦៦.៦៧%។ គណៈគ្រប់គ្រងទាំងអស់មានអាយុលើស ៤០ ឆ្នាំ និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ គណៈគ្រប់គ្រងដែលមានបទពិសោធន៍ចន្លោះ ១១ ដល់ ១៥ ឆ្នាំ មានចំនួន ៣៣.៣៣% និងលើសពី ១៥ ឆ្នាំ មានចំនួន៦៦.៦៧%

។ គណៈគ្រប់គ្រងដែលមានចំណេះដឹងភាសាបរទេសត្រឹមកម្រិតខ្សោយមានចំនួន ៣៣.៣៣% កម្រិតមធ្យម ៣៣.៣៣% និងកម្រិតល្អបង្គួរ ៣៣.៣៣%។

## ៤.២ លទ្ធផលបរិមាណវិស័យលើទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម

### ៤.២.១ ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី

### ក.ទិន្នន័យបរិមាណវិស័យ

ការគ្រប់គ្រងតាមសាលារៀនបានល្អផ្តល់ជូននាយកសាលា គ្រូបង្រៀន សិស្សានុសិស្ស និងអាណាព្យាបាលបានចូលរួមជាចំណែកមួយក្នុងការគ្រប់គ្រងលើដំណើរការនៃការអប់រំឱ្យបានល្អប្រសើរ ចូលរួមទទួលខុសត្រូវក្នុងដំណើរការអភិវឌ្ឍសាលាលារៀនដើម្បីបង្កើតនូវបរិយាកាសសិក្សាប្រកបដោយប្រសិទ្ធភាពដើម្បីឱ្យលទ្ធផលសិក្សារបស់សិស្សមានគុណភាពឆ្លើយតបផងដែរ។ តារាងទិន្នន័យខាងក្រោមនេះបានបង្ហាញពីមធ្យមភាគសរុបនៃភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មីតាមសូចនាករនីមួយៈ

**តារាង៤.១៖ ការគ្រប់គ្រងការបង្រៀន និងរៀន**

| ល.រ | ការគ្រប់ការបង្រៀន និងរៀន | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | នាយកមានភាពជឿជាក់ និងទំនុកចិត្តលើការងាររបស់គ្រូបង្រៀនក្នុងការសម្រេចចក្ខុវិស័យរបស់សាលារៀន | ៤.២៤ | ០.៣៤ | ល្អណាស់ | ៣.៦៧ | ០.៥៨ | ល្អបង្គួរ |
| ២ | បានទទួលការផ្តល់យោបល់ ឬអនុសាសន៍លើវិធីសាស្ត្របង្រៀនល្អៗបន្ថែម | ៤.១៨ | ០.៣៤ | ល្អ | ៤.០០ | ០.០០ | ល្អ |
| ៣ | មានសៀវភៅវត្តមានគ្រូនិងមានការត្រួតពិនិត្យសៀវភៅអវត្តមានជាប្រចាំ | ៤.៣៧ | ០.៣០ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |

| ល.រ | ការគ្រប់ការបង្រៀន និងរៀន | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ៤ | មានការប្រជុំបច្ចេកទេសជារៀងរាល់ខែ | ៤.៦៦ | ០.៦០ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ៥ | នាយកសាលាផ្តល់ និងជំរុញឱ្យប្រើប្រាស់បណ្ណាល័យ | ៤.៦០ | ០.៦៩ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៦ | វិធីសាស្រ្តបង្រៀនថ្មីៗត្រូវបានលើកទឹកចិត្តឱ្យអនុវត្ត | ៤.៦៦ | ០.៦១ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ៧ | កម្មវិធីសិក្សា និងកិច្ចតែងការបង្រៀនបានត្រួតពិនិត្យជាប្រចាំ | ៤.៥១ | ០៦៧ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៨ | គ្រូបង្រៀនល្អទទួលបានការលើកទឹកចិត្តជាសម្ភារៈ និងការសរសើរ | ៣.៩៨ | ០.៨៤ | ល្អ | ៤.៣៣ | ១.១៥ | ល្អណាស់ |
| ៩ | នាយកសាលាលើកទឹកចិត្តមាតាបិតាសិស្សឱ្យតាមដានលទ្ធផលសិក្សារបស់កូន | ៤.៦៤ | ០.៦៦ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ១០ | លទ្ធផលសិក្សារបស់សិស្សបានផ្សព្វផ្សាយជូនដល់សហគមន៍ | ៤.៦៩ | ០.៥៦ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ១១ | បង្កើតយន្តការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស តាមរយៈការធ្វើតេស្តស្តង់ដា | ៤.៥០ | ០.៧១ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |

| ល.រ | ការគ្រប់ការបង្រៀន និងរៀន | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| សរុប | | ៤.៤៧ | ០.៦៩ | ល្អណាស់ | ៤.៦៤ | ០.៣១ | ល្អណាស់ |

តាមតារាង៤.១ ទិន្នន័យទទួលបានពីគ្រូបង្រៀនបានបង្ហាញថា ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី លើការគ្រប់គ្រងការបង្រៀន និងរៀនឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៤៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុត "លទ្ធផលសិក្សារបស់សិស្សបានផ្សព្វផ្សាយជូនដល់សហគមន៍" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៦៩)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "គ្រូបង្រៀនល្អទទួលបានការលើកទឹកចិត្តជាសម្ភារៈ និងការសរសើរ" ឋិតក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៩៨)។

គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យពីភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មីលើការគ្រប់គ្រងការបង្រៀន និងរៀនឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៦៤)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតមានចំនួនប្រាំសូចនាករគឺៈ "មានការប្រជុំបច្ចេកទេសជារៀងរាល់ខែ" "វិធីសាស្រ្តបង្រៀនថ្មីៗត្រូវបានលើកទឹកចិត្តឱ្យអនុវត្ត" "នាយកសាលាលើកទឹកចិត្តមាតាបិតាសិស្សឱ្យតាមដានលទ្ធផលសិក្សារបស់កូន" "លទ្ធផលសិក្សារបស់សិស្សបានផ្សព្វផ្សាយជូនដល់សហគមន៍" និង"បង្កើតយន្តការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស តាមរយៈការធ្វើតេស្តស្តង់ដា" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ= ៥.០០) ស្មើៗគ្នា។ សូចនាករទទួលបានពិន្ទុទាបបំផុតគឺ "នាយកមានភាពជឿជាក់ និងទំនុកចិត្តលើការងាររបស់គ្រូបង្រៀនក្នុងការសម្រេចចក្ខុវិស័យរបស់សាលារៀន" ឋិតក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគពិន្ទុ= ៣.៦៧)។

តារាង៤.២៖ ការគ្រប់គ្រងរដ្ឋបាល

| ល.រ | ការគ្រប់គ្រងរដ្ឋបាល | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | នាយកលើកទឹកចិត្តដល់ការគិតឡើងវិញស្តីពីគំនិតថ្មីៗដែលពុំធ្លាប់ចោទសួរពីមុនៗ | ៤.០៦ | ០.៨៧ | ល្អ | ៤.៣៣ | ០៥៨ | ល្អណាស់ |
| ២ | នាយកបានប្រើប្រាស់ប្រព័ន្ធបណ្តាញសង្គមដើម្បីទទួលបានព័ត៌មានឆ្លើយតបបច្ចុប្បន្នភាព | ៤.៤៤ | ០៨០ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៣ | មានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់ឆ្លើយតបតម្រូវការបង្រៀន | ៤.១៤ | ០.៧៤ | ល្អ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៤ | ផ្សព្វផ្សាយពីការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍសាលារៀន ដល់គ្រូបង្រៀន | ៤.៤៩ | ០.៧៤ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ៥ | នាយកបានយកចិត្តទុកដាក់អំពីភាពចាំបាច់នៃទំនុកចិត្តគ្នា និងកិច្ចសហការការងារ | ៤.៣០ | ០.៧៩ | ល្អណាស់ | ៤.៣៣ | ០៥៨ | ល្អណាស់ |
| ៦ | ចែករំលែកលទ្ធផលវាយតម្លៃការបំពេញការងារសាលារៀនឆ្លើយ តបស្តង់ដាសាលារៀនមានប្រសិទ្ធភាពដល់គណៈកម្មការគ្រប់គ្រងសាលា | ៤.៣២ | ០.៧៨ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |

| ល.រ | ការគ្រប់គ្រងរដ្ឋបាល | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ៧ | បានប្រមូលព័ត៌មានជាក់ស្តែងពីលទ្ធផលសិក្សារបស់សិស្ស និងការវាយតម្លៃគ្រូ និងការវាយតម្លៃការអនុវត្តការងាររបស់សាលារៀន | ៤.៣៧ | ០.៧៦ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៨ | បានរៀបចំផែនការបំពេញការងាររបស់បុគ្គលិក | ៤.៣៩ | ០.៧៥ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៩ | បានស្នើការផ្តល់រង្វាន់ពីស្ថាប័នពាក់ព័ន្ធជូនបុគ្គលិកដែលបំពេញការងារបានល្អ | ៣.៨៩ | ០.៨២ | ល្អ | ៤.០០ | ០.០០ | ល្អ |
| ១០ | មានកិច្ចសហការល្អ ជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន | ៤.៤២ | ០.៧៣ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ១១ | មានការរៀបចំ កម្មវិធីជួបជុំរវាងសហគមន៍ និងសាលារៀន | ៤.៥៧ | ០.៧១ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ១២ | ផ្តល់តួនាទីសំខាន់ៗដល់ គ្រូបង្រៀន និងអាណាព្យាបាលសិស្សចូលរួមកសាងផែនការអភិវឌ្ឍ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន | ៤.៣៤ | ០.៧៣ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ១៣ | មានការផ្តល់ព័ត៌មានជាប្រចាំស្តីពីការពេញចិត្តការគ្រប់គ្រង និងសំណូមពរ | ៤.១០ | ០.៨៥ | ល្អ | ៣.៦៧ | ១.១៥ | ល្អបង្គួរ |
| សរុប | | ៤.២៩ | ០.៧៧ | ល្អណាស់ | ៤.៤៦ | ០.៣៦ | ល្អណាស់ |

តារាង៤.២ ទិន្នន័យទទួលបានពីគ្រូបង្រៀនបានបង្ហាញថា ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី លើការគ្រប់គ្រងរដ្ឋបាលបិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.២៩)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "មានការរៀបចំ កម្មវិធីជួបជុំរវាងសហគមន៍ និងសាលារៀន" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៥៧)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "បានស្នើការផ្តល់រង្វាន់ពីស្ថាប័នពាក់ព័ន្ធជូនបុគ្គលិកដែលបំពេញការងារបានល្អ" ក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៨៩)។

គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យពីភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី លើការគ្រប់គ្រង រដ្ឋបាល បិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៤៦)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតមានចំនួន ៣ សូចនាករគឺ៖ "ផ្សព្វផ្សាយពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ដល់គ្រូបង្រៀន" "មានកិច្ចសហការល្អ ជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន" និង"មានការរៀបចំ កម្មវិធីជួបជុំរវាងសហគមន៍ និងសាលារៀន" បិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៥.០០) ស្មើៗគ្នា។ សូចនាករទទួលបានពិន្ទុទាបបំផុតគឺ "មានការផ្តល់ព័ត៌មានជាប្រចាំស្តីពីការពេញចិត្តការគ្រប់គ្រង និងសំណូមពរ" បិតក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគពិន្ទុ=៣.៦៧)។

**តារាង៤.៣៖ ការគ្រប់គ្រងហិរញ្ញវត្ថុ**

| ល.រ | ការគ្រប់គ្រងហិរញ្ញវត្ថុ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | សាលារៀនបានបង្កើតគណៈកម្មការគ្រប់គ្រងថវិកាសាលារៀន | ៤.៥៦ | ០.៧០ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ២ | បានបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុជូនគណៈកម្មការគ្រប់គ្រងសាលារៀន | ៤.៣៧ | ០.៧៨ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៣ | បានផ្សព្វផ្សាយពីរបាយកាណ៍ ការគ្រប់គ្រងហិរញ្ញវត្ថុដល់ភាគីពាក់ព័ន្ធជាប្រចាំ | ៤.២៦ | ០.៧៧ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |

| ល.រ | ការគ្រប់គ្រងហិរញ្ញវត្ថុ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ៤ | នាយកបានប្រើប្រាស់ធនធានអស់លទ្ធភាព និងមានលទ្ធភាពកៀរគរធនធានសម្ភារៈ និងថវិកាសម្រាប់អភិវឌ្ឍសាលារៀន | ៤.៤៩ | ០.៧១ | ល្អណាស់ | ៤.០០ | ០.០០ | ល្អ |
| ៥ | បានរៀបចំផែនការកែលម្អសាលា និងថវិកាសាលារៀន | ៤.៥២ | ០.៧០ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៦ | នាយកបានចូលរួមក្នុងការស្វែងរកមូលនិធិសម្រាប់សាលារៀនក្នុងការចូលរួមការងារសង្គម | ៤.៥០ | ០.៧២ | ល្អណាស់ | ៣.៦៧ | ០.៥៨ | ល្អបង្គួរ |
| ៧ | នាយកបានស្វែងរកមូលនិធិសម្រាប់ឧបត្ថមដល់បុគ្គលិកអប់រំជួបការលំបាក | ៣.៨៩ | ១.០០ | ល្អ | ៤.០០ | ០.០០ | ល្អ |
| ៨ | នាយកលះបង់ខ្ពស់ដើម្បីការពារប្រយោជន៍របស់លោកគ្រូ-អ្នកគ្រូ | ៤.២៨ | ០.៧៨ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៩ | តម្រូវការសម្ភារៈឧបទេស ត្រូវបានឆ្លើយតបទាន់ពេលវេលា | ៣.៩៨ | ០.៨៤ | ល្អ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| សរុប | | ៤.៣២ | ០.៧៨ | ល្អណាស់ | ៤.៣៣ | ០.៤៥ | ល្អណាស់ |

តារាង៤.៣ ទិន្នន័យទទួលបានពីគ្រូបង្រៀនបានបង្ហាញថា ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី លើការគ្រប់គ្រងហិរញ្ញវត្ថុឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៣២)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "សាលារៀនបានបង្កើតគណៈកម្មការគ្រប់គ្រងថវិកាសាលារៀន" ឋិតក្នុង

កម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៥៦)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "នាយកបានស្វែងរកមូលនិធិសម្រាប់ឧបត្ថមដល់បុគ្គលិកអប់រំជួបការលំបាកឋិតក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៨៩)។

គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យពីភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី លើការគ្រប់គ្រងហិរញ្ញវត្ថុ ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៣៣)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតមានចំនួន ៤ សូចនាករគឺះ "សាលារៀនបានបង្កើតគណៈកម្មការគ្រប់គ្រងថវិកាសាលារៀន" "បានបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុជូនគណៈកម្មការគ្រប់គ្រងសាលារៀន" "បានផ្សព្វផ្សាយពីរបាយកាណ៍ ការគ្រប់គ្រងហិរញ្ញវត្ថុដល់ភាគីពាក់ព័ន្ធជាប្រចាំ" និង"នាយកលះបង់ខ្ពស់ដើម្បីការពារប្រយោជន៍របស់លោកគ្រូ-អ្នកគ្រូ" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៦៧) ស្មើៗគ្នា។ សូចនាករទទួលបានពិន្ទុទាបបំផុតគឺ "នាយកបានចូលរួមក្នុងការស្វែងរកមូលនិធិសម្រាប់សាលារៀនក្នុងការចូលរួមការងារសង្គម" ឋិតក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគពិន្ទុ=៣.៦៧)។

**តារាង៤.៤៖ ការគ្រប់គ្រងធនធានមនុស្ស**

| ល.រ | ការគ្រប់គ្រងធនធានមនុស្ស | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | នាយកមានសមត្ថភាពក្នុងការប្រើប្រាស់ធនធានបុគ្គលិកប្រកបដោយតម្លាភាព និងមានទំនួលខុសត្រូវខ្ពស់ | ៤.៣០ | ០.៧៨ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ២ | បង្កបរិយាកាសបំពេញការងារ ដោយការពេញចិត្ត និងស្មោះត្រង់ | ៤.៣១ | ០.៧៨ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៣ | នាយកបានលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំដល់បុគ្គលិកនៅក្នុងសាលារៀន | ៤.៤៤ | ០.៨០ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |

| ល.រ | ការគ្រប់គ្រងធនធានមនុស្ស | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ៤ | មិនប្រកាន់បក្សពួក និងរក្សាទុកគ្រូបង្រៀនដែលមានទេពកោសល្យ | ៤.២៤ | ០.៨៦ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៥ | វាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ បង្រៀនដោយផ្អែកលើលទ្ធផលសិក្សារបស់សិស្ស | ៤.៣០ | ០.៨៤ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៦ | រៀបចំផែនការ សម្រាប់អភិវឌ្ឍសមត្ថភាពបុគ្គលិកបង្រៀន | ៤.២៦ | ០.៨១ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៧ | លើកទឹកចិត្តគ្រូបង្រៀនតាមរយៈការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក | ៤.១៧ | ០.៨១ | ល្អ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៨ | ផ្តល់ធាតុចូលទាំងអស់ ដែលជាតម្រូវការរបស់សាលារៀន | ៤.១៨ | ០.៨១ | ល្អ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៩ | វាយតម្លៃថ្នាក់រៀនជាប្រចាំ ដោយផ្តោតលើលទ្ធផលសិក្សារបស់សិស្ស | ៤.២៤ | ០.៧៨ | ល្អណាស់ | ៤.០០ | ០.០០ | ល្អ |
| ១០ | បង្កើតផែនការវាយតម្លៃប្រចាំឆ្នាំសម្រាប់វាយតម្លៃលទ្ធផលការងាររបស់បុគ្គលិក | ៤.៤១ | ០.៧៧ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ១១ | ផ្តល់ការគាំទ្រទាំងសម្ភារៈ និងបច្ចេកទេសដល់គ្រូបង្រៀនក្នុងការអនុវត្តការងារ | ៤.២៨ | ០.៧៧ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ១២ | លើកកម្ពស់គុណវុឌ្ឍិគ្រូតាមរយៈការបង្កើតកម្មវិធីបណ្តុះបណ្តាលនានាក្នុងសាលា | ៤.៣៤ | ០.៧៨ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |

| ល.រ | ការគ្រប់គ្រងធនធានមនុស្ស | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១៣ | ជម្រុញឲ្យមានការបង្កើតកម្មវិធីបណ្តុះបណ្តាល បន្ថែមដល់សិស្សរៀនយឺត | ៤.៣៤ | ០.៨០ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| សរុប | | ៤.២៩ | ០.៨០ | ល្អណាស់ | ៤.៤៦ | ០.៤៩ | ល្អណាស់ |

តារាង៤.៤ ទិន្នន័យទទួលបានពីគ្រូបង្រៀនបានបង្ហាញថា ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី លើការគ្រប់គ្រង ធនធានមនុស្សឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.២៩)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "នាយកបានលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈជាប្រចាំដល់បុគ្គលិកនៅក្នុងសាលារៀន" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៤៤)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "លើកទឹកចិត្តគ្រូបង្រៀនតាមរយៈការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក" ឋិតក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.១៧)។

គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យពីភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី លើការគ្រប់គ្រង ធនធានមនុស្ស ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៤៦)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺៈ "ជម្រុញឱ្យមានការបង្កើតកម្មវិធីបណ្តុះបណ្តាល បន្ថែមដល់សិស្សរៀនយឺត" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៥.០០)។ សូចនាករទទួលបានពិន្ទុទាបបំផុតគឺ "វាយតម្លៃថ្នាក់រៀនជាប្រចាំដោយផ្តោតលើលទ្ធផលសិក្សារបស់សិស្ស ឋិតក្នុងកម្រិត "ល្អបង្គួរ" (មធ្យមភាគពិន្ទុ=៤.០០)។

### ៤.២.២ ការអនុវត្តគោលនយោបាយអប់រំស្ទែម

### ក. ទិន្នន័យបរិមាណវិស័យ

` គោលនយោបាយអប់រំស្ទែមត្រូវបានដាក់ឱ្យអនុវត្តនៅសាលាចំណោះទូទៅ។ ការសិក្សានៅសាលារៀនជំនាន់ថ្មី ផ្តោតលើថ្នាក់វិទ្យាសាស្ត្រផ្សារភ្ជាប់ទៅនឹងការអនុវត្តគោលនយោបាយអប់រំស្ទែមដោយបានផ្តល់សម្ភារៈ និងបច្ចេកទេគាំទ្រដល់ដំណើរការរៀន និងបង្រៀនដើម្បីលើកកម្ពស់ចំណោះដឹងរបស់សិស្សផ្នែកវិទ្យាសាស្ត្រត្រៀមរៀនជំនាញស្ទែមនៅថ្នាក់ឧត្តមសិក្សាដែលជាធនធានមនុស្សចាំបាច់ឆ្លើយតបទៅនឹងបរិបទក្នុងប្រទេស តំបន់ និងសកលលោក។ តារាងទិន្នន័យខាងក្រោមនេះបង្ហាញពីមធ្យមភាគពិន្ទុសូចនាករនីមួយៗដើម្បីឆ្លុះបញ្ចាំងពីការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី។

**តារាង៤.៥៖ ការអនុវត្តគោលនយោបាយអប់រំស្ទែម**

| ល.រ | ការអនុវត្តគោលនយោបាយអប់រំស្ទែម | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | នាយកបានប្រើប្រាស់ធនធានដើម្បីលើកទឹកចិត្ត និងជួយគាំទ្រដល់ការបង្កើតថ្មី | ៤.៣២ | ០.៧៩ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ២ | នាយកបានរៀបចំមន្ទីពិសោធន៍ និងអនុវត្តលើប្រព័ន្ធ ICT សម្រាប់ការរៀន និងបង្រៀន | ៤.៣៦ | ០.៧៤ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ៣ | នាយកបានជ្រាបការអនុវត្តគោលនយោបាយអប់រំស្ទែម នៅក្នុងសាលារៀនដើម្បីចូលរួមកសាងសង្គមឌីជីថល | ៤.៤៨ | ០.៦៧ | ល្អណាស់ | ៤.០០ | ០.០០ | ល្អ |
| ៤ | នាយកបានផ្តល់ឱកាសឱ្យបុគ្គលិកនៅក្នុងសាលារៀនចែករំលែកគំនិតនវានុវត្តន៍ និងគំនិតច្នៃប្រឌិតសម្រាប់អភិវឌ្ឍសាលារៀន | ៤.៤៨ | ០.៧១ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៥ | នាយកបានចូលរួមក្នុងកិច្ចការកសាងសហគមន៍វិជ្ជាជីវៈនៅក្នុងសាលារៀន | ៤.៤១ | ០.៧២ | ល្អណាស់ | ៤.០០ | ១.០០ | ល្អ |

| ល.រ | ការអនុវត្តគោលនយោបាយអប់រំស្នែម | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ៦ | នាយកបានសម្របសម្រួលការងារភាពជាដៃគូជាមួយសកម្មភាពមុខវិជ្ជាស្នែម និងសហគមន៍ | ៤.៤៤ | ០.៦៨ | ល្អណាស់ | ៤.០០ | ០.០០ | ល្អ |
| ៧ | នាយកបានធ្វើការសិក្សាស្រាវជ្រាវជាប្រចាំទៅលើបញ្ហាប្រឈមរបស់សាលារៀនទៅតាមត្រីមាសនីមួយៗនៃឆ្នាំសិក្សា | ៤.៣៨ | ០.៧៩ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៨ | នាយកមានភាពបត់បែន និងវៃឆ្លាតក្នុងការដោះស្រាយបញ្ហាតាមលក្ខណៈវិទ្យាសាស្ត្រ (ធ្វើអង្កេត សាកសួរ យោងតាមសម្មតិកម្ម ដើម្បីធ្វើការសម្រេចចិត្ត) | ៤.៤៦ | ០.៧១ | ល្អណាស់ | ៤.០០ | ១.០០ | ល្អ |
| ៩ | នាយកសាលា បានពិនិត្យ និងតាមដានការអនុវត្តម៉ោងពិសោធន៍តាមកាលវិភាគមុខវិជ្ជាបង្រៀនច្បាស់លាស់ | ៤.២២ | ០.៧៦ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ១០ | នាយកសាលា បានធ្វើបច្ចុប្បន្នភាពនៃមុខងាររបស់បន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ | ៤.២៩ | ០.៧១ | ល្អណាស់ | ៤.០០ | ១.០០ | ល្អ |
| ១១ | នាយកផ្តោតការយកចិត្តទុកដាក់លើរាល់បញ្ហាដែលជាកង្វល់របស់លោកគ្រូ-អ្នកគ្រូមុខវិជ្ជាស្នែម | ៤.៣៤ | ០.៧៣ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ១២ | នាយកមានការគិត និងវិភាគបែបយុទ្ធសាស្ត្រក្នុងការដោះស្រាយបញ្ហា | ៤.៣១ | ០.៧១ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ១៣ | នាយកសាលា ផ្តល់ឱកាសឱ្យគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | ៤.៤៤ | ០.៧១ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |

| ល.រ | ការអនុវត្តគោលនយោបាយអប់រំស្នែម | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១៤ | នាយកសាលា បានធ្វើផែនការសម្រាប់ការបណ្តុះបណ្តាលគ្រូ ទាក់ទងនឹងការប្រើប្រាស់សម្ភារៈក្នុងបន្ទប់ពិសោធន៍ | ៤.៣៤ | ០.៧៦ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ១៥ | នាយកសាលា បានស្វែងរកប្រាក់ចំណូលថវិកា ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍ | ៤.៣៧ | ០.៧៣ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ១៦ | មាននីតិវិធីក្នុងការរក្សាសម្ភារៈដែលខូចក្នុងបន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ | ៤.២៦ | ០.៨១ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ១៧ | នាយកសាលាបានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ច | ៤.៤៤ | ០.៧៥ | ល្អណាស់ | ៤.០០ | ១.០០ | ល្អ |
| ១៨ | នាយកសាលា បានត្រួតពិនិត្យជាប្រចាំលើបញ្ជីសម្ភារៈក្នុងបន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ | ៤.១៧ | ០.៧៩ | ល្អ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ១៩ | នាយកសាលា ចូលរួមលើកកម្ពស់ ការប្រើប្រាស់បន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រស្របតាមកម្មវិធីសិក្សា | ៤.៤០ | ០.៧៥ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ២០ | បន្ទប់ពិសោធន៍ មានបរិយាកាសល្អ ធ្វើឱ្យសិស្សងាយស្រួលសិក្សា | ៤.៣០ | ០.៨១ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ២១ | ពិនិត្យការប្រើប្រាស់វិធីសាស្ត្របង្រៀនពិសោធន៍ដោយឡែក ពីការបង្រៀនក្នុងថ្នាក់ | ៤.៣០ | ០.៧៧ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |

| ល.រ | ការអនុវត្តគោលនយោបាយអប់រំស្នែម | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ២២ | បានប្រើប្រាស់បច្ចេកវិទ្យា ICT ក្នុងការបង្រៀន និងរៀន | ៤.៥៨ | ០.៧១ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ២៣ | គ្រូបង្រៀន បង្រៀនត្រូវតាមឯកទេសដែលបានបណ្តុះបណ្តាល | ៤.៥៧ | ០.៦៦ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ២៤ | មានទស្សនៈវិស័យលើកកម្ពស់គុណភាពបង្រៀនវិទ្យាសាស្ត្រ | ៤.៥១ | ០.៦៦ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ២៥ | គ្រូចេះប្រើប្រាស់សម្ភារៈឧបទេស និងឧបករណ៍ពិសោធន៍ត្រឹមត្រូវ | ៤.៤២ | ០.៦៩ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ២៦ | បានច្នៃប្រឌិតផលិតសម្ភារៈឧបទេសបម្រើឱ្យស្នែម | ៤.៣០ | ០.៦៧ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ២៧ | សម្ភារៈបម្រើឱ្យស្នែម ទំនើប និងមានគុណភាពខ្ពស់ | ៤.១៨ | ០.៨០ | ល្អ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ២៨ | នាយកសាលា បានបង្កើតវគ្គសិក្ខាសាលាដល់គ្រូតាមមុខវិជ្ជាដែលត្រូវបង្រៀន | ៤.២២ | ០.៨០ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ២៩ | នាយកសាលា លើកទឹកចិត្តសិស្ស ដោយជំរុញបរិបទនៃការសិក្សាដោយខ្លួនឯង | ៤.៤៦ | ០.៧០ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៣០ | ទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ | ៣.៨៦ | ០.៩៥ | ល្អ | ៤.០០ | ១.០០ | ល្អ |

| ល.រ | ការអនុវត្តគោលនយោបាយអប់រំស្វែម | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ៣១ | តាំងពិពណ៌ស្នាដៃសិក្សា និងការប្រកួតប្រជែងរបស់សិស្ស | ៤.៦៨ | ០.៦២ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ៣២ | មានការចូលរួមអនុវត្តជាក់ស្តែងរបស់សិស្សក្នុងដំណើរការពិសោធន៍ | ៤.៥០ | ០.៧២ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៣៣ | សិស្សមានឆន្ទៈ និងចង់ស្វែងយល់មេរៀនក្នុងម៉ោងពិសោធន៍ | ៤.៤៧ | ០.៦៧ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| សរុប | | ៤.៣៧ | ០.៧៤ | ល្អណាស់ | ៤.៤១ | ០.៥៧ | ល្អណាស់ |

តារាង៤.៥ ទិន្នន័យទទួលបានពីគ្រូបង្រៀនបានបង្ហាញថា ការអនុវត្តគោលនយោបាយអប់រំស្វែម នៅសាលារៀនជំនាន់ថ្មី ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៣៧)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "តាំងពិពណ៌ស្នាដៃសិក្សា និងការប្រកួតប្រជែងរបស់សិស្ស" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៦៨)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "ទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ" ឋិតក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៣.៨៦)។

គណៈគ្រប់គ្រងបានផ្តល់ទិន្នន័យពីការអនុវត្តគោលនយោបាយអប់រំស្វែម នៅសាលារៀនជំនាន់ថ្មី ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៤១)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតមានចំនួន ២ គឺៈ "នាយកបានរៀបចំមន្ទីរពិសោធន៍ និងអនុវត្តលើប្រព័ន្ធICTសម្រាប់ការរៀន និងបង្រៀន" និង "តាំងពិពណ៌ស្នាដៃសិក្សា និងការប្រកួតប្រជែងរបស់សិស្ស" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៥.០០)ស្មើៗ

គ្នា។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតមានចំនួន ៧ សូចនាករគឺ "នាយកបានជ្រាបការអនុវត្តគោលនយោបាយអប់រំស្នែម នៅក្នុងសាលារៀនដើម្បីចូលរួមកសាងសង្គមឌីជីថល" "នាយកបានចូលរួមក្នុងកិច្ចការកសាងសហគមន៍វិជ្ជាជីវៈនៅក្នុងសាលារៀន" "នាយកបានសម្របសម្រួលការងារភាពជាដៃគូជាមួយសកម្មភាពមុខវិជ្ជាស្នែម និងសហគមន៍" "នាយកមានភាពបត់បែន និងវៃឆ្លាតក្នុងការដោះស្រាយបញ្ហាតាមលក្ខណៈវិទ្យាសាស្ត្រ (ធ្វើអង្កេត សាកសួរ យោងតាមសម្មតិកម្ម ដើម្បីធ្វើការសម្រេចចិត្ត)" "នាយកសាលាបានធ្វើបច្ចុប្បន្នភាពនៃមុខងាររបស់បន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ" "នាយកសាលាបានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ច" និង"ទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ" ឋិតក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុ=៤.០០) ស្មើៗគ្នា។ ឆ្លងតាមលទ្ធផលនេះបង្ហាញថាការអនុវត្តគោលនយោបាយអប់រំស្នែម នៅសាលារៀនជំនាន់ថ្មី មានភាពល្អប្រសើរ។

## ខ. ទិន្នន័យគុណវិស័យ

អ្នកសិក្សាស្រាវជ្រាវ សម្ភាសន៍អ្នកចូលរួម ដោយជ្រើសរើសទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ ដែលក្នុងនោះ មានទាំងកម្រិតអ្នកអនុវត្តនៅសាលារៀន និងកម្រិតអ្នកយល់ពីខ្លឹមសារគោលនយោបាយអប់រំ។ ដំណើរការសម្ភាសន៍ ត្រូវបានអនុវត្តទៅតាមនីតិវិធីដែលបានកំណត់ច្បាស់លាស់។ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់ពេលវេលា ចន្លោះពី៣០នាទី ទៅ៤០នាទី ក្នុងមួយកិច្ចសម្ភាសន៍។ ការសម្ភាសន៍ត្រូវបានរៀបចំឡើងដោយផ្ទាល់ ឬតាមរយៈអនឡាញ អាស្រ័យលើស្ថានភាពរបស់អ្នកចូលរួមផ្តល់ទិន្នន័យគុណវិស័យ។ អ្នកសិក្សាស្រាវជ្រាវ បានសម្ភាសន៍អ្នកចូលរួមផ្តល់ទិន្នន័យគ្រប់ចំនួន៩នាក់ មកពី៥ស្ថាប័នផ្សេងៗគ្នា ក្នុងក្រសួងអប់រំ យុវជន និងកីឡា។

តាមរយៈទិន្នន័យដែលទទួលបានពីការសម្ភាសន៍ជាមួយអ្នកចូលរួមផ្តល់ទិន្នន័យគុណវិស័យ លើភាពជាអ្នកដឹកនាំរបស់នាយកសាលារៀនជំនាន់ថ្មី មានខ្លឹមសារគោលសំខាន់ៗ ដូចខាងក្រោម៖

‶....សាលារៀនជំនាន់ថ្មី គឺបានអនុវត្តតាមកម្មវិធីសិក្សារបស់ក្រសួង។ គ្រូបង្រៀនបានប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែប ដើម្បីជំរុញលទ្ធផលសិក្សារបស់សិស្សឱ្យបានល្អប្រសើរ ព្រមទាំងមានទម្រង់វង្វាយតម្លៃលទ្ធផលសិក្សាមុនគ្រាហ៍ និងក្រោយការសិក្សាផងដែរ...″

(KI#1, 2, 4, 6, 7, 8, 9)

‶......សម្រាប់ការគ្រប់គ្រងរដ្ឋបាលនៅសាលារៀនជំនាន់ថ្មី បានអនុវត្តស្របតាមបទដ្ឋានគតិយុទ្ធដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងការរៀនរបស់សិស្ស ការបង្រៀនរបស់គ្រូ ទំនាក់ទំនងល្អជាមួយសហគមន៍ អណាព្យាបាល......″

(KI#1, 3, 4, 5, 7, 8, 9)

‶....លទ្ធផលសិក្សារបស់សិស្ស បានឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃការគ្រប់គ្រង ដំណើរការបង្រៀន និងការពិនិត្យតាមដាន និងវង្វាយតម្លៃរបស់គណៈគ្រប់គ្រងជាប់ជាប្រចាំផងដែរ។ សិស្សកសាងបានសមត្ថភាពចំណេះដឹង បំណិន និងឥរិយាបថ ព្រមទាំងមានអត្រាខ្ពស់លើការបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា និងការបណ្តុះបណ្តាលបច្ចេកទេសផ្សេងៗ...″

(KI#3, 4, 5, 7, 9)

‶....ឥរិយាបថនៃការចូលរួមរបស់បុគ្គលិក ដើម្បីឈានទៅសម្រេចបាន គោលដៅរបស់សាលារៀន គឺអាចឆ្លុះបញ្ចាំងពីតម្លាភាព និងគណនេយ្យភាពរបស់នាយកសាលា។ គណៈគ្រប់គ្រងអាចកៀរគរធនធានគាំទ្រពីសហគមន៍បាន ជាចំណុចដែលបង្ហាញពីភាពជឿជាក់លើការងារដឹកនាំសាលារៀន...″

(KI#1, 2, 3, 4, 5, 6, 7, 9)

‶....ការរក្សាទុកគ្រូបង្រៀនល្អ គឺជាការរក្សាបាននូវធនធានដ៏រឹងមាំមួយ ជួយទ្រទ្រង់ដល់ដំណើរបណ្តុះបណ្តាលនៅសាលារៀនជំនាន់ថ្មី ប្រកបដោយសក្តានុពល។ កង្វះធនធានគ្រូបង្រៀន នោះការអនុវត្តកម្មវិធីសិក្សាក៏មិនអាចប្រព្រឹត្តទៅបានដែរ...″

( KI#1, 3, 5, 6, 8 )

តាមរយៈទិន្ន័យដែលទទួលបានពីការសម្ភាសន៍ជាមួយអ្នកចូលរួមផ្តល់ទិន្នន័យគុណវិស័យ លើការអនុវត្តគោលនយោបាយអប់រំស្នែម មានខ្លឹមសារគោលសំខាន់ៗ ដូចខាងក្រោមៈ

"....សាលារៀនជំនាន់ថ្មីបានអនុវត្តតាមគោលនយោបាយអប់រំស្ទែម មានបំពាក់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រការអប់រំស្ទែម រៀបចំសម្ភារៈ និងសកម្មភាពនានាលើការអប់រំស្ទែម ដើម្បីឱ្យសិស្សទទួលបាននូវចំណេះដឹង ឆ្លើយតបការអប់រំសតវត្សទី២១...."

( KI#1, 2, 4, 8 )

"....តាមរយៈបរិក្ខារូបវន្តគាំទ្រ គ្រូបង្រៀនអាចប្រើប្រាស់បន្ទប់ពិសោធន៍ដើម្បីបង្រៀនមេរៀនសិស្សអាចអនុវត្តផ្ទាល់ជាមួយកុំព្យូទ័រលើមុខវិជ្ជាICT និងប្រើប្រាស់ម៉ាស៊ីនបញ្ចាំងស្លាយពេលប្រជុំបច្ចេកទេស..."

( KI#1, 2, 4, 8 )

"...បរិយាកាសនៃការសិក្សា បានបង្កលទ្ធភាពឱ្យសិស្សចេះសិក្សាដោយខ្លួនឯង តាមរយៈការដាក់កិច្ចការផ្ទះរបស់គ្រូ និងជំរុញការប្រើប្រាស់កុំព្យូទ័រដើម្បីរុករកឯកសារនានា បម្រើដល់ការសិក្សារៀនសូត្រ..."

( KI#3,5,6,7,9 )

"....សាលារៀនជំនាន់ថ្មីបានបញ្ជ្រាបការអនុវត្តគោលនយោបាយអប់រំស្ទែម តាមរយៈការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ពង្រឹងការអនុវត្តកម្មវិធិសិក្សា បែងចែកកាលវិភាគតាមនិយាមគ្រូបង្រៀន បង្កបរិយាកាសសិក្សារីករាយ និងជំរុញការសិក្សាស្រាវជ្រាវ ព្រមទាំងបានចូលរួមជាមួយគម្រោងនានាសំដៅលើកទឹកចិត្តសិស្សឱ្យចូលរួមប្រកួតប្រជែងមុខវិជ្ជាវិទ្យាសាស្រ្ត..."

( KI#1, 4, 6, 7 )

"....សាលារៀនជំនាន់ថ្មីបានប្រើប្រាស់បច្ចេកវិទ្យាទាំងក្នុងកិច្ចការងាររដ្ឋបាល និងការងារបង្រៀនដែលផ្តោតលើមុខវិជ្ជាវិទ្យាសាស្ត្រ លើកកម្ពស់ការគិត និងវិភាគស៊ីជម្រៅលើលក្ខណៈវិទ្យាសាស្ត្រ សំដៅកសាងធនធានមនុស្សឱ្យក្លាយជាពលរដ្ឋឌីជីថល ក្នុងសង្គមឌីជីថល..."

(KI#2, 3, 5, 9)

## ៤.៣ ពិភាក្សាលើទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី

ភាពជាអ្នកដឹកនាំរបស់នាយកសាលាល្អ គឺអាចឆ្លុះបញ្ចាំងបានតាមរយៈការប្រាស្រ័យទាក់ទងល្អ និងកិច្ចសហការល្អជាមួយភាគីពាក់ព័ន្ធក្នុងដំណើរការសាលារៀនដែលជាកត្តាសំខាន់បំផុតនាំឱ្យសម្រេចបានការងារក្រុម និងជំរុញប្រសិទ្ធភាពការបង្រៀន និងរៀន។ ភាពជាអ្នកដឹកនាំក្នុងសាលារៀន ផ្តោតសំខាន់ទៅលើការការកំណត់គោលដៅដែលសាលាត្រូវសម្រេចបាន ការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិបន្ទាប់មកធ្វើការសម្រេចចិត្តលើការបំពេញការងារប្រចាំថ្ងៃ នៅក្នុងសាលារៀនដើម្បីសម្រេចបានតាមផែនការ និងចំណុចដៅដែលបានកំណត់។ ការអនុវត្តគោលនយោបាយអប់រំ គឺទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងសាលារៀន ទើបបានអាចសម្រេចបានតាមផែនការប្រតិបត្តិប្រចាំឆ្នាំ និងគោលដៅរបស់សាលារៀន។

**តារាង៤.៦៖ ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី**

| ល.រ | សូចនាករ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុប | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | | |
| ១ | ការគ្រប់គ្រងការបង្រៀន និងរៀន | ៤.៤៧ | ០.៦៩ | ល្អណាស់ | ៤.៦៤ | ០.៣១ | ល្អណាស់ | ៤.៥៥ | ល្អណាស់ |

| ល.រ | សូចនាករ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុប | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | | |
| ២ | ការគ្រប់គ្រងរដ្ឋបាល | ៤.២៩ | ០.៧៧ | ល្អណាស់ | ៤.៤៦ | ០.៣៦ | ល្អណាស់ | ៤.៣៧ | ល្អណាស់ |
| ៣ | ការគ្រប់គ្រងហិរញ្ញវត្ថុ | ៤.៣២ | ០.៧៨ | ល្អណាស់ | ៤.៣៣ | ០.៤៥ | ល្អណាស់ | ៤.៣៣ | ល្អណាស់ |
| ៤ | ការគ្របគ្រងធនធានមនុស្ស | ៤.២៩ | ០.៨០ | ល្អណាស់ | ៤.៤៦ | ០.៤៩ | ល្អណាស់ | ៤.៣៨ | ល្អណាស់ |
| | សរុប | ៤.៣៤ | ០.៧៦ | ល្អណាស់ | ៤.៤៧ | ០.៤០ | ល្អណាស់ | ៤.៤១ | ល្អណាស់ |

តាមតារាង៤.៦ បង្ហាញពីទិន្នន័យរួមដែលបានពីគ្រូបង្រៀន និងគណៈគ្រប់គ្រងលើភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៤១) ។ ក្នុងន័យនេះបានបង្ហាញថាទាំងគណៈគ្រប់គ្រង និងគ្រូបង្រៀនយល់ស្របដូចគ្នាលើការអនុវត្តភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី បានល្អណាស់។ តាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកចូលរួមមួយចំនួនបានបង្ហាញឱ្យឃើញថា "ភាពជាអ្នកដឹកនាំរបស់នាយកសាលាសាលារៀនជំនាន់ថ្មី បានអនុវត្តតាមសមាសភាពទាំងបួននៃការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល ដែលមានការគ្រប់គ្រងការបង្រៀន និងរៀនបានខ្ពស់បំផុតក្នុងកម្រិតល្អណាស់ មានការវាយតម្លៃបានត្រឹមត្រូវដើម្បីឆ្លុះបញ្ចាំងចំណុចខ្លាំង និងខ្សោយហើយធ្វើការកែលម្អនិងពង្រឹង ធ្វើឱ្យសិស្សមានការយល់ដឹងស៊ីជម្រៅ មានការគ្រប់គ្រងរដ្ឋបាលបានល្អស្របតាមបទដ្ឋានគតយុត្តិ មានទំនាក់ទំនាក់ល្អជាមួយ សហគមន៍ អជ្ញាធរមូលដ្ឋាន សិស្ស គ្រូ អាណាព្យាបាលក្នុងការ

អភិវឌ្ឍសាលា ការគ្រប់គ្រងហិរញ្ញវត្ថុមានតម្លាភាព និងគណនេយ្យភាព និងមានការប្រើប្រាស់ធនធានបុគ្គលិក ផែនការអភិវឌ្ឍសមត្ថភាព និងលើកទឹកចិត្តបុគ្គលិកប្រកបដោយតម្លាភាព និងការទទួលខុសត្រូវខ្ពស់" ។ សូចនាករដែលមានគម្លាតនៃមធ្យមពិន្ទុតូចបានអនុវត្តការគ្រប់គ្រងការរៀន និងបង្រៀនបានល្អជាងគេក្នុងចំណោមសូចនាករទាំងបួន។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតពីគ្រូបង្រៀនគឺ ការគ្រប់គ្រងរដ្ឋបាល និងការគ្រប់គ្រងធនធានមនុស្ស។ ចំណែកទិន្នន័យដែលបានពីគណៈគ្រប់គ្រងសូចនាករដែលទទួលពិន្ទុទាបបំផុតគឺការគ្រប់គ្រងហិរញ្ញវត្ថុ ។

នៅក្នុងភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀនជំនាន់ថ្មី បានអនុវត្តលើការបង្រៀន និងរៀនបានល្អ។ ការបង្រៀន និងរៀនគឺជាសកម្មភាពស្នូលមួយដែលមានឥទ្ធិពលដោយផ្ទាល់លើលទ្ធផលសិក្សារបស់សិស្ស។ ក្នុងការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ ធនធានមនុស្សគឺជាការគាំទ្រដល់ដំណើរការបង្រៀន និងរៀន។ ក្នុងការផ្ទៀងផ្ទាត់រវាងទិន្នន័យរបស់គណៈគ្រប់គ្រង និងគ្រូបង្រៀន មានសូចនាករចំនួន ៣ ដែលមានកម្រិតពិន្ទុនៅទាបជាងការគ្រប់គ្រងការបង្រៀន និងរៀនគឺការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្ស។ ទោះបីជាសូចនាករទាំងបីនេះទទួលបានពិន្ទុកម្រិតទាបជាងសូចនាករផ្សេងទៀត ប៉ុន្តែស្ថិតនៅក្នុងកម្រិត "ល្អណាស់" ដូចសូចនាករដែលមានពិន្ទុខ្ពស់បំផុតដែរ បានន័យថានាគណៈគ្រប់គ្រងខិតខំយកចិត្តទុកដាក់ក្នុងការដឹកនាំគ្រប់គ្រងសាលារៀន។ ដូចនេះគណៈគ្រប់គ្រងសាលាត្រូវខិតខំបន្តអនុវត្តបន្ថែមទៀត ជាពិសេសសូចនាករដែលទទួលបានពិន្ទុទាបបំផុតដើម្បីទទួលបានកម្រិត "ល្អណាស់" ដូចគ្នា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងសាលាចូលរួមលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងនៅក្នុងបាឋកថានៅការប្រារព្ធទិវាគ្រូបង្រៀនថា "ភាពជាអ្នកដឹកនាំសាលារៀនគឺជាគន្លឹះនៃកំណែទម្រង់សាលារៀន។

**តារាង៤.៧៖ សរុបរួមការអនុវត្តគោលនយោបាយអប់រំស្នែម**

| បរិយាយ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុប | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|---|---|
| | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | | |
| ការអនុវត្តគោលនយោបាយស្នែម | ៤.៣៧ | ០.៧៤ | ល្អណាស់ | ៤.៤១ | ០.៥៧ | ល្អណាស់ | ៤.៣៩ | ល្អណាស់ |

តាមតារាង៤.៧ ទិន្នន័យដែលបានពីគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលារៀនជំនាន់ថ្មី លើការអនុវត្តគោលនយោបាយអប់រំស្នែម ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៣៩)។ ក្នុងន័យនេះបង្ហាញថា ទាំងគណៈគ្រប់គ្រង និងគ្រូបង្រៀនយល់ស្របដូចគ្នាលើការអនុវត្តគោលនយោបាយអប់រំស្នែម នៅសាលារៀនជំនាន់ថ្មី បានល្អណាស់។ តាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកចូលរួមដែលបំពេញការងារពាក់ព័ន្ធទៅនឹងសាលារៀនជំនាន់ថ្មីបានបង្ហាញស្របគ្នាថា "មានការបញ្ជ្រាបការអនុវត្តគោលនយោបាយអប់រំស្នែម បានល្អ ហើយជំរុញសិស្សទទួលបានចំណេះជំនាញសតវត្សរ៍ទី២១"។

**តារាង៤.៨៖ សូចនាករដែលមានមធ្យមពិន្ទុខ្ពស់ និងទាបស្តីពីការអនុវត្តគោលនយោបាយអប់រំស្នែម**

| ល.រ | សូចនាករ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុប | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | | |
| ១ | តាំងពិពណ៌ស្នាដៃសិក្សា និងការប្រកួតប្រជែងរបស់សិស្ស | ៤.៦៨ | ០.៦២ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ | ៤.៨៤ | ល្អណាស់ |

| ល.រ | សូចនាករ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុប | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | | |
| ២ | ទទួលបានរង្វាន់លើកទឹកចិត្ត ពេលរកឃើញរបៀបពិសោធន៍ថ្មីៗ | ៣.៨៦ | ០.៩៥ | ល្អ | ៤.០០ | ១.០០ | ល្អ | ៣.៩៣ | ល្អ |
| | សរុបមធ្យមភាគ | ៤.២៧ | ០.៧៨ | ល្អណាស់ | ៤.៥០ | ០.៥០ | ល្អណាស់ | ៤.៣៨ | ល្អណាស់ |

តាមតារាង៤.៨ បានបង្ហាញពីសូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតស្តីពីការអនុវត្តគោលនយោបាយអប់រំស្ទែម គឺ "តាំងពិពណ៌ស្នាដៃសិក្សាសិស្ស និងការប្រកួតប្រជែងរបស់សិស្ស" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុសរុប=៤.៨៤)។ ក្នុងន័យនេះបង្ហាញពីការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រងក្នុងការជំរុញការអនុវត្តគោលនយោបាយអប់រំស្ទែម ដោយផ្តោតលើការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ បង្កបរិយាកាសដល់សិស្សក្នុងការអនុវត្តជាក់ស្តែង។ ហើយគណៈគ្រប់គ្រងក៏បានខិតខំបង្ហាញលទ្ធផលចំណេះដឹងដែលសិស្សទទួលបានដល់សហគមន៍ និងអាណាព្យាបាលដើម្បីកសាងទំនុកចិត្តរបស់សហគមន៍មកលើការផ្តល់សេវាអប់រំរបស់សាលារៀនជំនាន់ថ្មី ធ្វើឱ្យមានការចូលរួមពីសហគមន៍ និងអាណាព្យាបាលលើដំណើរការសាលារៀន និងជួយសហការណ៍ជាមួយសាលាក្នុងការតាមដាន ជំរុញការសិក្សារបស់កូន និងចូលរួមគាំទ្រដល់ដំណើរការសាលារៀន។ ចំណែកឯសូចនាករដែលទទួលពិន្ទុទាបបំផុតគឺ "ទទួលបានរង្វាន់លើកទឹកចិត្តពេលរកឃើញរបៀបពិសោធន៍ថ្មីៗ" ដែលស្ថិតនៅក្នុងកម្រិត "ល្អ" (មធ្យមភាគពិន្ទុសរុប=៣.៩៣)។ ទោះបីជាសូចនាករទាំងនេះមានមធ្យមពិន្ទុទាបជាងគេប៉ុន្តែស្ថិតនៅក្នុងកម្រិត ល្អ ដែលបង្ហាញពីការខិតខំធ្វើឱ្យមានការអនុវត្តតាមគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មីបានល្អ។ ក្នុងន័យនេះនាយកត្រូវបន្តអនុវត្ត

ទៀតជាពិសេសលើសូចនាករដែលនៅកម្រិតទាបបំផុតដើម្បីជំរុញឱ្យការអនុវត្តគោនយោបាយអប់រំស្នេម នៅសាលានេះកាន់តែមានប្រសិទ្ធភាពល្អព្រមគ្នាលើគ្រប់ផ្នែក។

ឆ្លងតាមការពិភាក្សាទៅលើលទ្ធផលដែលបានពីគណៈគ្រប់គ្រង គ្រូបង្រៀន និងបានពីការសម្ភាសន៍ បញ្ជាក់ថាទិន្នន័យដែលបានមកមានភាពទាក់ទងគ្នា ឬមានការយល់ស្របដូចគ្នាពីគ្រប់ភាគីពាក់ព័ន្ធចំពោះការអនុវត្តគោលនយោបាយអប់រំស្នេម នៅសាលារៀនជំនាន់ថ្មី។ ទាំងនេះបញ្ជាក់ថាទិន្នន័យដែលទទួលបានមានលក្ខណៈវិទ្យាសាស្ត្រ។

**តារាង៤.៩៖ ទិន្នន័យគ្រូបង្រៀន និងគណៈគ្រប់គ្រងស្តីពីទំនាក់ទំនងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេម**

| ល.រ | បរិយាយ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុប | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | | |
| ១ | ភាពជាអ្នកដឹកនាំរបស់នាយក | ៤.៣៤ | ០.៧៦ | ល្អណាស់ | ៤.៤៧ | ០.៤០ | ល្អណាស់ | ៤.៤០ | ល្អណាស់ |
| ២ | ការអនុវត្តគោលនយោបាយអប់រំស្នេម | ៤.៣៧ | ០.៧៤ | ល្អ | ៤.៤១ | ០.៥៧ | ល្អណាស់ | ៤.៣៩ | ល្អ |
| | មធ្យមភាគសរុប | ៤.៣៦ | ០.៧៥ | ល្អណាស់ | ៤.៤៤ | ០.៥៤ | ល្អណាស់ | ៤.៤០ | ល្អណាស់ |

តាមតារាង៤.៩ បង្ហាញពីទិន្នន័យដែលបានពីគ្រូបង្រៀន និងគណៈគ្រប់គ្រងទៅលើភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែមនៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ មានទំនាក់ទំនងគ្នា ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុសរុប=៤.៤០)។

តាមរយៈទិន្នន័យដែលទទួលបានពីការសម្ភាសន៍ បានបង្ហាញថាភាពជាអ្នកដឹកនាំរបស់នាយក ត្រូវតែមានទំនាក់ទំនងជាមួយការអនុវត្តគោលនយោបាយអប់រំស្នែម នៅសាលារៀនជំនាន់ថ្មី ដូចជា៖

"...នាយកសាលា ត្រូវរៀបចំផែនការប្រតិបត្តិសាលារៀន ដោយយកមូលដ្ឋានចេញពីគោលនយោបាយអប់រំ សំដៅពង្រឹងការអនុវត្តកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន សម្ភារៈ បរិយាកាសសិក្សាដែលជំរុញគ្រូ និងសិស្សធ្វើការសិក្សាស្រាវជ្រាវ មានការលើកទឹកចិត្ត និងការវាយតម្លៃលើលទ្ធផលជាទៀងទាត់ហើយបានលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស..."

(KI#2, 4, 6)

"...ការដឹកនាំគ្រប់គ្រងសាលារៀនជំនាន់ថ្មី ត្រូវតែយកគោលនយោបាយអប់រំស្នែម មកអនុវត្តជាសកម្មភាពក្នុងការងារប្រចាំថ្ងៃនៅសាលារៀន ផ្តល់កិច្ចគាំទ្រទាំងសម្ភារៈ និងស្មារតី លើកកម្ពស់ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ជំរុញការកសាងស្នាដៃការងាររបស់គ្រូបង្រៀន និងការប្រកួតប្រជែងស្នាដៃវិទ្យាសាស្ត្ររបស់សិស្ស..."

(KI#1, 3, 7)

ភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែម មានទំនាក់ទំនងគ្នាដោយបានលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងាររបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្ស។ ក្នុងទិវាគ្រូបង្រៀន (ឆ្នាំ ២០២២) **ឯកឧត្តមបណ្ឌិតសភាចារ្យហង់ជួន ណារ៉ុន** បានលើកឡើងថា "ភាពជាអ្នកដឹកនាំរបស់នាយកនៅសាលារៀន គឺជាកត្តាគន្លឹះក្នុងកំណែទម្រង់សាលារៀន។ គណៈគ្រប់គ្រងត្រូវរៀបចំលក្ខខណ្ឌឱ្យបុគ្គលិកបំពេញការងារប្រកបដោយប្រសិទ្ធភាព ធ្វើឱ្យមានការផ្លាស់ប្តូរវប្បធម៌សាលារៀន លើកកម្ពស់គុណ

វឌ្ឍិគ្រូបង្រៀន។ គ្រូបង្រៀនត្រូវមានសមត្ថភាពសមស្របជាមួយកំណែទម្រង់វិស័យអប់រំ និងដើម្បីបំពេញវិជ្ជាជីវៈប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀតក្នុងទិវាគ្រូបង្រៀនពិភពលោក (២០២២) បានលើកប្រធានបទសំខាន់ ទាក់ទងទៅនឹងគុណសម្បត្តិគ្រូបង្រៀន ក្នុងខ្លឹមសារថា "គ្រូបង្រៀនជាបេះដូងនៃកំណែទម្រង់វិស័យអប់រំដើម្បីអភិវឌ្ឍ"។

ក្នុងបរិបទកំណែទម្រង់អប់រំ ការអនុវត្តគោលនយោបាយអប់រំនៅកម្រិតសាលារៀន គឺមានភាពចាំបាច់ដែលមិនអាចខានបាន ឬមើលរំលង ព្រោះបរាជ័យក្នុងការអនុវត្តគោលនយោបាយអប់រំ នាំឱ្យបរាជ័យគោលនយោបាយជាតិ លើការកសាងធនធានមនុស្ស ឆ្លើយតបតម្រូវការឧស្សាហកម្ម ៤.0 ផងដែរ។ នាយកសាលាត្រូវអនុវត្តការងារក្នុងភាពជាអ្នកដឹកនាំដែលអាចបត់បែនបានទៅតាមតម្រូវការរបស់គ្រូបង្រៀន និងបុគ្គលិកអប់រំក្នុងការលើកកម្ពស់ប្រសិទ្ធផលសាលារៀន។ យោងលើទ្រឹស្តីរបស់ Stufflebeam, CIPP model (1985) ផ្តោតលើខ្លឹមសារគោលនៃបរិបទ ធាតុចូល ដំណើរការ និងលទ្ធផល ដែលរួមមាន៖

បរិបទកម្មវិធីសាលារៀនជំនាន់ថ្មី ស្ថិតនៅក្នុងកម្មវិធីកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា។ សាលារៀនជំនាន់ថ្មីមានស្តង់ដានៃការអប់រំខ្ពស់ តាមរយៈការវិនិយោគកញ្ចប់ថវិកា និងផ្តោតទៅលើការពង្រឹងតម្លាភាព និងការទទួលខុសត្រូវដោយការផ្លាស់ប្តូរវិធីគ្រប់គ្រងសាលា ព្រមទាំងការឆ្លើយតបគោលដៅការអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០៣០។ កំណែទម្រង់សាលារៀនជំនាន់ថ្មីបានចាប់ផ្តើមមាននៅឆ្នាំ ២០១៥ ដែលនាយកមានភាពជាអ្នកដឹកនាំតាមការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល មានស្វ័យភាពកម្រិតខ្ពស់ផ្តោតលើការបំពេញការងាររបស់បុគ្គលិកដើម្បីគាំទ្រទៅនឹងគោលដៅរបស់ជាតិក្នុងការធ្វើឱ្យសម្រេចបាននូវការអប់រំប្រកបដោយគុណភាព និងមានភាពពាក់ព័ន្ធ។ ការអនុវត្តកម្មវិធីសិក្សានៅសាលារៀនជំនាន់ថ្មី ផ្តោតលើថ្នាក់វិទ្យាសាស្ត្រ ការសិក្សាមានគុណភាព។ ការបង្រៀនផ្តោតលើភាសាបរទេស គណិតវិទ្យា វិទ្យាសាស្ត្របច្ចេកវិទ្យាផ្សាភ្ជាប់ជាមួយការអនុវត្តគោលនយោបាយអប់រំស្នែម ដោយមានការរៀបចំថ្នាក់រៀន បរិស្ថានសិក្សាការរៀន និងបង្រៀនតាមការអប់រំស្នែម ឆ្លើយតបទៅនឹងបរិបទកំណែទម្រង់សាលារៀនរបស់ក្រសួងអប់រំ ។

នាយកនៅសាលារៀនជំនាន់ថ្មី មានសមត្ថភាពលើបច្ចេកវិទ្យា ភាសាបរទេស និងភាពជាអ្នកដឹកនាំឆ្លើយតបទៅនឹងការប្រែប្រួលនៃបរិបទកំណែទម្រង់ការគ្រប់គ្រងក្នុងវិស័យអប់រំ អនុវត្តគោលនយោបាយអប់រំស្នែម និងបានអនុវត្តតាមក្របខណ្ឌគោលនយោបាយអប់រំ។ ប្រសិនបើនាយកមានភាពជាអ្នកដឹកនាំសាលារៀនបានល្អ តែមិនបានអនុវត្តតាមគោលនយោបាយអប់រំស្នែម ដែលក្រសួងបានដាក់ចេញ ឬ នាយកបានអនុវត្តតាមគោលនយោបាយអប់រំស្នែម តែការដឹកនាំគ្រប់គ្រងសាលារៀនមិនមានប្រសិទ្ធភាពនោះប្រសិទ្ធភាពនៃការបំពេញការងាររបស់គ្រូក៏នៅមានកម្រិតហើយលទ្ធផលសិក្សារបស់ដែលឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍប្រទេសជាតិក៏មិនបានល្អដែរ។ ដូចនេះ ភពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែម ត្រូវតែមានទំនាក់ទំនងគ្នា។

នៅសាលារៀនជំនាន់ថ្មីមានធនធានដែលជាតុចូលគ្រប់គ្រាន់ ធានាបាននូវប្រសិទ្ធភាពនៃការបំពេញការងាររបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្សមានគុណភាពខ្ពស់តាមតម្រូវការ។ នាយកត្រូវធ្វើការត្រួតពិនិត្យតាមដានលើលទ្ធផលដែលទទួលបានទាំងអស់ព្រមទាំងធ្វើការវាយតម្លៃតាមប្រព័ន្ធច្បាស់លាស់លើការបំពេញការងាររបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្សជាប្រចាំដើម្បីឆ្លុះបញ្ចាំងនូវចំណុចខ្លាំង និងចំណុចខ្សោយដើម្បីកែលម្អ ពង្រឹងបន្ថែមទៀត។ នៅក្នុងដំណើរការគ្រប់គ្រងនៅសាលារៀនជំនាន់ថ្មី និងការអនុវត្តគោនយោបាយអប់រំស្នែម ត្រូវការជាតុចូលគ្រប់គ្រាន់ដូចជាធនធានសម្ភារៈ ធនធានគ្រូបង្រៀន ធនធានពេលវេលា និងធនធានថវិការ។ ធនធានសម្ភារៈមានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដូចជាអាគារសិក្សា មន្ទីពិសោធន៍ សម្ភារៈពិសោធន៍តាមមុខវិជ្ជា។ ធនធានគ្រូដែលមានចំណេះដឹងក្នុងការអប់រំស្នែម ដោយបានទទួលការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលជំនាន់ថ្មី និងទទួលបានការអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់ទៅលើចំណេះដឹងមុខវិជ្ជាជីវៈ វិធីសាស្ត្របង្រៀន និងបច្ចេកវិទ្យា។ ធនធានពេលវេលានៅសាលារៀនជំនាន់ថ្មីមានចំនួនម៉ោងសិក្សាច្រើនជាងសាលារៀនធម្មតា ហើយធនធានថវិកាទទួលបានការវិនិយោគច្រើនពីសំណាក់រដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និងកីឡា ដៃគូរអភិវឌ្ឍ និងសហគមន៍។ បើគ្មានជាតុចូលខាងលើនេះទេទោះបីជានាយក

មានការដឹកនាំគ្រប់គ្រងល្អ និងបានកំណត់យកការអនុវត្តគោលនយោបាយអប់រំស្ទែម ក៏ដោយក៏មិនអាចអនុវត្តកម្មវិធីសិក្សា និងដំណើរការដឹកនាំគ្រប់គ្រងសាលាមានប្រសិទ្ធភាពដែរព្រោះខ្វះធនធានដែលជាផ្នែកសំខាន់ហើយមិនអាចលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងារ និងលទ្ធផលសិក្សារបស់សិស្សបានល្អទេ ។

ដំណើរការសាលាជំនាន់ថ្មី ផ្តល់ឱកាសអោយសិស្សស្វ័យសិក្សាដោយខ្លួនឯង។ សហគមន៍បានចូលរួមក្នុងដំណើរការសិក្សា និងការអភិវឌ្ឍសាលារៀន ដើម្បីជំរុញលើកកម្ពស់គុណភាពអប់រំ សំដៅគាំទ្រ សមត្ថភាពប្រកួតប្រជែងជាមួយបណ្តាលប្រទេសមួយចំនួននៅក្នុងតំបន់ និងពិភពលោក។ នៅក្នុងដំណើរការនៅសាលារៀនជំនាន់ថ្មី មានការគាំទ្រទាំងផ្នែករឹង និងផ្នែកទន់។ បានន័យថាមានធនធានសម្ភារៈសម្បូរបែបសម្រាប់ប្រើប្រាស់គាំទ្រដំណើរការសាលារៀន ហើយមានធនធានមនុស្សដែលអាចប្រើសម្ភារៈទាំងនោះគាំទ្រដល់ការដំណើរ ការគ្រប់គ្រងការរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាពដើម្បីសម្រេចបាននូវវត្ថុបំណងមេរៀនដើម្បីឱ្យសិស្សមានការយល់ដឹងស៊ីជម្រៅ និងអាចប្រើប្រាស់បានក្នុងជីវភាពរស់នៅ។ ប្រសិនបើមានធនធានមនុស្សហើយគ្មានសម្ភារៈសម្រាប់ប្រើក៏ដំណើរការបង្រៀន និងរៀនគ្មានប្រសិទ្ធភាពដែរ។ ដូចគ្នានេះដែរប្រសិនបើមានសម្ភារៈតែគ្រូបង្រៀនមិនអាចប្រើបានក៏ដំណើរការបង្រៀន និងរៀនគ្មានប្រសិទ្ធភាពដែរហើយប្រសិនបើគ្មានធនធានមនុស្សដែលមានសមត្ថភាពឆ្លើយតប និងមានសម្ភារៈប្រើប្រាស់គ្រប់គ្រាន់នោះដំណើរការដឹកនាំគ្រប់គ្រងសាលានោះការគ្រប់គ្រងក៏មិនអាចមានប្រសិទ្ធភាពខ្ពស់ដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការបង្រៀន និងរៀន។ ដូចនេះដើម្បីទទួលបានលទ្ធផលល្អត្រូវតែមានភាពជាអ្នកដឹកនាំល្អ ធនធានមនុស្ស និងធនធានសម្ភារៈសមស្របសម្រាប់ដំណើរការសាលារៀនដែលមិនអាចខ្វះមួយណាបានឡើយ។

មានផលជះជាវិជ្ជមានលើប្រសិទ្ធភាពនៃការបំពេញការងាររបស់បុគ្គលិក និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមរយៈការអនុវត្តកម្មវិធីសិក្សាដែលផ្តោតលើការបង្រៀនថ្នាក់វិទ្យាសាស្ត្រដែលមានភាពស្របគ្នានឹងការអនុវត្តការអប់រំស្ទែម ធ្វើឱ្យសិស្សទទួលបាននូវចំណេះដឹងសតវត្សរ៍ទី២១ ត្រៀមសម្រាប់ការរៀនជំនាញស្ទែម នៅថ្នាក់ឧត្តមសិក្សាសម្រាប់បំពេញតម្រូវការវិស័យឧស្សាហកម្មដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និង

បដិវត្តន៍ឧស្សាហកម្ម៤.០។ បរិបទនៅសាលារៀនជំនាន់ថ្មី ឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំ មានធនធានដែលជាតុចូលគ្រប់គ្រាន់ មានដំណើរការសាលារៀនល្អបន្ថែមលើសពីនេះដើម្បីជានាបាននូវប្រសិទ្ធភាពនៃការបំពេញការងាររបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្សមានគុណភាពខ្ពស់តាមតម្រូវការ នាយកត្រូវធ្វើការត្រួតពិនិត្យតាមដានលើលទ្ធផលដែលទទួលបានទាំងអស់ព្រមទាំងធ្វើការវាយតម្លៃតាមប្រព័ន្ធច្បាស់លាស់លើការបំពេញការងាររបស់គ្រូ និងលទ្ធផលសិក្សារបស់សិស្សជាប្រចាំដើម្បីឆ្លុះបញ្ចាំងនូវចំណុចខ្លាំង និងចំណុចខ្សោយដើម្បីកែលម្អ ពង្រឹង បន្ថែមទៀត។ បន្ថែមពីលើនេះត្រូវផ្ទៀងផ្ទាត់លទ្ធផលដែលទទួលបានជាមួយលទ្ធផលថ្នាក់ជាតិថែមទៀតផងដើម្បីធ្វើការវាស់វែងប្រៀបធៀបជាមួយសាលាផ្សេងៗក្នុងប្រទេសកម្ពុជា។ ដូចនេះការផ្ទៀងផ្ទាត់លទ្ធផលពិតជាមានទំនាក់ទំនងជាមួយនឹងភាពដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម ដែលអាចឆ្លុះបញ្ចាំងពីការអនុវត្ត និងធ្វើការពង្រឹងលើចំណុចខ្វះខាតព្រមទាំងធ្វើឱ្យមានការទទួលស្គាល់ជាទូទៅសម្រាប់លទ្ធផលដែលសាលារៀនជំនាន់ថ្មី សម្រេចបាន។ កាលណាការដឹកនាំសាលារៀនឆ្លើយតបទៅនឹងបរិបទនៃកំណែទម្រង់អប់រំ មានធាតុចូលគ្រប់គ្រាន់មានដំណើរការល្អ និងការវាយតម្លៃលទ្ធផលដើម្បីឆ្លុះបញ្ចាំងបានល្អ នាំឱ្យមានការអនុវត្តការបង្រៀន និងរៀន ការអនុវត្តកម្មវិធីសិក្សាបានជោគជ័យនាំឱ្យមានការអនុវត្តគោលនយោបាយអប់រំស្ទែម បានជោគជ័យ និងជះឥទ្ធិពលដល់ភាពជាអ្នកដឹកនាំរបស់នាយកបានល្អ។

ជាលទ្ធផលនៃទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី បានជះឥទ្ធិពលលើប្រសិទ្ធភាពនៃការបំពេញការងាររបស់បុគ្គលិក និងលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សតាមរយៈការអនុវត្តកម្មវិធីសិក្សាដែលផ្តោតលើការបង្រៀនថ្នាក់វិទ្យាសាស្ត្រដែលមានភាពស្របគ្នានឹងការអនុវត្តការអប់រំស្ទែម បរិបទដែលសិស្សស្វ័យសិក្សា ការច្នៃប្រឌិត ចង់ចេះចង់ដឹងឱ្យបានទូលំទូលាយលើចំណេះដឹងដែលគ្រូបានបង្រៀន ធ្វើឱ្យសិស្សទទួលបាននូវចំណេះដឹងសតវត្សរ៍ទី២១

ត្រៀមសម្រាប់ការរៀនជំនាញស្នែម នៅថ្នាក់ឧត្តមសិក្សាសម្រាប់បំពេញតម្រូវការវិស័យឧស្សាហកម្មដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងបដិវត្តន៍ឧស្សាហកម្ម៤.០។

## ៤.៤ ការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ

### ៤.៤.១ ទិន្នន័យបរិមាណវិស័យ

ដើម្បីធ្វើការវាស់ពីកម្រិតនៃការអនុវត្តគោលនយោបាយអប់រំស្ទែម ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនដល់ការបង្រៀនរបស់គ្រូ អ្នកសិក្សាស្រាវជ្រាវបានប្រើសូចនាករចំនួន ១៦។

**តារាង៤.១០៖ ការអនុវត្តគោលនយោបាយអប់រំស្ទែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ**

| ល.រ | ការអនុវត្តគោលនយោបាយអប់រំស្ទែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១ | បានរៀបចំសមត្ថភាពគ្រូបង្រៀនឆ្លើយតបទៅនឹងតម្រូវការអប់រំសតវត្សទី២១ | ៤.៥២ | ០.៦២ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ២ | បានជំរុញគ្រូអនុវត្តតាមគន្លងអាជីពវិជ្ជាជីវៈគ្រូបង្រៀន | ៤.៥២ | ០.៦៣ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៣ | បានអនុវត្តសម្ភារៈឧបទេស ឆ្លើយតបមុខវិជ្ជាស្ទែម នៅក្នុងសាលារៀនដើម្បីចូលរួមកសាងសង្គមឌីជីថល | ៤.៤១ | ០.៧២ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៤ | ផ្តល់កិច្ចគាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាក្នុងដំណើរការបង្រៀន | ៤.៥២ | ០.៦៣ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |

| ល.រ | ការអនុវត្តគោលនយោបាយអប់រំស្ទែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ៥ | បានជំរុញគ្រូ អនុវត្តវិធីសាស្រ្តបង្រៀនថ្មីៗ | ៤.៥៦ | ០.៦៨ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ |
| ៦ | ផ្តល់ឱកាសដល់គ្រូបង្រៀនធ្វើកិច្ចការស្រាវជ្រាវ និងបង្កើតគំនិតនវានុវត្តន៍ | ៤.៥២ | ០.៦២ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៧ | គ្រូអាចប្រើប្រាស់បច្ចេកវិទ្យាគាំទ្រផ្សេងៗ ដើម្បីបង្រៀន និងរៀនមុខវិជ្ជាស្ទែម | ៤.៤៨ | ០.៦៦ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ៨ | ផ្តល់លទ្ធភាពដល់គ្រូក្នុងការបត់បែនទៅតាមលក្ខខណ្ឌរបស់សិស្សដើម្បីសម្រេចគោលបំណងមេរៀន | ៤.៤៤ | ០.៦២ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |
| ៩ | គ្រូអាចប្រើប្រាស់បច្ចេកវិទ្យា ក្នុងការវាយតម្លៃសិស្ស និងរក្សាទុកឯកសារ | ៤.៤៩ | ០.៦៦ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ១០ | លើកកម្ពស់ទំនាក់ទំនងរបស់សិស្សក្នុងថ្នាក់រៀន តាមរយៈសិស្សចូលរួម និងផ្តោតលើដំណើរការបង្រៀនរបស់គ្រូ | ៤.៤៧ | ០.៦៦ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ១១ | គ្រូចូលរួមក្នុងសហគមន៍សិក្សាវិជ្ជាជីវៈទៅតាមឯកទេសរៀងៗខ្លួន | ៤.៤៧ | ០.៧២ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ១២ | ជំរុញការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ក្នុងការរៀន និងបង្រៀន | ៤.៤៦ | ០.៧១ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ១៣ | គ្រូណែនាំសិស្សឱ្យចេះស្រាវជ្រាវលំហាត់ឬមេរៀននៅលើបណ្តាញសង្គផ្សេងៗ | ៤.៥៣ | ០.៧០ | ល្អណាស់ | ៤.៣៣ | ០.៥៨ | ល្អណាស់ |

| ល.រ | ការអនុវត្តគោលនយោបាយអប់រំស្ទែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | |
|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
| ១៤ | សិស្សទទួលបានបទពិសោធន៍ជាច្រើនពីការប្រើប្រាស់បច្ចេកវិទ្យា តាមរយៈដំណើរការបង្រៀនរបស់គ្រូ | ៤.៥៤ | ០.៦៦ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ១៥ | ជំរុញការច្នៃប្រឌិតថ្មីៗ និងនវានុវត្តន៍ តាមរយៈការប្រើបច្ចេកវិទ្យាក្នុងថ្នាក់រៀន | ៤.៥៤ | ០.៦៣ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| ១៦ | សិស្សអាចសម្របខ្លួនជាមួយបន្ទប់រៀនវៃឆ្លាត និងបណ្ណាល័យទំនើប ដែលប្រើប្រាស់ដោយប្រព័ន្ធអ៊ីនធឺណិតក្នុងការស្រាវជ្រាវមេរៀន | ៤.៤៧ | ០.៦៩ | ល្អណាស់ | ៤.៦៧ | ០.៥៨ | ល្អណាស់ |
| សរុប | | ៤.៤៩ | ០.៦៦ | ល្អណាស់ | ៤.៥៦ | ០.៥៤ | ល្អណាស់ |

តាមតារាង៤.១០ ទិន្នន័យដែលបានពីគ្រូបង្រៀនបានបង្ហាញថាការអនុវត្តគោលនយោបាយអប់រំស្ទែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមពិន្ទុ=៤.៤៩)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "បានជំរុញគ្រូអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៥៦)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតគឺ "បានអនុវត្តសម្ភារៈឧបទេស ឆ្លើយតបមុខវិជ្ជាស្ទែម នៅក្នុងសាលារៀនដើម្បីចូលរួមកសាងសង្គមឌីជីថល" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៤១)។

គណៈគ្រប់គ្រងសាលាបានផ្តល់ទិន្នន័យលើការអនុវត្តគោលនយោបាយអប់រំស្ទែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមពិន្ទុ៤.៥៦)។ សូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "បានជំរុញគ្រូ អនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមពិន្ទុ=៥.០០)។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតមានចំនួន ៦ សូចនាករ គឺ៖ "បានរៀបចំសមត្ថភាពគ្រូបង្រៀនឆ្លើយតបទៅនឹងតម្រូវការអប់រំសតវត្សទី២១" "បានជំរុញគ្រូអនុវត្តតាមគន្លងអាជីពវិជ្ជាជីវៈគ្រូបង្រៀន" "បានអនុវត្តសម្ភារៈឧបទេស ឆ្លើយតបមុខវិជ្ជាស្ទែម នៅក្នុងសាលារៀនដើម្បីចូលរួមកសាងសង្គមឌីជីថល" "ផ្តល់ឱកាសដល់គ្រូបង្រៀនធ្វើកិច្ចការស្រាវជ្រាវ និងបង្កើតគំនិតនវានុវត្តន៍" "ផ្តល់លទ្ធភាពដល់គ្រូក្នុងការបត់បែនទៅតាមលក្ខខណ្ឌរបស់សិស្សដើម្បីសម្រេចគោលបំណងមេរៀន" "គ្រូណែនាំសិស្សឱ្យចេះស្រាវជ្រាវលំហាត់ ឬមេរៀននៅលើបណ្តាញសង្គផ្សេងៗ" ក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៣៣) ស្មើៗគ្នា។

### ៤.៤.២ ទិន្នន័យគុណវិស័យ

ភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀន របស់គ្រូនៅសាលារៀនជំនាន់ថ្មី។ តាមទិន្នន័យដែលទទួលបានពីការសម្ភាសន៍ អ្នកចូលរួមភាគច្រើនបានលើកឡើងពីភាពចាំបាច់ក្នុងការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី ដើម្បីជំរុញ និងពង្រឹងប្រសិទ្ធភាពរបស់គ្រូបង្រៀន ស្របទៅតាមគន្លងអាជីពវិជ្ជាជីវៈ និងការអប់រំនៅសតវត្សទី២១។

> "........ការអនុវត្តគោលនយោបាយអប់រំស្ទែមនៅសាលារៀនជំនាន់ថ្មី បានជំរុញការចូលរួមរបស់គ្រូ ក្នុងការផ្សារភ្ជាប់ទ្រឹស្តីជាមួយការអនុវត្ត និងគំនិតបង្កើតថ្មី ឆ្លើយតបទៅនឹងតម្រូវការសិក្សារបស់សិស្សថ្នាក់វិទ្យាសាស្ត្រ។ សិស្សានុសិស្សអាច ស្វែងយល់ពីលក្ខណៈវិទ្យាសាស្ត្រនៃបាតុភូត និងប្រតិកម្មគីមីតាមរយៈដំណើរការពិសោធន៍របស់គ្រូ ព្រមទាំងទម្លាប់ក្នុងគន្លងនៃការសិក្សាដោយខ្លួនឯង...."

(KI#1, 4, 5)

‶....កិច្ចគាំទ្រពីថ្នាក់ដឹកនាំ លើការផលិតសម្ភារៈសម្រាប់បង្រៀន និងការបង្កលទ្ធភាពឱ្យគ្រូបង្រៀនធ្វើការស្រាវជ្រាវដោយខ្លួនឯង គឺជាកត្តាអាទិភាព ដែលមានភាពបន្សុីគ្នាជាមួយឥទ្ធិពលបច្ចេកវិទ្យាក្នុងយុគសម័យឌីជីថល។ តាមរយៈការសិក្សា លើការផលិតសម្ភារៈឧបទេសតាមមេរៀន អាចជំរុញឱ្យគ្រូបង្រៀនបង្កើតបានបណ្តាញវិជ្ជាជីវៈតាមឯកទេស ទាំងក្នុងសាលារៀនជំនាន់ថ្មី និងបណ្តាញក្នុងប្រទេសផងដែរ....″

(KI#3, 6, 7, 9)

‶....ក្នុងបរិការណ៍នៃការបំពេញការងារនៅសាលារៀនជំនាន់ថ្មី គ្រូបង្រៀនគឺត្រូវការជាចាំបាច់ណាស់ នូវការលើកទឹកចិត្ត និងការផ្តល់គុណតម្លៃលើឯកទេសតាមវិជ្ជាជីវៈពីថ្នាក់ដឹកនាំ ពីគ្រូបង្រៀន ពីសហគមន៍ និងសិស្សានុសិស្សជាដើម។ ភាពពេញចិត្តរបស់គ្រូ បានជំរុញឱ្យការច្នៃប្រឌិតកើតឡើង និងមានលក្ខណៈប្រកួតប្រជែង ក្នុងបណ្តាញវិជ្ជាជីវៈ....″

(KI#2, 5, 8)

## ៤.៥. ពិភាក្សាលើការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនជំនាន់ថ្មី ផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ

គ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន និងអ្នកឯកទេសអប់រំជាផ្នែកមួយដ៏សំខាន់ចូលរួមក្នុងការផលិតមូលធនមនុស្ស។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយអប់រំ និងបទដ្ឋានគតិយុត្តិផ្សេងៗសម្រាប់អភិវឌ្ឍ និងលើកកម្ពស់គុណភាពគ្រូបង្រៀន សំដៅធានាបានថាគុណភាពអប់រំ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារសេដ្ឋកិច្ច។ ការរៀបចំគន្លងអាជីពគ្រូបង្រៀនមានចក្ខុវិស័យកសាងគ្រូបង្រៀនឱ្យមានស្តង់ដាចំណេះដឹង ជំនាញ សីលធម៌ និងសមត្ថភាពអនុវត្តវិជ្ជាជីវៈដោយមានការទទួលស្គាល់ពី សិស្សានុសិស្ស សហគមន៍ និងសង្គមហើយឆ្លើយតបទៅនឹងការប្រែប្រួលសង្គម បរិបទក្នុងតំបន់ បរិបទសកលលោក និងតម្រូវការសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចជាតិព្រមទាំងអាចដោះស្រាយបញ្ហាប្រឈមក្នុងវិស័យអប់រំដែលកំពុងតែជួបប្រទះយ៉ាងច្រើន។

### តារាង៤.១១៖ សង្ខេបការអនុវត្តគោលនយោបាយអប់រំស្ទែម បានផ្ដល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ

| បរិយាយ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុប | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|---|---|
| | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | | |
| នយោបាយអប់រំស្ទែមផ្ដល់កិច្ចគាំទ្រដល់ការបង្រៀន | ៤.៤៩ | ០.៦៦ | ល្អណាស់ | ៤.៥៦ | ០.៥៤ | ល្អណាស់ | ៤.៥២ | ល្អណាស់ |

តាមរយៈតារាង៤.១១ ទិន្នន័យដែលបានពីគ្រូបង្រៀនបានបង្ហាញថាការអនុវត្តគោលនយោបាយអប់រំស្ទែម ផ្ដល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូទទួលបានពិន្ទុ ឋិតក្នុងកម្រិត ”ល្អណាស់” (មធ្យមភាគពិន្ទុសរុប= ៤.៥២)។ ក្នុងន័យនេះបង្ហាញពីការយល់ឃើញស្របគ្នារវាងភាគីទាំងពីរទៅលើការផ្ដល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូដែលបង្ហាញពីការយកចិត្តទុកដាក់របស់គណៈគ្រប់គ្រងក្នុងការផ្ដល់ការគាំទ្រដល់ការបង្រៀនស្ទែម ដោយផ្ដល់ការអភិវឌ្ឍសមត្ថភាពគ្រូជាបន្តបន្ទាប់។ តាមរយៈទិន្នន័យបរិមាណវិស័យទាំងពីរខាងលើយល់ស្របគ្នាលើសូចនាករដែលទទួលបានពិន្ទុខ្ពស់បំផុតគឺ "បានជំរុញគ្រូអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ” ឋិតក្នុងកម្រិត "ល្អណាស់” ដូចគ្នាដោយទិន្នន័យដែលបានពីគ្រូមានមធ្យមភាគពិន្ទុ=៤.៥៦ និងគណៈគ្រប់គ្រងមានមធ្យមភាគ=៥.០០។ ទិន្នន័យនេះបញ្ជាក់ថាគណៈគ្រប់គ្រងយកចិត្តទុកដាក់គាំទ្រឱ្យគ្រូអនុវត្តវិធីសាស្ត្រថ្មីៗក្នុងការបង្រៀន អភិវឌ្ឍសមត្ថភាពលើវិធីសាស្ត្របង្រៀនស្ទែម។ សូចនាករដែលទទួលបានពិន្ទុទាបបំផុតមានចំនួន ៦ សូចនាករ គឺ៖ "បានរៀបចំសមត្ថភាពគ្រូបង្រៀនឆ្លើយតបទៅនឹងតម្រូវការអប់រំសតវត្សទី២១” ,”បានជំរុញគ្រូអនុវត្តតាមគន្លងអាជីពវិជ្ជាជីវៈគ្រូបង្រៀន” ,”បានអនុវត្តសម្ភារៈឧបទេស ឆ្លើយតបមុខវិជ្ជាស្ទែមនៅក្នុងសាលារៀនដើម្បីចូលរួមកសាងសង្គមឌីជីថល” ”ផ្ដល់ឱកាសដល់គ្រូបង្រៀនធ្វើកិច្ចការស្រាវជ្រាវ និង

បង្កើតគំនិតនវានុវត្តន៍" "ផ្តល់លទ្ធភាពដល់គ្រូក្នុងការបត់បែនទៅតាមលក្ខខណ្ឌរបស់សិស្សដើម្បីសម្រេចគោលបំណងមេរៀន" "គ្រូណែនាំសិស្សឱ្យចេះស្រាវជ្រាវលំហាត់ ឬមេរៀននៅលើបណ្តាញសង្គផ្សេងៗ" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុ=៤.៣៣) ស្មើៗគ្នា។

ដោយយោងទៅតាមទិន្នន័យស្តីពីការអនុវត្តគោលនយោបាយអប់រំស្នែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូបានរកឃើញសូចនាករមួយចំនួនដែលទទួលបានពិន្ទុទាបបំផុត ឋិតក្នុងកម្រិត "ល្អ" (មានមធ្យមភាគពិន្ទុ=៤.៣៣) ដែលត្រូវពង្រឹងការអនុវត្តបន្ថែមដូចជា៖ ១) រៀបចំកញ្ចប់សមត្ថភាពរបស់គ្រូដោយគោរពតាមគន្លងអាជីពគ្រូបង្រៀន ២) ផ្តល់ឱកាសបន្ថែមទៀតឱ្យគ្រូបង្រៀនធ្វើកិច្ចការស្រាវជ្រាវ និងបង្កើតគំនិតនវានុវត្តន៍ ៣) ផ្តល់លទ្ធភាពដល់គ្រូមានភាពបត់បែនក្នុងការបង្រៀនទៅតាមលក្ខខណ្ឌរបស់សិស្សដើម្បីសម្រេចគោលបំណងមេរៀន ៤) ជំរុញឱ្យគ្រូបានអនុវត្តសម្ភារៈឧបទេសឆ្លើយតបមុខវិជ្ជាស្នែម នៅក្នុងសាលារៀនដើម្បីចូលរួមកសាងសង្គមឌីជីថល និង៥) គ្រូណែនាំសិស្សឱ្យចេះស្រាវជ្រាវលំហាត់ ឬមេរៀននៅលើបណ្តាញសង្គមផ្សេងៗ។

**តារាង៤.១២៖ សង្ខេបសូចនាករមានមធ្យមភាគខ្ពស់ និងទាបស្តីការអនុវត្តគោលនយោបាយអប់រំស្នែម បានផ្តល់កិច្ចគាំទ្រដល់ការបង្រៀនរបស់គ្រូ**

| ល.រ | សូចនាករ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុប | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | | |
| ១ | បានជំរុញគ្រូអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ | ៤.៥៦ | ០.៦៨ | ល្អណាស់ | ៥.០០ | ០.០០ | ល្អណាស់ | ៤.៧៨ | ល្អណាស់ |
| ២ | បានអនុវត្តសម្ភារៈឧបទេសឆ្លើយតបមុខវិជ្ជាស្នែម នៅក្នុងសាលា | ៤.៤១ | ០.៧២ | ល្អ | ៤.៣៣ | ០.៥៨ | ល្អ | ៤.៣៧ | ល្អ |

| ល.រ | សូចនាករ | គ្រូបង្រៀន | | | គណៈគ្រប់គ្រង | | | សរុប | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|---|---|---|---|---|
| | | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ | | |
| | រៀនដើម្បីចូលរួមកសាងសង្គមឱ្យដីថល | | | | | | | | |
| | **សរុប** | ៤.៤៨ | ០.៧០ | ល្អណាស់ | ៤.១៧ | ០.២៩ | ល្អណាស់ | ៤.៣២ | ល្អណាស់ |

តាមតារាង៤.១២ បង្ហាញពីសូចនាករដែលទទួលបានមធ្យមភាគពិន្ទុខ្ពស់បំផុត និងទាបបំផុតដែលគ្រូបង្រៀន និងគណៈគ្រប់គ្រងយល់ស្របដូចគ្នា។ សូចនាករដែលទទួលបានមធ្យមភាគពិន្ទុខ្ពស់បំផុតដូចគ្នាគឺ "បានជំរុញគ្រូអនុវត្តវិធីសាស្រ្តបង្រៀនថ្មីៗ" ឋិតក្នុងកម្រិត "ល្អណាស់" (មធ្យមភាគពិន្ទុរួម=៤.៧៨)។ បានន័យថានាយកមានការយល់ឃើញ និងផ្តល់ភាពសំខាន់ដល់គុណភាពគ្រូបង្រៀននៅក្នុងដំណើរការរៀន និងបង្រៀន ហើយខិតខំជំរុញគ្រូឱ្យប្រើវិធីសាស្រ្តបង្រៀនដែលមានប្រសិទ្ធភាពសម្រាប់ការអប់រំស្វែម។ យោងតាម Bennell and Akyeampong (2007) ដើម្បីទទួលបានលទ្ធផលសិក្សារបស់សិស្សប្រសើរឡើងនៅប្រទេសកំពុងអភិវឌ្ឍគឺត្រូវពង្រឹងលើគុណភាពនៃការបង្រៀន។

តាមរយៈទិន្នន័យសម្ភាសន៍គុណវិស័យបានបង្ហាញថា ហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារូបវន្តគាំទ្រ និងតម្លាភាពរបស់គណៈគ្រប់គ្រងនៅសាលារៀនជំនាន់ថ្មី បានបង្កលក្ខណៈឱ្យការអនុវត្តគោលនយោបាយអប់រំស្វែមមានវិសាលភាពទូលំទូលាយ ព្រមទាំងបានជ្រាបចូលដល់គុណភាពនៃការអប់រំក្នុងថ្នាក់រៀនផងដែរ។ ទិន្នន័យដែលទទួលបានពីការសម្ភាសន៍ បានបញ្ជាក់បន្ថែមដូចខ្លឹមសារខាងក្រោមៈ

"…….ការអនុវត្តតាមគោលនយោបាយអប់រំស្វែម របស់នាយកសាលារៀនជំនាន់ថ្មី បានផ្តល់កិច្ចគាំទ្រដល់គ្រូបង្រៀនលើស្វ័យភាពនៃការសម្រេចចិត្តក្នុងដំណើរការបង្រៀន ពង្រឹងកញ្ចប់

សមត្ថភាពបន្ថែមលើជំនាញវិជ្ជាជីវៈ បំណិនក្នុងការប្រើប្រាស់បច្ចេកវិទ្យាដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងឆ្លើយតបទាន់ពេលវេលាទៅនឹងការអប់រំក្នុងយុគសម័យឌីជីថល....˝

(KI#1, 4, 8)

‶... ក្នុងកំណែទម្រង់ការអប់រំ ការពង្រឹងគុណភាពគ្រូបង្រៀន គឺជាចំណុចអាទិភាពឆ្លើយតបទៅនឹងការដាក់ចេញគោលនយោបាយអប់រំគាំទ្រជាច្រើន ក្នុងន័យបង្កលទ្ធភាពឱ្យគ្រូបង្រៀនអភិវឌ្ឍលើសមត្ថភាពរបស់ខ្លួនជាប់ជាប្រចាំ ព្រោះថាការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស គឺអាស្រ័យលើដំណើរការនៃការផ្ទេរចំណេះដឹងរបស់គ្រូ និងធានាបានគុណភាពនៃការសិក្សារៀនសូត្រ...˝

(KI#1, 3, 5, 7)

‶...សាលារៀនផ្តល់កិច្ចគាំទ្រដល់គ្រូបង្រៀន នោះគ្រូបង្រៀនអាចផ្តល់កិច្ចគាំទ្រដល់សិស្សានុសិស្សបានផងដែរ តាមរយៈដំណើរការបង្រៀន ការលើកទឹកចិត្ត ការបណ្តុះស្មារតីស្រឡាញ់ការសិក្សា និងការប្រកួតប្រជែងអាស្រ័យលើសមត្ថភាពពិតជាក់ស្តែង...˝

(KI#2, 3, 5, 9)

តាមរយៈទិន្នន័យបរិមាណវិស័យ និងគុណវិស័យ អ្នកសិក្សាស្រាវជ្រាវអាចទាញសេចក្តីសន្និដ្ឋានបានថា ដើម្បីជំរុញលទ្ធផលសិក្សារបស់សិស្សឱ្យកាន់តែមានភាពប្រសើរឡើង ការផ្តល់កិច្ចគាំទ្រដល់ដំណើរការបង្រៀនរបស់គ្រូ តាមរយៈការអនុវត្តគោលនយោបាយអប់រំស្នេមរបស់នាយកសាលារៀនជំនាន់ថ្មី គឺជាការចាំបាច់ និងត្រូវបានលើកកម្ពស់។ ដោយផ្អែកលើការស្រាវជ្រាវនានា បានបង្ហាញថាបញ្ហាប្រឈមមួយក្នុងវិស័យអប់រំគឺគុណភាពគ្រូបង្រៀន គុណភាពគ្រូជាកត្តាកំណត់គន្លឹះលើការសិក្សារបស់សិស្ស។ បញ្ហាប្រឈមនេះអាចត្រូវបានដោះស្រាយតាមរយៈការគាំទ្រ និងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ យោងតាម Ejiwale (២០១៣) បានលើកឡើងថាបរិក្ខារូបវន្តគាំទ្រដល់ការបង្រៀន និងរៀនមានស្ថានភាពខ្សោយ ដែលធ្វើឱ្យការ

អនុវត្តការអប់រំស្វែម នៅតែជាកង្វល់ និងជួបបញ្ហាប្រឈមច្រើននៅក្នុងប្រទេសកម្ពុជាយើងដែលទាមទារការយកចិត្តទុកដាក់លើបញ្ហានេះជាចាំបាច់។

ការអនុវត្តគោលនយោបាយអប់រំស្វែមនៅសាលារៀនជំនាន់ថ្មី បានធ្វើឱ្យគ្រូទទួលបានការបណ្តុះបណ្តាលលើការអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់។ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន គឺសំដៅលើកាធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពគ្រូក្នុងដំណើរការបង្រៀន ដែលគ្រូអាចបង្រៀនសិស្សដោយភាពច្បាស់លាស់ មានលក្ខណៈវិទ្យាសាស្ត្រ និងការផ្ទេរចំណេះដឹងពិតប្រាកដ។ គ្រូបង្រៀន ក៏អាចទទួលបានការអភិវឌ្ឍសមត្ថភាពតាមរយៈ ការចូលរួមសិក្ខាសិលា ការប្រឹក្សាគរុកោសល្យ ការសិក្សាស្រាវជ្រាវដោយខ្លួនឯង និងការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈជាដើម។ គ្រូបង្រៀន គម្បីប្រកាន់ជំហរអភិវឌ្ឍន៍សមត្ថភាពជាប្រចាំ ជាអ្នកសិក្សារៀនសូត្រពេញមួយជីវិត និងផ្សារភ្ជាប់ទំនាក់ទំនងជាមួយសិស្ស និងគ្រូបង្រៀនផ្សេងទៀត (Fenstermacher, 1994; Kennedy, 2002; Munby, Russell & Martin, 2001)។ តាមការសិក្សាស្រាវជ្រាវរបស់ K Van Veen, R Zwart, and J Meirink (2012) បានបង្ហាញថាលទ្ធផលសិក្សារបស់សិស្សទទួលបានកម្រិតខ្ពស់ មានភាពជាប់ពាក់ព័ន្ធទៅនឹងសមត្ថភាពរបស់គ្រូបង្រៀនដែលអនុវត្តតាមកម្មវិធីសិក្សា និងគោលនយោបាយអប់រំនៅក្នុងថ្នាក់រៀន ព្រមទាំងស្របទៅនឹងបរិបទសង្គម។ តាមការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថាគ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាល និងសិក្សាច្រើនអាចជួយឱ្យការបង្រៀនមានមហិច្ឆតា និងមានប្រសិទ្ធភាពជាងមុន។ ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូចូលរួមពង្រឹងក្នុងដំណើរការសាលារៀនគឺត្រូវកសាងការយល់ដឹងអំពីគុណភាពផ្ទាល់ខ្លួនរបស់គ្រូ សក្តានុពល និងការចង់ចេះចង់ដឹងរបស់គ្រូទាំងឡាយរបស់គ្រូដែលគាំទ្រដល់សមត្ថភាពគរុកោសល្យ និងការបង្ហាត់បង្ហាញសិស្សឱ្យប្រសើរឡើង។ ការសិក្សាស្រាវជ្រាវខាងលើក៏បានបង្ហាញផងដែរថាការផ្លាស់ប្តូរជាវិជ្ជមានកើតមានចំពោះការបំពេញការងាររបស់គ្រូដែល គ្រូពិសោធន៍ជាបន្តបន្ទាប់ និងការអភិវឌ្ឍវិជ្ជាជីវៈដែលមានគុណភាពខ្ពស់(Rhoton & Stile, 2002)។

ការអភិវឌ្ឍសមត្ថភាពឱ្យឆ្លើយតបទៅនឹងតម្រូវការអប់រំស្នែម គឺជាផ្តល់ការគាំទ្រដល់គ្រូលើសមត្ថភាពច្រើនយ៉ាងតាមសម័យទំនើបនេះ។ ជារឿងសំខាន់ដែលត្រូវយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពគ្រូព្រោះគ្រូបង្រៀនជាអ្នកមានឥទ្ធិពលដោយផ្ទាល់ទៅលើដំណើរការបង្រៀន និងរៀន លទ្ធផលសិក្សារបស់សិស្សអាស្រ័យលើអន្តរកម្មរវាងសិស្ស និងគ្រូដែលគ្រូត្រូវរៀបចំខ្លឹមសារមេរៀន វិធីសាស្ត្របង្រៀន រៀបចំបរិស្ថានថ្នាក់រៀន ការវាយតម្លៃឱ្យមានភាពទាក់ទាញដល់សិស្សឱ្យមានចំណាប់អារម្មណ៍រៀន។ យោងតាម Norton and Kelly (2013) បានបង្ហាញថានាយកសាលាមិនមានឥទ្ធិពលផ្ទាល់ទៅលើការសិក្សារបស់សិស្សទេ ប៉ុន្តែនាយកសាលាមានឥទ្ធិពលដោយប្រយោលទៅលើគណៈគ្រប់គ្រង និងគ្រូបង្រៀនដែលជាអ្នកជះឥទ្ធិពលដល់ការសិក្សារបស់សិស្សានុសិស្ស។ កាលណាគ្រូបង្រៀនមានសមត្ថភាពកាន់តែខ្ពស់ ការបង្រៀនកាន់តែមានគុណភាព។ ដើម្បីអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ គោលការណ៍ឱ្យសម្រេចតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំត្រូវការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យបានពេញលេញជាមុនសិន។ លោកបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថា "គ្រូបង្រៀនជាបេះដូងនៃកំណែទម្រង់វិស័យអប់រំដើម្បីអភិវឌ្ឍ"។ ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន នាយកអាចសហការណ៍ជាមួយគ្រូក្នុងការកំណត់គោលដៅការអភិវឌ្ឍសមត្ថភាពដូចជាការប្រើប្រាស់ ICT វិធីសាស្ត្របង្រៀន ការសង្កេតថ្នាក់រៀន និងការអនុវត្តគន្លងអាជីគ្រូបង្រៀន។ ការផ្តល់ការអភិវឌ្ឍសមត្ថភាពទាំងឡាយនេះក្នុងគោលបំណងឱ្យគ្រូអាចបង្រៀន និងរៀនបែបនវានុវត្ត ដើម្បីចូលរួមអភិវឌ្ឍជំនាញសតវត្សរ៍ទី២១ដល់សិស្ស។ យោងតាម Koehler and Mishra (2009) គ្រូនៅក្នុងយុគសម័យឌីជីថលត្រូវមានកញ្ចប់សមត្ថភាពដែលរួមគ្នានូវចំណេះដឹងសំខាន់ៗចំនួន ៣ ដូចជា៖ ១) ចំណេះដឹងបច្ចេកវិទ្យា ២)ចំណេះដឹងខ្លឹមសារមេរៀន និង៣)ចំណេះដឹងគរុកោសល្យ។ ចំណេះដឹងបច្ចេកវិទ្យាគ្រូត្រូវមានចំណេះដឹងស្តីពីកុំព្យូទ័រ អ៊ីនធឺណិត វីដេអូឌីជីថល ក្តារខៀនឆ្លាត ដើម្បីប្រើប្រាស់ក្នុងការបង្រៀន និងរៀនឱ្យសិស្សយល់ពីចំណេះដឹងក្នុងកម្មវិធីសិក្សាបានច្បាស់គឺបច្ចេកវិទ្យាផ្លាស់ប្តូរពីរបៀបបង្រៀនរបស់គ្រូពីការបង្រៀនតាមបែបប្រពៃណីមកមានសមត្ថភាពបង្រៀនតាមស្នែម។ ចំណែកឯចំណេះដឹងពីខ្លឹម

សារមេរៀនជាចំណេះដឹងពីមុខវិជ្ជាដែលត្រូវបង្រៀនត្រូវចេះសំយោគបញ្ចូលគ្នានូវខ្លឹមសារដែលត្រូវបង្រៀន និងវិធីសាស្ត្រឱ្យស្របទៅនឹងរបៀបរៀនរបស់សិស្ស បរិបទរស់នៅ វត្ថុបំណងនៃកម្មវិធីសិក្សាជាដើម។ ចំណេះដឹងគរុកោសល្យជាចំណេះដឹងពីវិធីសាស្ត្របង្រៀន និងដំណើរការបង្រៀនជាពិសេសវិធីសាស្ត្របង្រៀនទំនើបថ្មីៗ ការរៀបចំកិច្ចតែងការបង្រៀន។ គ្រូត្រូវបញ្ចូលនូវសមាសភាគទាំងបីនៃកញ្ចប់សមត្ថភាពរបស់គ្រូនេះដើម្បីលើកកម្ពស់ការបង្រៀន និងរៀនក៏ដូចជាលទ្ធផលសិក្សារបស់សិស្ស។

ជារួមការដែលប្រើប្រាស់ភាពជាអ្នកដឹកនាំរបស់នាយកតាមការគ្រប់គ្រងសាលាដោយឈរលើលទ្ធផល និងការអនុវត្តតាមគោលនយោបាយអប់រំស្នែម បានគាំទ្រដល់គ្រូបង្រៀនដោយបានផ្តល់ការអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់ដើម្បីក្លាយជាគ្រូបង្រៀនម្នាក់មានសមត្ថភាពស្តង់ដាវិជ្ជាជីវៈខ្ពស់អាចផ្តល់ឱ្យសិស្សនូវចំណេះដឹងសតវត្សរ៍ទី២១ ឆ្លើយតបទៅនឹងការប្រែប្រួលសង្គម និងតម្រូវការដើម្បីអភិវឌ្ឍសេដ្ឋកិច្ច។ គ្រូបង្រៀនជាកម្លាំងចលករជួរមុខមិនអាចខ្វះបានសម្រាប់ចូលរួមក្នុងកំណែទម្រង់អភិវឌ្ឍវិស័យអប់រំ។ ដូចនេះគុណភាពគ្រូជាចំណុចសំខាន់ដែលត្រូវតែអភិវឌ្ឍ និងផ្តល់តម្លៃដូចច្បាប់ស្តីពីការអប់រំបានចែងថា "បុគ្គលិកអប់រំមានសិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ខ្ពស់ពីសង្គម និងមានសិទ្ធិអភិវឌ្ឍន៍ខាងវិជ្ជាជីវៈ។ ជាក់ស្តែងនៅប្រទេសកម្ពុជាក៏ដូចជាប្រទេសជាច្រើនផ្សេងទៀតគ្រូបង្រៀនមិនសូវមានឱកាសអភិវឌ្ឍវិជ្ជាជីវៈ និងគ្មានតំណែងបន្តខ្ពង់ខ្ពស់បន្តទៀតទេពោលគឺមានងារជាគ្រូបង្រៀនពេញមួយជីវិតហើយកត្តានេះអាចធ្វើឱ្យប៉ះពាល់ដល់គុណភាពអប់រំ។ ដោយយល់ឃើញដូចច្នេះហើយទើបក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគន្លងអាជីពគ្រូបង្រៀនដើម្បីចូលរួមពង្រឹងគុណភាពការបង្រៀន និងរៀន (MoEYS, 2018)។ ក្នុងន័យនេះនាយកសាលារៀនជំនាន់ថ្មី ខិតខំអនុវត្តតាមគន្លងអាជីពគ្រូផ្តល់ឱ្យនូវការអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់ផ្តល់សេចក្តីថ្លៃថ្នូរដល់គ្រូបង្រៀន។ ដូចនេះការអនុវត្តការបំពេញការងារនៅក្នុងសាលានេះបានឆ្លើយតបទៅនឹងកំណែទម្រង់ និងគោលនយោបាយអប់រំនានាក្នុងវិស័យអប់រំបានល្អហើយបានលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សផងដែរ។

# ជំពូកទី៥
# សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្ដីសន្និដ្ឋាន

គ្រឹះស្ថានអប់រំជាភ្នាក់ងារសំខាន់មួយអនុវត្តគោលនយោបាយអប់រំដែលក្រសួងអប់រំរៀបចំឡើងស្រប ទៅនឹងគោលនយោបាយជាតិទាំងឡាយដើម្បីធ្វើឱ្យសម្រេចបាននូវចក្ខុវិស័យអភិវឌ្ឍប្រទេសរបស់រាជរដ្ឋាភិបាល។ ភាពជាអ្នកដឹកនាំគ្រប់គ្រងរបស់នាយកសាលាពិតជាបានដើរតួនាទីសំខាន់លើការសម្រេចបាននូវភាពជោគជ័យរបស់សាលារៀន។ ប្រសិទ្ធិភាពនៃភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារបស់នាយកបានបានប្រែក្លាយសាលារៀនឱ្យមានភាពល្អប្រសើរឡើងដែលជាការចូលរួមចំណែកក្នុងកំណែទម្រង់វិស័យអប់រំទទួលបានជោគជ័យ និងបណ្ដុះបានមូលធនមនុស្សឆ្លើយតបតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការសិក្សាស្រាវជ្រាវស្ដីពី "ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្ដីពីការអប់រំវិទ្យាសស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ" មានគោលបំណងស្វែងយល់ពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្ដីពីការអប់រំស្ទែម ព្រមទាំងកិច្ចគាំទ្រនៃទំនាក់ទំនងនេះដល់ការបង្រៀនរបស់គ្រូ។

លទ្ធផលដែលបានពីការស្រាវជ្រាវនេះបានបង្ហាញថាភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែមនៅសាលារៀនជំនាន់ថ្មី ទទួលបានមធ្យមពិន្ទុក្នុងកម្រិត "ល្អណាស់" ដូចគ្នា នាយកអនុវត្តតាមការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល។ តាមទិន្នន័យរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម នៅសាលារៀនខាងលើ មានទំនាក់ទំនងគ្នាល្អណាស់។ ការអនុវត្តគោលនយោបាយអប់រំស្ទែម និងអនុវត្តភាពជាអ្នកដឹកនាំរបស់នាយកតាមការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល។ មានភាពឆ្លើយតបគ្នាទៅវិញទៅមកដើម្បីលើកកម្ពស់ប្រសិទ្ធភាពបំពេញការងាររបស់គ្រូបង្រៀន និងលទ្ធផលសិក្សារបស់សិស្សដោយផ្ដល់នូវចំណេះដឹងសតវត្សរ៍ទី២១ឆ្លើយតបទៅនឹងយុគសម័យឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម ៤.០។ នាយកបំពេញការងាបានល្អឈរលើសុច្ចរិតភាព មានសមត្ថ

ភាពក្នុងការដឹកនាំ និងអាចដោះស្រាយបញ្ហាប្រឈមដែលកើតមាននៅក្នុងសាលាបានល្អ នាំឱ្យគ្រូបង្រៀនចូលរួមបំពេញការងារយ៉ាងសកម្ម ព្រមទាំងមានទំនាក់ទំនងល្អជាមួយសហគមន៍ អាណាព្យាបាលចូលរួមគាំទ្រធ្វើឱ្យដំណើរការសាលារៀនប្រព្រឹត្តទៅបានល្អ រួមផ្សំនឹងបរិបទសាលារៀនជំនាន់ថ្មី អនុវត្តការអប់រំស្នែម ថែមទាំងនាយកសាលាបានខិតខំជំរុញគាំទ្រផ្នែកធនធាន និងបច្ចេកទេស និងពិនិត្យតាមដានការអនុវត្តដោយសកម្មដើម្បីឱ្យលទ្ធផលសិក្សារបស់សិស្សមានភាពល្អប្រសើរ។ ក្នុងករណីភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែមមិនមានទំនាក់ទំនងគ្នានឹងជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃការធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំហើយជះឥទ្ធិពលដល់ដំណើរការបង្រៀន និងរៀនហើយលទ្ធផលសិក្សារបស់សិស្សក៏មិនត្រូវបានលើកម្ពស់ដើម្បីឱ្យឆ្លើយតបទៅនឹងបរិបទសង្គមឌីជីថលផងដែរ។ ប៉ុន្តែការអនុវត្តទាំងនេះមិនមានភាពល្អស្មើគ្នាគ្រប់សូចនាករទាំងអស់ទេ ត្រូវពង្រឹងលើការស្វះស្វែងរកវង្វាន់លើកទឹកចិត្តពីស្ថាប័នពាក់ព័ន្ធបន្ថែមទៀតដល់គ្រូដែលខិតខំបំពេញការងារ និងជួបការលំបាក ការផ្តល់ព័ត៌មានជាប្រចាំស្តីពីការគ្រប់គ្រង និងសំណូមពររបស់គ្រូ វាយតម្លៃថ្នាក់រៀនជាប្រចាំដោយឈរលើលទ្ធផលសិក្សារបស់សិស្ស បន្ថែមទៀតដើម្បីឱ្យការគ្រប់គ្រងនៅសាលារៀនជំនាន់ថ្មីកាន់តែមានប្រសិទ្ធភាព និងមានការទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋាន។

ភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នែម បានផ្តល់ការគាំទ្រដល់ការបង្រៀនរបស់គ្រូនៅសាលារៀនជំនាន់ថ្មី បានក្នុងកម្រិត "ល្អណាស់" ដោយបានអភិវឌ្ឍសមត្ថភាពគ្រូលើវិជ្ជាជីវៈ។ សមត្ថភាពគ្រូក្នុងការបង្រៀនជាចំណុចគន្លឹះមួយក្នុងការចូលរួមលើកម្ពស់លទ្ធផលសិក្សារបស់សិស្ស តាមរយៈគុណភាពបង្រៀន។ សមត្ថភាពគ្រូដែលចាំបាច់សម្រាប់ការអប់រំស្នែម គឺត្រូវមានចំណេះដឹងលើខ្លឹមសារមេរៀន ចំណេះដឹងគរុកោសល្យ និងចំណេះដឹងបច្ចេកវិទ្យា ដើម្បីឱ្យសមស្របទៅនឹងតម្រូវការក្នុងការផ្តល់ចំណេះដឹងដល់សិស្សសម្រាប់យុគសម័យឌីជីថល។ នាយកបានផ្តល់កិច្ចគាំទ្រដល់ការអនុវត្តគោលនយោបាយអប់រំស្នែម បានល្អដូចជាបានជំរុញឱ្យគ្រូអនុវត្តវិធីសាស្ត្រថ្មីៗ គាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យា

ក្នុងការបង្រៀន និងរៀន និងសម្ភារៈបង្រៀន ដូចជាបន្ទប់វិទ្យាសាស្ត្រ បណ្ណាល័យទំនើប ព្រោះថាសម្ភារៈ និងវិធីសាស្ត្របង្រៀនដែលមានប្រសិទ្ធភាពជាចំណុចគន្លឹះសំខាន់ដើម្បីអនុវត្តគោលនយោបាយអប់រំស្នេមបានជោគជ័យ។ ទោះជាយ៉ាងណានៅមានសកម្មភាពខ្លះទៀតដែលនាយកត្រូវពង្រឹងដូចជាការប្រើប្រាស់សម្ភារៈឧបទេសឆ្លើយតបទៅនឹងការអប់រំស្នេម ព្រោះថាការប្រើប្រាស់សម្ភារៈឧបទេសមិនបានត្រឹមត្រូវ និងមិនគ្រប់គ្រាន់សម្រាប់ការអប់រំស្នេមធ្វើឱ្យដំណើរការបង្រៀនរបស់គ្រូមិនសម្រេចបានតាមវត្ថុបំណងមេរៀនហើយលទ្ធផលសិក្សារបស់សិស្សដែលទទួលបាននូវមានកម្រិតផងដែរ។ ការអភិវឌ្ឍសមត្ថភាពបង្រៀនរបស់គ្រូធ្វើឱ្យគ្រូទទួលបានកម្រិតស្តង់ដាវិជ្ជាជីវៈខ្ពស់ និងការអភិវឌ្ឍសមត្ថភាពបានទូលំទូលាយដើម្បីបង្កើនសមត្ថភាពសមត្ថភាពគ្រូបង្រៀនក្នុងការផ្តល់នូវចំណេះដឹង និងជំនាញស្របទៅនឹងកម្មវិធីសាលារៀនជំនាន់ថ្មីឆ្លើយតបទៅនឹងបរិបទការអប់រំបែបឌីជីថល និងការមកដល់នៃយុគសម័យបដិវត្តន៍ឧស្សាហកម្ម៤.០។

ជារួមភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្នេម នៅសាលារៀនជំនាន់ថ្មី មានភាពឆ្លើយតបគ្នា ដើម្បីលើកកម្ពស់ការបំពេញការងាររបស់គ្រូ និងបានជះឥទ្ធិពលលើលទ្ធផលសិក្សារបស់សិស្សធ្វើឱ្យសិស្សដែលរៀននៅទីនេះទទួលបាននូវចំណេះដឹងសតវត្សរ៍ទី២១។ ការអនុវត្តការគ្រប់គ្រងសាលារៀនដោយឈរលើលទ្ធផល និងការដាក់ឱ្យអនុវត្តគោលនយោបាយអប់រំស្នេម ជារឿងត្រឹមត្រូវសម្រាប់បរិបទកំណែទម្រង់វិស័យអប់រំនៅកម្ពុជា។ ដូចនេះដើម្បីទទួលបានធនធានមនុស្សកាន់តែច្រើនដើម្បីចូលរួមអភិវឌ្ឍប្រទេស ត្រូវបន្តអនុវត្តឧត្តមានុវត្តបែបនេះទៀតនេះ និងធ្វើវាឱ្យកាន់តែប្រសើរឡើង។ ដោយផ្អែកលើលទ្ធផលវិជ្ជមានបែបនេះសូមជំរុញការអនុវត្តបែបនេះដល់សាលារៀនផ្សេងទៀត។ បន្ថែមពីនេះទៀតក្នុងការដឹកនាំគ្រប់គ្រងសាលារៀន នាយសាលាត្រូវយកក្របខណ្ឌគោលនយោបាយអប់រំមកអនុវត្តព្រោះក្របខណ្ឌគោលនយោបាយអប់រំទាំងនោះឆ្លើយតបកំណែទម្រង់វិស័យអប់រំ គោលដៅអប់រំជាតិ គោលដៅអភិវឌ្ឍប្រទេស បរិបទតំបន់ និងសកល។

## ៥.២ សំណូមពរ

យោងតាមលទ្ធផលដែលបានរកឃើញរួមជាមួយសេចក្ដីសន្និដ្ឋាន អ្នកសិក្សាស្រាវជ្រាវសូមលើកឡើងនូវសំណូមពរមួយចំនួនដល់ភាគីពាក់ព័ន្ធដើម្បីរួមចំណែកបន្តលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែប្រសើរឡើងបន្ថែមទៀតដូចជា៖

**ក្រសួងអប់រំ យុវជន និងកីឡា**

- ពង្រឹងការអនុវត្តគោលនយោបាយអប់រំទី២ស្ដីពីការធានាភាពស័ក្ដសិទ្ធភាពនៃភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ដោយលើកកម្ពស់សមត្ថភាពនាយក
- ជំរុញការស្រាវជ្រាវ បង្កើតថ្មីរបស់គ្រូបង្រៀន ការអនុវត្តគន្លងអាជីពវិជ្ជាជីវៈគ្រូបង្រៀន ឬសហគមន៍សិក្សាវិជ្ជាជីវៈដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។

**នាយកដ្ឋានគោលនយោបាយអប់រំ**

- ជំរុញការអនុវត្តគោលនយោបាយអប់រំស្នែមនៅតាមសាលារៀន តាមរយៈការផ្សព្វផ្សាយ សន្និសីទរៀបចំយន្តការលើកកម្ពស់, វាយតម្លៃពិនិត្យតាមដានការអនុវត្តគោលនយោបាយ ឬប្រកួតប្រណាំងការអនុវត្តការអប់រំស្នែម នៅទុតិយភូមិ
- ពង្រឹងការត្រួតពិនិត្យតាមដានលើការអនុវត្តគោលនយោបាយអប់រំស្នែមនៅតាមសាលារៀន និងសិក្សាពីបញ្ហាប្រឈមនានា ក្នុងការអនុវត្តគោលនយោបាយអប់រំ។

**សាលារៀន**

- គណៈគ្រប់គ្រងសាលារៀនគួរតែជំរុញការផ្សព្វផ្សាយគោលនយោបាយអប់រំស្នែម និងតួនាទីសហគមន៍ក្នុងដំណើរការសាលារៀនដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សដល់មាតាបិតា និងសហគមន៍ឱ្យបានទូលំទូលាយបន្ថែមទៀត
- គណៈគ្រប់គ្រងគួរតែបន្តផ្ដល់ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនតាមរយៈការគាំទ្រការស្រាវជ្រាវ ការបង្កើតថ្មីដើម្បីចូលរួមគាំទ្រការបង្រៀនរបស់គ្រូកាន់តែប្រសើរឡើង។

**ផែនការគម្រោងអភិវឌ្ឍន៍សាលារៀន**

- ចូលរួមវិនិយោគនៅសាលារៀនជំនាន់ថ្មីបន្តទៀតដើម្បីបំពេញតម្រូវការនៅក្នុងសាលា និងកាត់បន្ថយបន្ទុករបស់អាណាព្យាបាលមកសាលារៀនជំនាន់ថ្មី
- បន្តចូលរួមបណ្តុះបណ្តាលសមត្ថភាពគ្រូបង្រៀនបន្ថែមទៀតលើវិធីសាស្ត្រ ខ្លឹមសារ បច្ចេកវិទ្យា ការស្រាវជ្រាវដើម្បីជំរុញការអនុវត្តគោលនយោបាយអប់រំនេះកាន់តែមានប្រសិទ្ធភាពខ្ពស់។

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *ផែនទីបង្ហាញផ្លូវការអប់រំមធ្យមសិក្សាឆ្នាំ២០៣០.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) *ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *ទស្សនាទានស្តីពីការគ្រប់គ្រងតាមសាលារៀន.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *របាយការណ៍សមិទ្ធិផលសាលារៀនជំនាន់ថ្មី ពាក់កណ្តាលឆ្នាំទី៣.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *ឯកសារស្តីពីយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *គោលការណ៍ណែនាំប្រតិបត្តិកម្មវិធីលារៀនជំនាន់ថ្មី.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *គោលនយោបាយស្តីកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការ.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *គោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *គោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មី.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) *គោលនយោបាយ និងយុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងការអប់រំនៅកម្ពុជា.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៣) *គោលនយោបាយស្តីពីការអប់រំបច្ចេកទេស.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១០) *ផែនការគោល បច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ក្នុងវិស័យអប់រំ.*ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន (២០២០) *កំណែទម្រង់សាលារៀននៅកម្ពុជា.* រាជធានីភ្នំពេញៈ ក្រសួងអប់រំ យុវជន និងកីឡានៃ

មជ្ឈមណ្ឌលកម្ពុជា៤.0 (២០២២). *ការអប់រំស្នែមនៅកម្ពុជា* បានទទួលពីៈ http://www.cambodia4point0.org/

រាជរដ្ឋាភិបាលកម្ពុជា (២០១៥) *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥).* ភ្នំពេញ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

Akinbode, A. I. & Shuhumi, S. R. A. (2018). The Principalship in The Twenty-first Century. International Journal of Teaching, Education and Learning, 2 (2), 137-138

Agustinus Bandur, (2008). A Study of The Implementation of School-Based Management in Flores Primary Schools in Indonesia.

Carpenter, D. (2015). School Culture and Leadership of Professional Learning Community. International Journal of Educational Management, 29(5), 682-694.

Char Vann, L. (2018). Questions regarding new generation school

Eric, R. Viggayan (2017). School-Based Management Practices of Public Secondary School´ Heads: Basis for Policy Recommendation. Journal of The SPUP Graduate School Research

Ejiwale, J. A. (2013). Barriers to Successful Implementation of STEM Education. Journal of Education and Learning.

Fowler, & Walter, (2020). Instructional Leadership: New Responsibilities for a New Reality. College & Research Libraries News, 64(7), 465-468. Retrieved from https://crin.acrl.acrl.org/index. php/crlnews/article/view,23725/31114.

Gamage, D. T. (2008). How did School-Based Governance Led to Distributed Leadership, Partnership and Improved Learning. Journal of the Centre for Research in Secondary Schools, 7, 27-41.

Gamage, D.T. (1998). How Community Participation Promotes Efficiency, Effectiveness, and Quality in Education. Journal of Educational Planning and Administration, 12 (3), 313-323.

Graham, P. (1991). What America has Expected of its Schools Over the Past Century. Paper Presented at the Conference on Democracy and Education. Chicago, Illinois.

Hallinger, P. (2009). Leadership for 21st Century Schools: From Instructional Leadership to Leadership for Learning. Hong Kong Institute of Education.

Hallinger, P. (2003). Leading Educational Change: Reflections on the Practice of

Instructional and Transformational Leadership. Cambridge Journal of Education, 33, 329-352.

Hallinger, P. (2005). Instructional Leadership and the School Principal: A Passing Fancy That Refuses to Fade Away. Leadership and Policy in School, 4, 221-239. http://dx.doi.org/10.1080/15700760500244793

Koch Im, Chhorvanna Lor, Morkaoth Pring, Sophea Mar, & Khek, S. (2019). Regional Symposium on STEM Education.

Kaing, S. (2016). How Can STEM Education Help Stimulate Economic Growth in Cambodia. Research Gate.

Melissa Donaher & Nuoya Wu, (2020). Cambodian New Generation School Reform.

Nur Farhana binti Ramli, Othm an bin Talib, Siti Aishah binti Hassan, & Manaf, U. K. b. A. (2017). STEM Instructional Implementation and its Challenges: A Systematic Review. ResearchGate.

Mattews, L.J. & Crow, G (2010). The Principalship: New Role in Professional Learning Community. USA: Pearson.

Mc Ewan, E. (2002). Seven Steps to Instructional Leadership. California: Corwin Press.

Sheninger. (2014). The Pillars of Digital Leadership. International Center for Leadership in Education

Whitehead, B. M., Boschee, F., & Decker, R. H. (2013). The Principal: Leadership for a Global Society. United States of America: SAGE.

Zapda, S. ( 2003 ). Instructional Supervision. Applying Tool and Concept. New York: Eye on Education.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ "ក"
## កម្រងសំណួរក្នុងការប្រមូលទិន្នន័យសម្រាប់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ (វិទ្យាល័យព្រះស៊ីសុវត្ថិ និងវិទ្យាល័យព្រែកលៀប)

នាងខ្ញុំឈ្មោះ កុយ ពៅគង់ ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី **«ទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយស្តីពីការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅសាលារៀនជំនាន់ថ្មី ក្នុងរាជធានីភ្នំពេញ»** ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះគឺដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំរបស់នាយក និងការអនុវត្តគោលនយោបាយអប់រំស្ទែម ព្រមទាំងកិច្ចគាំទ្រនៃទំនាក់ទំនងអថេរទាំងពីរនេះដល់គ្រូបង្រៀននៅសាលារៀនជំនាន់ថ្មីក្នុងរាជធានីភ្នំពេញ។ ទិន្នន័យដែលប្រមូលបានពីលោកគ្រូ-អ្នកគ្រូដែលជាគ្រូបង្រៀនមានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគឆ្លើយតបទៅនឹងប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបានមកនេះ គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះប៉ុណ្ណោះ។ ក្នុងន័យនេះសូមលោកគ្រូ-អ្នកគ្រូមេត្តាផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យនាងខ្ញុំអាចទទួលបានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវដែលអាចជឿជាក់និងទុកចិត្តបានក៏ដូចជាដើម្បីចូលរួមចំណែកក្នុងការពង្រឹងគុណភាពអប់រំឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍប្រទេស។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់លោកគ្រូ-អ្នកគ្រូ។

### ផ្នែកទី១៖ ព័ត៌មានទូទៅ

**ការណែនាំ ៖** សូមលោកគ្រូ-អ្នកគ្រូឆ្លើយសំណួរ និងគូសសញ្ញា (✓)នៅក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែង។

១.មុខវិជ្ជាឯកទេស៖..........................................................................................

២.បង្រៀនមុខវិជ្ជា៖.......................................................................................

៣.បង្រៀនថ្នាក់ទី៖.........................................................................................

